ទស្សនាវដ្តីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា




លេខ១០០ ខែមេសា ឆ្នាំ២០០៨

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត

លេខ២៨ ខែមេសា ឆ្នាំ២០០២

## មាតិកា

◆ សំបុត្រៈ សិទ្ធិមានជីវិត ....................................................១

**ផ្នែកឯកសារ**

◆ ឈិម សុជិត និស្សិតមកពីកាណាដា ....................................៤

◆ ប្រាក់ បូ ហៅ ប្រាក់ យូទ្រី អ្នកសួរចម្លើយ ........................៧

◆ សំបុត្រជូនទង់ក្រហមកិត្តិយស ............................................៨

◆ រាជសារ ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ .....១០

◆ទិន្នន័យទីតាំងរួមនៃអំពើប្រល័យពូជសាសន៍ ........................១៣

◆កម្មាភិបាលខ្មែរក្រហមនិងថ្ងៃ១៧ ខែមេសា .......................១៥

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ ........១៧

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ រូបថតឯកសារ.............................................................១៩

◆ កប់បាត់ទៅក្នុងបដិវត្តន៍ខ្មែរក្រហម .....................................២១

◆ សម្លេងពីមន្ទីរ ស-២១.....................................................២៥

◆ គាំភ្លើងធំសំណល់ពីការទម្លាក់គ្រាប់បែក ...............................៣០

◆ ហ៊ីម ហ៊ុយ ចង់បានយុត្តិធម៌.............................................៣៣

**ផ្នែកច្បាប់**

◆តុលាការនៅទីម័រខាងកើត....................................................៣៦

**វេទិកាពិភាក្សាសាធារណៈ**

◆ ខ្សែគំនិតដើម្បីរកយុត្តិធម៌ពិតប្រាកដមួយ...............................៤១

◆ ទ្រឹស្តីនៃភាពជាអ្នកដឹកនាំៈ សមមិត្ត ប៉ុល ពត ......................៤៦

◆ រឿងក្តី មីឡូសីវិច............................................................៥៣

**ធំព័រស្រាវជ្រាវរកគ្រួសារ**

◆ពៅ ហុង បាត់បង់គ្រួសារ...................................................៥៥

**សិល្បៈខ្មែរក្រហមៈ**

◆រឿងបដិវត្តៈ ពលកម្មម៉ែៗយើង...........................................៥៨

◆ចម្រៀងៈ ជយោ!ថ្ងៃ១៧ មេសា យើងរំដោះភ្នំពេញ........គ្របក្រោយ



យាយស៊ុំ (ភូមិថ្មី ឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ)

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**វាគ្មិនលេខនេះៈ** ដេង ពង្សរ៉ាស៊ី, អៀ ម៉េងទ្រី, វ៉ាន់ថាន់ ពៅដារ៉ា, ហ៊ុយ វណ្ណៈ, ឡុង ដានី, សម សុជាតិ, ស៊ូហ្សាណា លីនតុន, ដេវីដ ឆេនដល័រ, ភីតធ័រ ម៉ាឃ្យៀរ, **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, ជួង សុភារិទ្ធ **ជំនួយការនិពន្ធនាយកៈ** សាន់ កល្យាណ **និពន្ធនាយករងទី១ៈ** ស្វួ ប៊ុនស៊ូ **និពន្ធនាយករងទី២ៈ** សឹម សុរិយ៉ា **អ្នកបកប្រែៈ** អេង កុកថាយ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** សុខ វណ្ណៈ

*សំបុត្រៈ*

# សិទ្ធិមានជីវិត

ខ្ញុំសូមសង្ខេបការងារមួយចំនួនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលធ្វើឡើងដើម្បីការពិត យុត្តិធម៌ និងការបង្រួបបង្រួមនិងផ្សះផ្សាជាតិនៅក្នុងប្រទេសកម្ពុជា ។ ការងារនេះយើងបាននិងកំពុងធ្វើចាប់តាំងពីឆ្នាំ១៩៩៥មកម្ល៉េះ ។ នៅថ្ងៃសៅរ៍ ទី៩ ខែមីនា ឆ្នាំ២០០២ វេលាម៉ោង៤ៈ៣០រសៀល នៅឯសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ខ្ញុំបានរៀបចំបញ្ចាំងខ្សែភាពយន្តឯកសារដែលមានចំណងជើងថា "បុប្ផាណា" ជូនលោកសាស្ត្រាចារ្យ ភីតធ័រ ឡីប្រិច ដែលជាតំណាងពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៅកម្ពុជា ។ ខ្សែភាពយន្តឯកសារនេះរៀបរាប់អំពីគូស្វាមីភរិយាមួយគូដែលត្រូវបានខ្មែរក្រហមធ្វើទារុណកម្ម ហើយយកទៅសម្លាប់ចោល ដោយមូលហេតុថាអ្នកទាំងពីរជាប្តីប្រពន្ធដែលគ្មានការអនុញ្ញាតពីអង្គការ ។ ក្រោយពីបញ្ចាំងខ្សែភាពយន្តចប់ ខ្ញុំក៏សួរទៅបុគ្គលិករបស់លោកសាស្ត្រាចារ្យ ឡីប្រិច ដែលមានប្រមាណជាង២០នាក់ និងដែលសុទ្ធសឹងជាអ្នកសិទ្ធិមនុស្សអន្តរជាតិ ។ ខ្ញុំសួរថា "តើសិទ្ធិមនុស្សអ្វីដែលសំខាន់ជាងគេបំផុត?" ។ ជាធម្មតា ប្រជាជនទូទៅតែងតែនិយាយអំពីសិទ្ធិនិយាយស្តីដោយសេរី សិទ្ធិចូលរួម បង្កើតសមាគម សិទ្ធិប្រមូលផ្តុំគ្នាក្នុងគោលបំណងរកសន្តិភាព និងសិទ្ធិសារពត៌មានដែលជាសិទ្ធិដ៏សំខាន់សម្រាប់ប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យជាដើម ។ ខ្ញុំបានប្រាប់ទៅក្រុមសិទ្ធិមនុស្សនោះដោយចំៗថា សិទ្ធិទាំងអស់នេះគ្មានន័យអ្វីទាំងអស់ ប្រសិនបើយើងបាត់បង់ជីវិតហើយនោះ ។ សិទ្ធិដែលសំខាន់បំផុតគឺសិទ្ធិរស់រានមានជីវិត ។ យើងអាចមានសិទ្ធិផ្សេងៗទៀត លុះត្រាតែសិទ្ធិដែលជាមូលដ្ឋាន (សិទ្ធិមានជីវិត) ត្រូវបានធានាជាមុនសិន ។ សិទ្ធិជាមូលដ្ឋាននេះត្រូវបានរំលោភយ៉ាងធ្ងន់ធ្ងរពីសំណាក់របបកម្ពុជាប្រជាធិបតេយ្យដែលដឹកនាំដោយ ប៉ុល ពត ។ ប្រជាជនកម្ពុជាប្រមាណជាង៣០ភាគរយ ត្រូវបានសម្លាប់ដោយខ្មែរក្រហមក្នុងអំឡុងពេលមិនដល់៤ឆ្នាំផង ។ នៅក្នុងប្រវត្តិសាស្ត្រ គ្មានរដ្ឋាភិបាលណាមួយក្រៅពីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហមដែលដកហូតសិទ្ធិរស់រានមានជីវិតពីប្រជាជនក្នុងកម្រិតខ្ពស់បែបនេះឡើយ ។ ដោយសារហេតុផលនេះ យើងអាចនិយាយបានថារបបខ្មែរក្រហមគឺជារបបដែលបានរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរបំផុតនៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ។

ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ មេដឹកនាំខ្មែរក្រហមនៅតែមានសេរីភាពពេញទីក្នុងរយៈពេល១ភាគ៤នៃសតវត្សរ៍ក្រោយពីបានប្រព្រឹត្តអំពើឃោរឃៅដែលមិនធ្លាប់មានពីមុនមក ។ ភាពរួចទោសដែលចេះតែបន្តរហូតមកដល់សព្វថ្ងៃនេះ ជាសញ្ញាបញ្ឈាក់ប្រាប់ប្រជាជនកម្ពុជាថា សិទ្ធិជាមូលដ្ឋានរបស់មនុស្សគឺគ្មានសារសំខាន់អ្វីទាល់តែសោះ ។ សិទ្ធិជាមូលដ្ឋាននេះត្រូវបានរំលោភបំពានម្តងហើយម្តងទៀត (យ៉ាងហោចណាស់២លានដង) ហើយមកទល់នឹងពេលនេះ នៅតែគ្មានរដ្ឋអំណាចណាមួយអាចផ្តន្ទាទោសអ្នកប្រព្រឹត្តបទល្មើសបានឡើយ ។ នៅមានរឿងច្រើនជាងនេះទៀតដែលត្រូវបកស្រាយ គឺថាអតីតមេដឹកនាំខ្មែរក្រហមជិះរថយន្តតម្លៃខ្ពស់ៗ រស់នៅក្នុងភូមិគ្រឹះស៊ីមស្អែកដោយមានអង្គរក្សនិងអ្នកហែហមបម្រើឆ្វេងស្តាំ ។ និយាយឲ្យខ្លីមកមេដឹកនាំខ្មែរក្រហមជាអ្នកមានសម្បត្តិស្តុកស្តម្ភនិងមានអំណាចបំណែកជនរងគ្រោះវិញរស់នៅក្នុងភាពក្រីក្រ បានព្រឹកខ្វះល្ងាចនិងការនិរាសព្រាត់ប្រាស ។

នៅមជ្ឈមណ្ឌលឯកសារកម្ពុជា យើងបានចំណាយពេល៧ឆ្នាំរួចមកហើយ ធ្វើការផ្លាស់ប្តូរស្ថានភាពដែលមិនអាចទទួលយកបាននេះ ។ យើងបានចងក្រងឯកសារខ្មែរក្រហមយ៉ាងច្រើនសន្ធឹកសន្ធាប់ ទាក់ទងទៅនឹងឧក្រិដ្ឋកម្មនិងប្រវត្តិសាស្ត្រនៅក្នុងរបបខ្មែរក្រហម ។ មកទល់នឹងពេលនេះ យើងបានធ្វើផែនទីស្រាវជ្រាវទៅលើរណ្តៅសាកសពរួមចំនួន ១៩ ៤៤០រណ្តៅ មន្ទីរសន្តិសុខចំនួន១៦៧កន្លែង និងកន្លែងតម្កល់អដ្ឋិធាតុចំនួន៧៧កន្លែង ។ យើងបានប្រមែប្រមូលឯកសារខ្មែរក្រហមចំនួន

ជាង៦សែនទំព័រ ដែលស្ថិតក្នុងដំណើរការបកប្រែ ចុះបញ្ជីធ្វើកាតាឡុកនិងបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យកុំព្យូទ័រជាបណ្តើរៗ ។ យើងថែមទាំងបានប្រមូលឯកសារដែលនិយាយពីកម្មាភិបាលខ្មែរក្រហមចំនួន១៨០០០នាក់ ហើយយើងកំពុងតែស្រាវជ្រាវរកខ្សែសង្វាក់បញ្ជារបស់បក្សកុម្មុយនិស្តកម្ពុជាដែលដឹកនាំដោយប៉ុល ពត ចាប់តាំងពីថ្នាក់លើរួមមាន ប៉ុល ពត រហូតដល់ថ្នាក់ក្រោម ដូចជាគណៈស្រុក ប្រធានឃុំ និងប្រធានភូមិ ។ នៅពេលយើងចាប់ផ្តើមធ្វើការស្រាវជ្រាវដំបូង យើងមិនទាន់ដឹងច្បាស់ថាតើខ្មែរក្រហមអនុវត្តអំពើអគតិដោយរបៀបណាខ្លះនោះទេ ។ ប៉ុន្តែឥឡូវនេះយើងបានដឹងយ៉ាងច្រើនទាក់ទងទៅនឹង “អ្នកណាជាអ្នកប្រព្រឹត្ត ប្រព្រឹត្តអ្វីខ្លះ ប្រព្រឹត្តនៅពេលណា និងនៅកន្លែងណា” ។ យើងរកឃើញថាមានជនរងគ្រោះច្រើនជាងចំនួនដែលអ្នកសិក្សាជាន់ខ្ពស់បានជឿជាក់ពីមុនមក ពោលគឺមានរហូតដល់ជាងពីរលាននាក់ដែលត្រូវបាត់បង់ជីវិត ។ ទោះជាយ៉ាងនេះក្តី ក៏ការងារប្រមូលភស្តុតាងរបស់យើងគ្រាន់តែជាចំណែកតូចមួយនៃផ្ទៃរឿងប្រវត្តិសាស្ត្រទាំងមូលតែប៉ុណ្ណោះ ។

៧ឆ្នាំចុងក្រោយនេះយើងបានជំរុញដំណើរការមួយដែលនឹងធ្វើឲ្យអាជ្ញាធរមានសមត្ថកិច្ចប្រមូលរៀបចំភស្តុតាង និងនាំយកទៅតុលាការដែលសម្រេចតែទៅលើអង្គច្បាប់ប្រឆាំងនឹងចារីនៃបទល្មើស ។ យើងបាននិងកំពុងធ្វើការជាមួយអ្នកជំនាញការច្បាប់នៅក្នុងជួររាជរដ្ឋាភិបាល អង្គការសហប្រជាជាតិ និងប្រទេសនានានៅលើពិភពលោក ជាពិសេសសហរដ្ឋអាមេរិកនិងអឺរ៉ុប ដែលមានការចាប់អារម្មណ៍ក្នុងការរៀបចំនូវគម្រោងបង្កើតជាស្ថាប័នមួយសម្រាប់បម្រើយុត្តិធម៌នៃអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា ។ ទន្ទឹមគ្នានេះដែរ យើងក៏នៅបាននិងកំពុងធ្វើការជាមួយ (ប៉ុន្តែជួនកាលប្រឆាំង) អាជ្ញាធរនយោបាយមកពីជុំវិញពិភពលោក ដើម្បីឲ្យអ្នកទាំងនោះធ្វើអ្វីដែលត្រឹមត្រូវនិងធ្វើសេចក្តីសម្រេចចិត្តជាដុំកំភួនសម្រាប់វាយសំពងទៅលើវប្បធម៌នៃការរួចទោសនៅក្នុងប្រទេសកម្ពុជា ។ ទោះបីជាយើងបានធ្វើដំណើរក្នុងគន្លងផ្លូវដ៏វែង ហើយបានសម្រេចបានសមិទ្ធផលដ៏ច្រើនក៏ដោយ ក៏យើងមិនទាន់បានឈានទៅដល់គោលដៅរបស់យើងនៅឡើយទេ ។ យើងមិនទាន់មានលទ្ធភាពជំរុញរាជរដ្ឋាភិបាលកម្ពុជានិងសហគមន៍អន្តរជាតិថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគួរតែត្រូវបានកាត់សេចក្តីក្នុងលក្ខណៈដែលអាចទទួលយកបាន ពោលគឺក្នុងលក្ខណៈមួយដែលជួយឲ្យកម្ពុជាព្យាបាលរបួសរបស់ខ្លួន និងលែងវិលវល់នឹងអតីតកាលរបស់ខ្លួនតទៅទៀត ដើម្បីធ្វើដំណើរឆ្ពោះទៅមុខ ។

គោលដៅឈានទៅរកយុត្តិធម៌នៃអំពើប្រល័យពូជសាសន៍នៅកម្ពុជាអាចឬមិនអាចសម្រេច ។ ទន្ទឹមនឹងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលដៅទីពីរដែលមិនមានកម្រិតទាបជាងការលើកស្ទួយយុត្តិធម៌ឡើយ ។ គោលដៅនោះគឺធានាឲ្យមានការចងចាំ ។ ការចងចាំក៏ដូចជាយុត្តិធម៌ដែរ គឺជាមូលដ្ឋានគ្រឹះសម្រាប់បង្កើតនីតិរដ្ឋនិងការផ្សះផ្សានិងបង្រួបបង្រួមជាតិនៅកម្ពុជា ។ ក្រៅពីកិច្ចខិតខំប្រឹងប្រែងរបស់យើងក្នុងការយកអង្គហេតុពិតនៃអំពើប្រល័យពូជសាសន៍មកចងក្រងជាឯកសារដែលជាវិធីមួយសម្រាប់លើកកម្ពស់ការចងចាំ នៅមានវិធីមួយទៀតគឺតាមរយៈទស្សនាវដ្តី“ស្វែងរកការពិត” ។ មកទល់នឹងពេលនេះទស្សនាវដ្តីស្វែងរកការពិតកំពុងតែបន្តដំណើរការផ្សព្វផ្សាយនៅក្នុងឆ្នាំទីបីរបស់ខ្លួន ។ ទំព័រទស្សនាវដ្តីស្វែងរកការពិតបានពាំនាំយកនូវរបកគំហើញឃើញថ្មីៗ តាមរយៈការសិក្សាស្រាវជ្រាវនិងចងក្រងឯកសារផ្សព្វផ្សាយទៅដល់អ្នកស្រុក អ្នកភូមិ ទូទាំងប្រទេសនិងក្រៅប្រទេស ។ យើងបានចែកចាយទស្សនាវដ្តីដោយឥតគិតថ្លៃនៅតាមស្រុក ឃុំ ភូមិ រៀងរាល់ខែ ។ ទោះបីជាកិច្ចខិតខំប្រឹងប្រែងបែបនេះរួមជាមួយគម្រោងការងារផ្សេងៗទៀតរបស់យើងមានបំណងរក្សាការចងចាំសំខាន់យ៉ាងនេះក៏ដោយ ក៏នៅមិនទាន់គ្រប់គ្រាន់នៅឡើយដែរ ។ ដើម្បីឲ្យប្រជាជនកម្ពុជាចងជាប់ដោយអតីតកាលតទៅទៀត យើងត្រូវការជាចាំបាច់នូវយុត្តិធម៌ ។

អង្គការសហប្រជាជាតិបានខិតខំព្យាយាមនាំយកនូវយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា ដោយចំណាយពេលរហូតដល់ជាងបួនឆ្នាំ ក្នុងការចរចាជាមួយរាជរដ្ឋាភិបាលកម្ពុជាលើបញ្ហាបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ នៅដើមឆ្នាំ១៩៩៩ អ្នកជំនាញការអង្គការសហប្រជាជាតិបានស្នើឲ្យបង្កើតនូវតុលាការអន្តរជាតិពិសេសមួយ សម្រាប់កាត់ទោសមេដឹកនាំខ្មែរ

ក្រហម ដោយយកគំរូតាមតុលាការព្រហ្មទណ្ឌអន្តរជាតិបង្កើតឡើងសម្រាប់ប្រទេសយូហ្គោស្លាវី ។ រាជរដ្ឋាភិបាលកម្ពុជាបានបដិសេធយ៉ាងដាច់អហង្កានូវសំណើនេះ ដោយសំអាងថានេះជាការរំលោភទៅលើអធិបតេយ្យភាពរបស់កម្ពុជា ។ ពេលនោះអង្គការសហប្រជាជាតិនិងកម្ពុជាបានព្យាយាមយល់ស្របទៅនឹងគំរូយុត្តិធម៌ថ្មីដែលមិនទាន់មានពីមុនមកនេះ ។ គំរូថ្មីនេះគឺតុលាការ "ចម្រុះ" បង្កើតឡើងដោយគិតគូរពីការព្រួយបារម្ភអំពីអធិប-តេយ្យភាពដែលលើកឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ។

ប៉ុន្តែនៅថ្ងៃទី៨ ខែកុម្ភៈ ក្នុងឆ្នាំ២០០២នេះ អង្គការសហប្រជាជាតិបានប្រកាសថា ខ្លួនឈប់បន្តការចរចាជាមួយកម្ពុជាទៀតហើយ ។ អង្គការសហប្រជាជាតិលើកហេតុផលថាច្បាប់ដែលអនុម័តដោយកម្ពុជានៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ មិនអាចធានាបាននូវយុត្តិធម៌កម្រិតអន្តរជាតិដែលចេញពីតុលាការប្រភេទនេះទេ ។ ទោះបីជាទទួលសម្ពាធពីសហគមន៍អន្តរជាតិយ៉ាងណាក៏ដោយ ក៏លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ នៅតែរក្សាជំហរយ៉ាងមាំដដែល ។ រហូតមកដល់ថ្ងៃទី១៣ ខែមីនា លោកអគ្គលេខាបានប្រកាសថា ប្រសិនបើខាងសហគមន៍អន្តរជាតិចង់ឃើញការផ្លាស់ប្តូរចេញពីសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ចាំបាច់ត្រូវតែបញ្ចុះបញ្ចូលធ្វើយ៉ាងណាឲ្យសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ផ្លាស់ប្តូរជំហរនិងឥរិយាបថជាមុនសិន ។

ចំណែកខាងរាជរដ្ឋាភិបាលកម្ពុជាវិញនិយាយថា ខ្លួនមានការភ្ញាក់ផ្អើលចំពោះសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ដោយបញ្ជាក់ថា បញ្ហាគ្រប់យ៉ាងនៅក្នុងច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវបានយល់ស្របជាមួយអង្គការសហប្រជាជាតិរួចរាល់អស់ហើយ ។ ជំហរនេះ អង្គការសហប្រជាជាតិមិនចូលរួមជាមួយទេ ។ នៅថ្ងៃទី១៥ ខែមីនា ឯកឧត្តម សុខ អាន ប្រធានក្រុមការងារសម្រាប់សហប្រតិបត្តិការជាមួយអ្នកជំនាញការច្បាប់បរទេសនិងការរៀបចំដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម បានសម្តែងនូវ "សេចក្តីសង្ឃឹមអស់ពីចិត្ត" សាជាថ្មីទៀតថា នឹងរិះរកផ្លូវដើម្បីទម្លាយភាពទាល់ច្រកបច្ចុប្បន្ននេះ ។ ឯកឧត្តមមានប្រសាសន៍ថា រាជរដ្ឋាភិបាលជឿជាក់ថា "មានមូលដ្ឋានច្បាស់លាស់មួយៗសម្រាប់ឲ្យមានមូលដ្ឋានចរចាសាជាថ្មី" ។ ប៉ុន្តែឯកឧត្តមមិនបានបង្ហាញច្បាស់ថា រាជរដ្ឋាភិបាលកម្ពុជារៀបចំខ្លួនក្នុងការផ្លាស់ប្តូរជំហរនិងធ្វើវិសោធនកម្មច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមតាមការជំទាស់របស់អង្គការសហប្រជាជាតិនៅឡើយទេ ។

អង្គការសហប្រជាជាតិតែងតែនិយាយអំពីយុត្តិធម៌ ពោលគឺការសម្រេចបាននូវយុត្តិធម៌មួយដែលមានកម្រិតអន្តរជាតិនៅក្នុងប្រទេសកម្ពុជា ។ ការគិតដូច្នេះគឺជាការត្រឹមត្រូវណាស់ ។

រដ្ឋាភិបាលកម្ពុជាតែងតែនិយាយអំពីការបង្រួបបង្រួមនិងផ្សះផ្សាជាតិ ដែលជាការចាំបាច់សម្រាប់ថែរក្សាសន្តិភាព និងផ្សះរបួសសង្គមកម្ពុជាដែលទទួលរងនូវសង្គ្រាមយាយី ។ ការគិតរបស់រដ្ឋាភិបាលកម្ពុជា ក៏ជាការត្រឹមត្រូវបំផុតដែរ ។

ប៉ុន្តែខ្ញុំយល់ថាគ្មានអ្នកណាម្នាក់និយាយឲ្យបានច្បាស់លាស់អំពីការពិតឡើយ ។ ការពិតគឺថា យុត្តិធម៌និងការបង្រួបបង្រួមនិងផ្សះផ្សាជាតិមិនអាចកាត់ផ្តាច់ចេញពីគ្នាបាន ។ យើងមិនអាចមានមួយហើយខ្វះមួយបានទេ ។ ជនរងគ្រោះបានជឿជាក់លើអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាជ្រុលពេក ដោយជឿជាក់ថា ភាគីទាំងពីរនឹងនាំមកនូវយុត្តិធម៌និងការបង្រួបបង្រួមជាតិ ។ សព្វថ្ងៃនេះ ប្រជាជនកម្ពុជាកំពុងតែក្លាយជាចំណាប់ខ្មាំងនៅក្នុងបញ្ហានេះ ។ អង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាកំពុងតែបដិសេធចោលនូវការទទួលខុសត្រូវចំពោះយើងខ្ញុំទាំងអស់គ្នាដែលជាជនរងគ្រោះនិងជនដៃដល់ ។ អង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា ធ្វើឲ្យយើងទាំងអស់គ្នា និងយុត្តិធម៌ព្រមទាំងការពិតទទួលបរាជ័យ ។ ភាពរួចទោសរបស់មេដឹកនាំខ្មែរក្រហមនៅតែបន្តលងប្រជាជនកម្ពុជាជារៀងរាល់ថ្ងៃ ។ គ្រួសារនីមួយៗសុទ្ធតែបាត់បង់នូវរបស់មានតម្លៃដែលមិនអាចរកអ្វីមកជំនួសបាន ។ ជាក់ស្តែងគឺរឿងរបស់ក្រុមគ្រួសារខ្ញុំផ្ទាល់ ។ នៅក្នុងរបបខ្មែរក្រហម បងថ្លៃរបស់ខ្ញុំតែងតែហូបអាហារដ៏តិចតួចបំផុតដើម្បីសន្សំវេចខ្ចប់ទុកឲ្យកូនតូចៗទាំងបីរបស់គាត់ ។ មានថ្ងៃមួយគាត់ត្រូវបានឈ្លបខ្មែរក្រហមចាប់ចងនៅពេលកំពុងតែលួចកាកសំណល់ពីផ្ទះបាយរួមសម្រាប់បន្ថែមទៅលើរបបកំណត់ចិញ្ចឹមគ្រួសារ ។

**(តទៅទំព័រ៦០)**

# ឈិម សុជិត និស្សិតមកពីកាណាដា

ឈិម សុជិត ជាបញ្ញវន្តខ្មែរមួយរូប កើតនៅក្នុងគ្រួសារកសិករក្រីក្រមួយក្នុងខេត្តបាត់ដំបង ដែលមានវាសនាបានបន្តការសិក្សានៅបរទេស ។ នារយៈពេលចុងក្រោយនៃរបបសាធារណរដ្ឋខ្មែរ ឈិម សុជិត បានទៅរស់នៅប្រទេសកាណាដាក្នុងនាមជាជនភៀសខ្លួន។ ពេលត្រឡប់ចូលមាតុប្រទេសវិញក៏ត្រូវអង្គការចាប់ខ្លួន នៅថ្ងៃ១២-១០-៧៦ បញ្ជូនមកមន្ទីរស-២១ (គុកទួលស្លែង) តែម្តង។ នៅទួលស្លែង ឈិម សុជិត ត្រូវបានសួរចម្លើយដោយឈ្មោះ ប្រាក់ បូ ។ បន្ទាប់ពីសួរចម្លើយអស់ជាច្រើនលើកច្រើនសា ឈិម សុជិត ត្រូវអង្គការយកទៅកម្ទេចនៅថ្ងៃទី២៨-១-១៩៧៧ ។

## ប្រវត្តិរូបសង្ខេប

សុជិត មានអាយុ៣២ឆ្នាំ(១៩៧៧) ស្រុកកំណើតនៅឃុំស្វាយពៅ ស្រុកសង្កែ ខេត្តបាត់ដំបង ។

ឪពុកឈ្មោះ ឈិម ជា ។ ម្តាយឈ្មោះ សំរិទ្ធ ហួន(ស្លាប់) ។ ម្តាយចុងឈ្មោះ ឱប សន មុខរបរធ្វើស្រែនៅខេត្តបាត់ដំបង ។

ឈិម សុជិត មានបងប្អូន៤នាក់គឺ ÷

១) ឈិម សុមិត្រ ភេទប្រុស សិស្សវិទ្យាល័យបាត់ដំបង ។

២) ឈិម សុមិត្រា ភេទស្រី សិស្សវិទ្យាល័យបាត់ដំបង ។

៣) ឈិម សុមនោ ភេទប្រុស សិស្សបឋមសិក្សា ។

៤) ឈិម សុមនី ភេទស្រី សិស្សបឋមសិក្សា ។

ឆ្នាំ១៩៦៧ ឈិម សុជិត បានបញ្ចប់ការសិក្សានៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រក្រុងភ្នំពេញ ។

ខែវិច្ឆិកា ឆ្នាំ១៩៦៧ បានទទួលអាហារូបករណ៍ទៅសិក្សានៅប្រទេសបែលហ្សិក ប៉ុន្តែត្រូវត្រឡប់មកកម្ពុជាវិញដោយសារមានជំងឺមិនអាចរៀនកើត ។

នៅខែមករា ឆ្នាំ១៩៦៩ ឈិម សុជិត មកធ្វើការនៅអគ្គិសនីកម្ពុជាក្រុងភ្នំពេញ ។

ខែកញ្ញា ឆ្នាំ១៩៦៩ បានឡើងធ្វើជាមេក្រុមខាងបញ្ជីគណនេយ្យចេញចូលទូទៅ ។

## ប្រវត្តិនយោបាយ

### ក) នៅប្រទេសកម្ពុជា

នៅខែ១២-១៩៦៩ ឈិម សុជិត ត្រូវបានមិត្តម្នាក់ឈ្មោះ ប៊ុន យឹន ណែនាំឲ្យស្គាល់មនុស្សម្នាក់ទៀតឈ្មោះ សារ៉ាយ ប៊ុនគី (ភ្នាក់ងារ)ជាទាហានស័ក្តិ៤ ក្រសួងការបរទេស ។ ដោយប្រឈមមុខនឹងជីវភាពក្នុងការរកប្រាក់សម្រាប់ផ្គត់ផ្គង់គ្រួសារនៅឯស្រែ នៅខែកុម្ភៈ ឆ្នាំ១៩៧០ ឈិម សុជិត បានស្ម័គ្រចិត្តចូលជាសេ.អ៊ី.អា តាមរយៈ សារ៉ាយ ប៊ុនគី ក្នុងខ្សែរបស់ឈ្មោះ ពីទែរ ចំសុន និងឈ្មោះ អង់ដ្រេ ម៉ុតតេ (ភ្នាក់ងារសេ.អ៊ី.អាប្រទេសបារាំង) ។ ឈិម សុជិត បានទទួលប្រាក់ខែ១៨០ដុល្លារក្នុងមួយខែ ក្នុងតួនាទីជាអ្នកបំផុសសិស្ស-និស្សិតនៅតាមមហាវិទ្យាល័យឲ្យមានកំហឹងពុះកញ្ជ្រោលឡើងប្រឆាំងនឹងរបបរាជានិយម សីហនុ ហើយងាកមកគាំទ្ររបប លន់ ណុល (របបសាធារណរដ្ឋខ្មែរ) វិញ ។

ឈិម សុជិត បានទៅទាក់ទងនិស្សិតម្នាក់ឈ្មោះ កុយ ប៊ិច រៀននៅមហាវិទ្យាល័យច្បាប់ឲ្យជួយបំផុសចលនានេះឡើង ។ ក្រោយមកបានទាក់ទងសិស្សមួយចំនួនទៀតឈ្មោះ ប៉ែន គាន, សន ថាត, ឃិម គិចសែ និង កែម សុន្ទរោ ឲ្យជួយបំផុសចលនាបន្តគ្នាទៅទៀត ។

ខែតុលា ឆ្នាំ១៩៧០ សារ៉ាយ ប៊ុនគី បានចាត់តាំងឲ្យ ឈិម សុជិត មកទាក់ទងសិស្សនិងនិស្សិតបន្ថែម ដើម្បីនិយាយបំផុសឲ្យឃើញថាសម្តេច សីហនុ បានទៅប្រទេសចិនប្រជាមានិតដើម្បីបានពឹងពាក់កម្លាំងទ័ពរបស់យួនវៀតកុងដណ្តើមអំណាចមកវិញ ហើយសម្តេចបានយកព្រះនាមរបស់ទ្រង់ទៅបិទបាំងមិនឲ្យមតិអន្តរជាតិដឹងថា សម្តេច សីហនុ ពឹងទ័ពវៀតកុងមកច្បាំងជាមួយពួក លន់ ណុល ។ នៅខែក្នុងដដែលនេះ ឈិម សុជិត បានមកជួបសិស្សនិងនិស្សិតដែលខ្លួនធ្លាប់បានទាក់ទងពីខាងលើដែលកំពុងតែជឿស៊ប់ថា សម្តេច សីហនុ បានក្បត់មែន។ ឈិម សុជិត បានបន្តការទាក់ទងជាមួយនិស្សិតទាំង៥នាក់នេះកាន់តែជិតស្និទ្ធ ដើម្បីបញ្ចុះបញ្ចូលអ្នកទាំងប្រាំនាក់ឲ្យជួយបន្តការផ្សព្វផ្សាយអំពីគម្រោងការរបស់ខ្លួន ។

ខែមករា ឆ្នាំ១៩៧១ ឈិម សុជិត ទាក់ទងជាមួយនិស្សិត

៣នាក់ឈ្មោះ ប៉ុង លីស្វង នៅមហាវិទ្យាល័យពេទ្យ, គឹម ស្រ៊ាង នៅមហាវិទ្យាល័យគរុកោសល្យ និងឈ្មោះ ឈិម ណាត ។ ឈិម សុជិត ខិតខំពន្យល់ឲ្យអ្នកទាំងបីឲ្យជឿថា កងទ័ពបដិវត្តកម្ពុជាស្ថិតនៅក្រោមការត្រួតត្រារបស់ពួកវៀតកុង វៀតមិញ និងបង្ហាញថាពួកយួនកុម្មុយនិស្តបានប្រើឲ្យពួកវៀតមិញវាយប្រទេសកម្ពុជា ដើម្បីយកប្រទេសកម្ពុជាធ្វើជារណបរបស់ខ្លួន ។

នៅក្នុងខែមេសា ឆ្នាំ១៩៧១ ជាខែបុណ្យចូលឆ្នាំខ្មែរ ។ ឈិម សុជិត បានទៅលេងស្រុកកំណើតដើម្បីជួបជុំញាតិមិត្តបងប្អូននៅខេត្តបាត់ដំបង ។ តាមដំណើរចេញពីភ្នំពេញទៅបាត់ដំបង ឈិម សុជិត បានជួបសន្ទនាជាមួយគ្រូបង្រៀនម្នាក់ឈ្មោះ គង់ រេត អំពីរឿងសង្គ្រាមនៅក្នុងប្រទេសកម្ពុជាថា កងទ័ពបដិវត្តកម្មាភិបាលជាន់ខ្ពស់ទាំងអស់សុទ្ធជាពួកវៀតមិញនិងវៀតកុង គ្មានកងទ័ពបដិវត្តពិតប្រាកដនៅកម្ពុជាទេ ។ គ្រូបង្រៀននោះបានគាំទ្រគំនិតរបស់ ឈិម សុជិត ព្រោះថាគាត់ស្អប់ខ្មែរក្រហម ។ ខ្មែរក្រហមតែងតែមកអុកឡុកអ្នកស្រុករបស់គាត់ឲ្យជួយជាអង្ករ ត្រីសាច់ និងប្រាក់កាស ព្រមទាំងចាប់បង្ខំអ្នកស្រុកខ្លះឲ្យទៅជាមួយខ្លួនទៀត ។ ដោយឃើញថា គង់ រេត មិនពេញចិត្តខ្មែរក្រហម ឈិម សុជិត ក៏បានបញ្ចុះបញ្ចូលសុំឲ្យជួយពន្យល់អ្នកភូមិងើបឡើងប្រឆាំងនឹងខ្មែរក្រហម ។

ខែកញ្ញា ឆ្នាំ១៩៧១ ឈិម សុជិត ឈប់ធ្វើការនៅក្នុងអគ្គិសនីកម្ពុជា ហើយបានសុំចូលធ្វើការនៅធនាគារឥណទានជាតិវិញ ។ ក្នុងធនាគារនេះ ឈិម សុជិត ទទួលខុសត្រូវខាងសំបុត្រឯកសារដឹកទំនិញចេញចូលក្រៅប្រទេស ។ មួយខែបន្ទាប់ ឈិម សុជិត បានសុំលោក កែវ ម៉ុងគ្រី ចាងហ្វាងនៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ដើម្បីបង្រៀនមុខវិជ្ជាបញ្ជីគណនេយ្យដល់សិស្សនៅក្នុងមហាវិទ្យាល័យនោះ ។ នៅពេលបង្រៀនម្តងៗ ឈិម សុជិត តែងតែឆ្លៀតឱកាសនិយាយប្រាប់សិស្សអំពីបដិវត្តខ្មែរក្រហម ដើម្បីឲ្យសិស្សស្អប់និងផ្តន្ទាពួកខ្មែរបដិវត្ត ។

ខែវិច្ឆិកា ឆ្នាំ១៩៧១ សភាពការណ៍នយោបាយនៅក្នុងប្រទេសមានការប្រែប្រួល ។ អ្នកកសាងសាធារណរដ្ឋខ្មែរបានបែកខ្ញែកគ្នាទីទៃរៀងៗខ្លួន ធ្វើឲ្យជំហរនយោបាយក្នុងប្រទេសកាន់តែចុះខ្សោយ ហើយសិស្សនិស្សិតដែលផុសផុលនឹងរបបសាធារណរដ្ឋនិយមពីមុនមក ក៏បានប្រែឥរិយាបថនៅស្ងៀមចាំសង្កេតមើលព្រឹត្តិការណ៍វិញដែរ ។

ខែមីនា ឆ្នាំ១៩៧២ ឈិម សុជិត បានជួប កុយ ប៊ុច, យិម គិចសែ និង ប៉ុង លីស្វង ដើម្បីស្វែងយល់ពីគោលជំហររបស់និស្សិតនៅតាមមហាវិទ្យាល័យ ។ អ្នកទាំងបីបានប្រាប់ឲ្យដឹងថា និស្សិតភាគច្រើននៅតែមិនចូលចិត្តទ័ពបដិវត្តខ្មែរក្រហម ហើយគេមានចិត្តស្រឡាញ់របបសាធារណរដ្ឋដដែល ប៉ុន្តែមិនសប្បាយចិត្តជាមួយអ្នកដឹកនាំរបបសាធារណរដ្ឋដែលមិនអនុវត្តតាមគោលការណ៍របបសាធារណរដ្ឋនិយម ។ ក្រោយពីបានដឹងថានិស្សិតភាគច្រើននៅតែមានការគាំទ្ររបបសាធារណរដ្ឋនៅក្នុងខែ៥ ឈិម សុជិត ក៏បានបន្តការទាក់ទងជាមួយនិស្សិត ២នាក់ទៀត និយាយបំផុសកំហឹងធ្វើឲ្យនិស្សិតទាំងពីរមានចិត្តក្តៅក្រហាយឆ្អាលយកទៅផ្សព្វផ្សាយបន្ត ។ ខែ៨-១៩៧២ ឈិម សុជិត បានទទួលដំណឹងពី សារ៉ាយ ប៊ុនគី ថា ខ្មែរក្រហមនៅក្រៅប្រទេសកំពុងតែធ្វើសង្គ្រាមនយោបាយជាមួយរបបសាធារណរដ្ឋយ៉ាងស៊ិតស្វាញ ហើយមានប្រទេសជាច្រើនបានទទួលស្គាល់និងគាំទ្រអង្គការបដិវត្តន៍ខ្មែរក្រហម ។ មិនតែប៉ុណ្ណោះ ពួកខ្មែរក្រហមកំពុងបន្តសង្គ្រាមនយោបាយនៅលើឆាកអន្តរជាតិទៀត ។ ដើម្បីទប់ទល់នឹងការរីកពាលដាលរបស់ពួកខ្មែរក្រហមនៅលើឆាកអន្តរជាតិនោះ សារ៉ាយ ប៊ុនគី ក៏បានចាត់តាំង ឈិម សុជិត, អ៊ិត សារ៉េត (ក្រសួងឃោសនាការ) និង ឡេវស៊ិត សោភ័នថា (អគ្គិសនីកម្ពុជា) ចូលជាសមាជិកក្នុងគណៈប្រតិភូដើម្បីធ្វើដំណើរទៅប្រទេសអាហ្សង់ទីន ប្រទេសអ៊ូរូហ្គាយ ប្រទេសប៉ារ៉ាហ្គាយ និងប្រទេសប្រេស៊ីល ។ គណៈប្រតិភូនេះបានឲ្យឈ្មោះថាជាគណៈប្រតិភូសុឆន្ទៈ ។ គណៈប្រតិភូរបស់ ឈិម សុជិត បានធ្វើដំណើរឆ្ពោះទៅប្រទេសទាំងបួនក្នុងគោលបំណងដើម្បីស្វែងរកការគាំទ្រពីរដ្ឋាភិបាលរបស់ប្រទេសទាំងនោះ ។ ក្រោយពីបានស្រាយបំភ្លឺប្រាប់អំពីសភាពការណ៍នយោបាយនៅប្រទេសកម្ពុជាហើយ តំណាងរដ្ឋាភិបាលរបស់ប្រទេសនីមួយៗក៏បានសន្យាជាមួយក្រុមគណៈប្រតិភូថា នឹងជួយគាំទ្រខាងសាធារណរដ្ឋខ្មែរប្រឆាំងនឹងកុម្មុយនិស្ត ។

ថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៧២ ឈិម សុជិត បានធ្វើ

ដំណើរឆ្ពោះទៅប្រទេសកូរ៉េខាងត្បូង ដើម្បីសិក្សានូវមុខវិជ្ជាធ្វើពាណិជ្ជកម្មអន្តរជាតិរបស់ក្រសួងអប់រំជាតិដែលបានយល់ព្រមឲ្យតាមការដាក់ពាក្យសុំ ។ ឈិម សុជិត បានចូលរួមក្នុងពិធីជប់លៀងមួយជាមួយមិត្តរួមថ្នាក់ ។ ឈិម សុជិត បានរៀបរាប់ប្រាប់ពីសង្គ្រាមកំពុងឆេះឡើងនៅកម្ពុជា តាមការស្នើសុំរបស់មិត្តរួមថ្នាក់ថា "បដិវត្តខ្មែរក្រហមគេថាច្បាំងដើម្បីរំដោះកម្ពុជាពីចក្រពត្តិ ។ ការពិតនៅក្នុងប្រទេសកម្ពុជាពុំមានចក្រពត្តិឯណាទេ សង្គ្រាមនេះ(កម្ពុជា) មិនខុសពីពួកកូរ៉េខាងជើងទេ ។..." មិត្តរួមថ្នាក់របស់ ឈិម សុជិត ភាគច្រើនសុទ្ធតែគាំទ្រខាងសាធារណរដ្ឋខ្មែរ ពីព្រោះប្រទេសកូរ៉េខាងត្បូង ក៏ធ្លាប់បានទទួលនូវសេចក្តីទុក្ខវេទនាម្តងរួចមកហើយ គឺនៅពេលពួកកូរ៉េកុម្មុយនិស្តខាងជើងចូលមកបង្កសង្គ្រាមជាមួយប្រទេសនេះនៅក្នុងអំឡុងឆ្នាំ១៩៥០ ដល់ឆ្នាំ១៩៥៣ ។

ខែមីនា ឆ្នាំ១៩៧៥ ឈិម សុជិត ត្រូវត្រឡប់មកមាតុប្រទេសវិញ ប៉ុន្តែអាក្រក់ព្រលានយន្តហោះពោធិចិនតុងត្រូវខ្មែរក្រហមផ្លោងដាក់ដោយគ្រាប់បែក ទីក្រុងភ្នំពេញទាំងមូលត្រូវបានឡោមព័ទ្ធដោយកងទ័ពបដិវត្ត ។ ដោយមិនអាចវិលមកកាន់មាតុប្រទេសវិញបាន ឈិម សុជិត ក៏បានដាក់ពាក្យសុំសិទ្ធិជ្រកកោនប្រទេសកាណាដាក្នុងនាមជាជនភៀសខ្លួន ។

**១) នៅប្រទេសកាណាដា**

នៅប្រទេសកាណាដា ឈិម សុជិត បានជាលេខាធិការខាងបញ្ជីគណនេយ្យនៅក្រុមហ៊ុនលក់សម្លៀកបំពាក់នារីមួយ ។ រហូតដល់ខែ១២-១៩៧៥ ឈិម សុជិត បានជួបស្គាល់ ជួន វិសិដ្ឋ មេក្រុមនៅកាណាដា (ទីប្រឹក្សាសេ.អ៊ី.អារបស់ ជួន វិសិដ្ឋ ឈ្មោះ វិល្លិយ៉ាំ ស្នែខែរ នៅប្រទេសអាមេរិក) ។ តាមរយៈ ជួន វិសិដ្ឋ នេះ ឈិម សុជិត បានស្ម័គ្រចិត្តចូលធ្វើការជាមួយចលនាសេរីកាជាតិខ្មែរ ក្នុងគោលបំណងរំដោះកម្ពុជាមកវិញ ។ នៅថ្ងៃទី១-១-១៩៧៦ ឈិម សុជិត បានបន្តការងារជាមួយ ជុំទី (អ្នកយកពត៌មានយោធានៅកាណាដា) និង គុយ រុង (នៅក្នុងក្រុមរបស់ ជួន វិសិដ្ឋ និងជាអ្នកឃោសនាប្រមូលខ្មែរនៅកាណាដា) ។ ឈិម សុជិត មានភារកិច្ចទាក់ទងនិងប្រមូលប្រជាជនជម្លៀស ។

ឈិម សុជិត បានទៅជួបទាក់ទងជាមួយខ្មែរភៀសខ្លួនជាច្រើននាក់ដែលរស់នៅក្រៅប្រទេស ព្រមទាំងបាននិយាយបញ្ចុះបញ្ចូលអ្នកទាំងនោះឲ្យមានកំហឹងចូលក្នុងចលនាជាតិខ្មែរប្រឆាំងនឹងបដិវត្តកម្ពុជា ដោយលើកយកហេតុផលនៃការព្រាត់ប្រាសឪពុកម្តាយបងប្អូនមកបង្ហាញថាៈ ដោយសារតែពួកខ្មែរបដិវត្តវាយយកក្រុងភ្នំពេញ ពួកខ្មែរបដិវត្តបានដេញប្រជាជនឲ្យចេញពីក្រុងឲ្យទៅនៅតាមជនបទ រស់នៅលំបាកវេទនា អត់បាយក្រហាយទឹក គ្មានទីជម្រកក្នុងពេលរដូវកំពុងក្តៅ ធ្វើឲ្យប្រជាជនខ្មែររងទុក្ខវេទនាស្លាប់ជាបន្តបន្ទាប់ ។ ប្រជាជនខ្មែររស់នៅដូចជាសត្វធាតុ អង្គការចង់ចាប់អ្នកណាសម្លាប់ចោលក៏បាន គ្មានតុលាការរកខុសត្រូវទេ ហើយអង្គការចាត់ទុកមនុស្សចាស់ៗរស់នៅបំបង់តែបាយ ធ្វើការលែងកើតទៀតហើយ បើស្លាប់ក៏គ្មានខាតអ្វីដែរ ។ ចំណែកប្រជាជនជម្លៀស អង្គការចិញ្ចឹមទុកគ្រាន់ជាឧបករណ៍បង្កបង្កើនផលប៉ុណ្ណោះ ។ កាលណាគេមិនពេញចិត្តបុសង្ស័យនរណាម្នាក់ គេលើកយករឿងអតីតកាលមកលាតត្រដាងចោទប្រកាន់ថាប្រឆាំងនឹងអង្គការបដិវត្តន៍ ឬចោទថាជាភ្នាក់ងារសម្ងាត់របស់ចក្រពត្តិ បន្ទាប់មកចាប់បញ្ជូនទៅអង្គការលើរហូតដល់បាត់ខ្លួន ។ ម្យ៉ាងទៀត ផលិតផលស្រូវជាច្រើនពាន់តោនដែលផលិតបានដោយប្រជាជន អង្គការបែរជាយកទៅជួយប្រទេសចិនប្រជាមានិតនិងប្រទេសលាវ អង្គការសុខចិត្តឲ្យប្រជាជនអត់ឃ្លាន ។ ដូច្នេះ ប្រជាជនខ្មែរមិនមែនជាម្ចាស់លើវាសនាខ្លួនដូចអង្គការថានោះទេ គឺអង្គការបដិវត្តន៍ជាម្ចាស់លើជីវិតរបស់ប្រជាជនខ្មែរ ។ ឈិម សុជិត ក៏បានលើកយកហេតុផលនេះបញ្ចុះបញ្ចូល អ៊ាប ប៊ុនឡុង ឲ្យចូលចលនាសេរីកាជាតិខ្មែរ ។

នៅក្នុងខែឧសភា-មិថុនានេះ ឈិម សុជិត បានចូលរួមប្រជុំតាមការអញ្ជើញរបស់ ជួន វិសិដ្ឋ ចំនួនពីរដង ។ ការប្រជុំនេះគឺដើម្បីប្រាប់អំពីផែនការវាយរំដោះកម្ពុជាតាមផ្លូវនយោបាយដែលបានរៀបចំធ្វើចប់សព្វគ្រប់ហើយ ។

ខែសីហា ឆ្នាំ១៩៧៦ ឈិម សុជិត ត្រូវចូលមកប្រទេសកម្ពុជាតាមការចាត់តាំងរបស់ ជួន វិសិដ្ឋ ។ ឈិម សុជិត បានទទួលភារកិច្ចពី ជួន វិសិដ្ឋ ដើរទាក់ទងប្រមូលប្រជាជនជម្លៀសនិងផែនការមួយចំនួនដែលត្រូវយកអនុវត្តនៅក្នុងប្រទេសកម្ពុជា ។ ផែនការនោះគឺ ១) ពេលចូលមកដល់កម្ពុជា ត្រូវទាក់ទងជាមួយ

បក្ខពួកដែលមានគ្នា៨នាក់ ដូចជាឈ្មោះ សារ៉ាយ ប៊ុនគី សក្តិ៤ ក្រសួងការពារជាតិ, ប៊ុន យ៉ឹន ស័ក្តិ១ក្រសួងការពារជាតិ, ស៊ិន វ៉ុង អ្នកលក់ទំនិញ, ឡេវ ស៊ុតសោភ័នថា ខាងអគ្គីសនីកម្ពុជា, អ៊ិត សារ៉េត ឃោសនាការ, នង ផល្លី, ញ៉ែម ដោវឿង វិទ្យាល័យឯកជនតាភារស្មី និង ហោរ អាន ជាមុន ដើម្បីជាបង្អែកក្នុងការទាក់ទងនៅពេលក្រោយ ។ ២) ក្រោយពីទាក់ទងពួកនោះហើយត្រូវឲ្យឈ្មោះ សារ៉ាយ ប៊ុនគី ធ្វើជាមេក្រុមដើម្បីចាត់តាំងប្រគល់មុខសញ្ញាឲ្យអ្នក៨នាក់ទៅបញ្ចុះបញ្ចូលប្រមូលប្រជាជនជម្លៀស ។ ៣) ក្នុងពេលជាមួយគ្នានោះ គឺត្រូវទាក់ទងជាមួយមនុស្សក្នុងជួរបដិវត្ត១២នាក់ទៀតជាបង្អែក ។ តាមមុខសញ្ញាគឺ សារ៉ាយ ប៊ុនគី ទៅទាក់ទង សារិន ឆាក, ហួត សម្បត្តិ, ចៅ សេង (នៅក្រសួងការបរទេស) ។ អ៊ិត សារ៉េត ជាអ្នកទាក់ទង ភោគ ឆាយ, ចៅ ទារី និង អ៊ុប វ៉ែន ។ ឡេវស៊ុត សោភ័នថា ជាអ្នកទាក់ទង ឌី ផុន, រស់ ជាទ្វោ, ផ្លោក សាផាន់ ដោយឡែក ឈិម សុជិត មានមុខសញ្ញាទៅទាក់ទង ម៉ែន និកថូ, នុត ប៊ុនសុង និង ដែង កៅរី ដើម្បីធ្វើជាបង្អែកនិងជាប្រភពស៊ើបពត៌មានផ្សេងៗពីក្នុងអង្គការបដិវត្តន៍ខ្មែរក្រហម ។

ថ្ងៃទី២០ ខែ៨ ឆ្នាំ១៩៧៦ ឈិម សុជិត បានធ្វើដំណើរមកដល់កម្ពុជា ។ ពេលនោះអង្គការបានបញ្ជូន ឈិម សុជិត ឲ្យទៅនៅអង្គភាពក-១៥ (នៅក្នុងសាលាបច្ចេកទេសមិត្តភាពខ្មែរ-សូវៀត) ។

ចាប់តាំងពីពេល ឈិម សុជិត មកដល់កម្ពុជារហូតដល់ថ្ងៃអង្គការចាប់ខ្លួន ឈិម សុជិត ពុំដែលបានតាមអនុវត្តផែនការដែល ជួន វិសិដ្ឋ ចាត់តាំងទេ ដោយហេតុថា ឈិម សុជិត គ្មានសិទ្ធិដើរទៅណាមកណាតាមចិត្តដូចដែលខ្លួនបានគិតនោះឡើយ ។ ឈិម សុជិត បានសរសេរនៅក្នុងចម្លើយសារភាពនោះទៀតថា គាត់ភ្ញាក់ខ្លួននៅពេលដែលឃើញសភាពការណ៍ជាក់ស្តែងនៅក្នុងប្រទេសធ្វើឲ្យគាត់ភ្ញាក់អារម្មណ៍និងបានមើលឃើញពីទិសដៅពិតប្រាកដរបស់អង្គការបដិវត្តន៍ ។

ថ្ងៃទី១ ខែ៩ ឆ្នាំ១៩៧៦ ឈិម សុជិត ត្រូវអង្គការផ្លាស់មកនៅអង្គភាពបឹងត្របែកវិញ ។ ថ្ងៃទី២៣-៩ ឈិម សុជិត ត្រូវអង្គការផ្លាស់ឲ្យទៅនៅកន្លែងមួយផ្សេងទៀតគឺអង្គភាពតាឡី ។ ឈិម សុជិត បានរស់នៅក្នុងអង្គភាពតាឡីរហូតដល់ថ្ងៃអង្គការចាប់ខ្លួននិងកម្ទេច ។

**លី សុផល**

## ប្រាក់ បូ ហៅ ប្រាក់ យុទ្ធី អ្នកសួរចម្លើយករណីអ្នកទោស ឈិម សុជិត

ប្រាក់ បូ ឬ មិត្តបូ គឺជាឈ្មោះប្រើសម្រាប់នៅក្នុងជួរបដិវត្ត ។ ឈ្មោះពិតគឺ ប្រាក់ យុទ្ធី មានអាយុ២៣ឆ្នាំ ភេទប្រុស ជនជាតិខ្មែរ ។ ប្រាក់ បូ មានស្រុកកំណើតនៅភូមិព្រែកតាដួង ឃុំព្រែកថ្មី ស្រុក១៨ តំបន់២៥ ។

ឪពុកឈ្មោះ ប្រាក់ អ៊ិន អាយុ៥៥ឆ្នាំ ជនជាតិខ្មែរ ។

ម្តាយឈ្មោះ ជា គួយ អាយុ៤៨ឆ្នាំ ជនជាតិខ្មែរ មុខរបររកស៊ីៈ ធ្វើចម្ការ ។

ប្រាក់ បូ បានបញ្ឈប់ការសិក្សាត្រឹមថ្នាក់ទី៩ចាស់ រហូតក្រោយមកនៅដើមខែ១ ឆ្នាំ១៩៧៣ ប្រាក់ បូ បានចូលបម្រើក្នុងជួរបដិវត្តតាមរយៈ ផន ស្រ៊ី ជាប្រធានរោងចក្រទឹកត្រីតំបន់២៥ ។ ផន ស្រ៊ី បាននាំ ប្រាក់ បូ ឲ្យចូលធ្វើការនៅក្នុងមន្ទីរពាណិជ្ជកម្មតំបន់២៥អស់រយៈពេលមួយឆ្នាំ ក្រោមការដឹកនាំរបស់ឈ្មោះ ហុង ប្រធានមន្ទីរពាណិជ្ជកម្មលេខ២១ក្នុងតំបន់២៥ ។ ក្រោយមកទៀត អង្គការក៏បានចាត់តាំង ប្រាក់ បូ មកកាប់ព្រៃនិងធ្វើស្រូវនៅកសិដ្ឋានមន្ទីរស-២១ អស់រយៈពេលបីខែ ដឹកនាំដោយឈ្មោះ តាស៊ឹម ប្រធានកសិដ្ឋាន ។ នៅថ្ងៃទី១៧-៤-៧៥ ប្រាក់ បូ ត្រូវអង្គការបញ្ជូនមកនៅក្នុងអង្គភាព២៦៥ ក្រោមការដឹកនាំឈ្មោះ វ៉ាត ជាអនុសេនាតូច២២ អស់រយៈពេល៩ខែទៀត ។ បន្ទាប់មកអង្គការចាត់តាំងឲ្យទៅរៀនសូត្រនៅសាលាបច្ចេកទេសយោធាកងពល៧០៣ អស់រយៈពេល៥ខែ១៦ថ្ងៃ ដែលមាន ទុយ និង ប៉េង ជាគណៈសាលាយោធា ។ ក្រោយពីបញ្ចប់វគ្គរៀនសូត្រនៅសាលាយោធាមក ប្រាក់ បូ ត្រូវអង្គការចាត់តាំងឲ្យមកធ្វើជានីរសានៅមន្ទីរស-២១ (គុកទួលស្លែង) ក្រោមការដឹកនាំរបស់ឈ្មោះ ប៉ូ អនុសេនាតូច ។ ធ្វើជានីរសាអស់ជិតមួយឆ្នាំ នៅខែ៨-៧៦ ប្រាក់ បូ ត្រូវអង្គការបញ្ជូនធ្វើជាយុទ្ធជនសួរចម្លើយនៅមន្ទីរស-២១ រហូត ។

# សំបុត្រជូនធង់ក្រហមកិត្តិយស

## ស្រុកប្រសូត ស្រុកកំពង់ត្រឡាចលើ និង ស្រុកត្រាំកក់

គោរពជូនកម្មាភិបាល យុទ្ធជន-យុទ្ធនារី និងប្រជាជនកសិករសហករណ៍ទាំងអស់នៃស្រុកប្រសូត ស្រុកកំពង់ត្រឡាចលើ និងស្រុកត្រាំកក់ ជាទីស្នេហា!

នៅក្នុងឆ្នាំ១៩៧៦ កន្លងទៅនេះ បណ្តាសមមិត្តទាំងអស់ ទាំងកម្មាភិបាល ទាំងយុទ្ធជន-យុទ្ធនារី ទាំងប្រជាជន កសិករសហករណ៍ទាំងអស់ បានលើកកម្ពស់ស្មារតីបដិវត្តយ៉ាងខ្ពស់ ធ្វើការប្រយុទ្ធស៊ិតស្វាញដោយគោលជំហរឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួនកម្រិតខ្ពស់ ពុះពារដោះស្រាយគ្រប់ឧបសគ្គដែលបណ្តាសមមិត្តជួបប្រទះជាបន្តបន្ទាប់ សម្រេចភារកិច្ចរបស់បណ្តាសមមិត្តបានយ៉ាងល្អប្រសើរលើគ្រប់ផ្នែកទាំងអស់ ទាំងកិច្ចការពារប្រទេស ការពារលទ្ធផលបដិវត្តយើង ទាំងការបន្តធ្វើបដិវត្តសង្គមនិយម ទាំងការកសាងសង្គមនិយម ធ្វើឲ្យស្រុកទាំងបីរបស់បណ្តាសមមិត្តគឺស្រុកប្រសូត្រ ស្រុកកំពង់ត្រឡាចលើ និងស្រុកត្រាំកក់ មានការរីកចំរើនយ៉ាងឆាប់រហ័ស មានលក្ខណៈសម្បត្តិជាគំរូឆ្នាំ១៩៧៦ សម្រាប់ទូទាំងប្រទេសរៀនសូត្រដើម្បីជំរុញចលនាវាយសម្រុកសម្រេចភារកិច្ចឆ្នាំ១៩៧៧របស់បក្ស ដណ្តើមមហាជ័យជម្នះ មហាលោតផ្លោះ មហាអស្ចារ្យ ថែមទៀតលើគ្រប់ផ្នែក ។

១) បណ្តាសមមិត្ត ជាគំរូខាងការបង្កបង្កើនផលនិងខាងការដោះស្រាយជីវភាពប្រជាជន ។ ស្រុកបណ្តាសមមិត្តជាស្រុកដីអន់ ទឹកខ្វះ ជីវភាពប្រជាជនមានការលំបាកតាំងពីសង្គមចាស់មក ប៉ុន្តែបណ្តាសមមិត្តបានពុះពារអនុវត្តភារកិច្ចឆ្នាំ១៩៧៦របស់បក្សបានខ្លាំងក្លា សម្រេចបានផលស្រូវជាអតិបរមា ទុកពូជបានគ្រប់គ្រាន់ ដោះស្រាយជីវភាពប្រជាជនបានល្អ ហើយផ្តល់ជូនរដ្ឋបានច្រើនទៀត ។

២) គំរូខាងគោលជំហរឯករាជ្យ-ម្ចាស់ការខ្លួនទីពឹងខ្លួន ។ បណ្តាសមមិត្តមានលក្ខណៈសម្បត្តិធម្មជាតិនិងសម្ភារសព្វបែបយ៉ាងតិចតួចណាស់ ហើយផ្នែកខ្លះអាក្រក់ផង តែបណ្តាសមមិត្តប្រយុទ្ធសម្រេចបានផលច្រើន ដោយគោលជំហរឯករាជ្យម្ចាស់ការ ខ្លួនឧបត្ថម្ភខ្លួនកម្រិតខ្ពស់ ។

៣) គំរូខាងគោលជំហរបដិវត្តសង្គមនិយម ធ្វើការផ្សារបដិវត្តសង្គមនិយមបានល្អ ធ្វើការតស៊ូបានខ្លាំងក្លា និងជ្រាលជ្រៅនៅក្នុងស្រុកបណ្តាសមមិត្តទាំងមូល ពិសេសនៅក្នុងបក្ស ។

៤) គំរូខាងគោលជំហរសមូហភាពខ្ពស់ ខាងស្មារតីលះបង់ ស្មារតីសាមគ្គីភាពធំទូលាយ ទាំងក្នុងក្របខ័ណ្ឌតំបន់ ទាំងក្នុងក្របខ័ណ្ឌភាគ ។

នេះជាជ័យជម្នះមួយធំរបស់បណ្តាសមមិត្ត ហើយក៏ជ័យជម្នះមួយធំរបស់ប្រជាជនយើងទាំងមូល របស់កងទ័ពបដិវត្តយើងទាំងមូល របស់បក្សយើងទាំងមូល ។

នេះជាការរួមវិភាគទានមួយយ៉ាងសំខាន់ក្នុងការជំរុញកិច្ចការពារប្រទេស ជំរុញចលនាបដិវត្តសង្គមនិយម និងជំរុញចលនាវាយសម្រុកកសាងសង្គមនិយមដោះស្រាយជីវភាពប្រជាជនរបស់បក្សតាមសន្ទុះមហាលោតផ្លោះ មហាអស្ចារ្យ ។

អាស្រ័យហេតុនេះ គណៈកម្មាធិការមជ្ឈិមបក្សសូមថ្លែងនូវសេចក្តីសរសើរអបអរសាទរប្រកបដោយមនោសញ្ចេតនាបដិវត្តយ៉ាងស្និទ្ធស្នាលនឹងយ៉ាងកក់ក្តៅបំផុត ដល់បណ្តាសមមិត្តទាំងអស់ ហើយសូមប្រគល់ជូនទង់ក្រហមកិត្តិយសឆ្នាំ១៩៧៦ ដល់បណ្តាសមមិត្តទាំងអស់ ។

### សមមិត្តជាទីស្នេហា

ស្រុករបស់បណ្តាសមមិត្តបានទទួលទង់ក្រហមកិត្តិយសឆ្នាំ១៩៧៦របស់បក្ស ។ នេះជាកិត្តិយសយ៉ាងខ្ពស់ខ្ពស់ដែលបក្សយើង ប្រជាជនកម្មករ-កសិករ សមូហភាពយើងទូទាំងប្រទេស កងទ័ពបដិវត្តយើង ប្រគល់ជូនបណ្តាសមមិត្តទាំងអស់ ។ នេះមិនបានន័យថាភារកិច្ចបណ្តាសមមិត្តចប់ត្រឹមប៉ុណ្ណោះទេ ។ សមមិត្តជាទីស្នេហាទាំងអស់ ត្រូវបន្តពង្រឹងពង្រីកលក្ខណៈសម្បត្តិជាគំរូរបស់ស្រុក បណ្តាសមមិត្តតទៅទៀត ដោយៈ

១) ពង្រីងពង្រីកជ័យជម្នះឆ្នាំ៧៦កន្លងមករបស់បណ្ដាសមមិត្តឲ្យខ្លាំងក្លាតទៅទៀត ដោយរៀនសូត្រពិសោធន៍គ្រប់ផ្នែកកន្លងមករបស់ស្រុកបណ្ដាសមមិត្ត ពិសោធន៍ការងារនយោបាយការងារសតិអារម្មណ៍ ការងារចាត់តាំង ការងារចាត់តាំងកម្លាំង ការងារបច្ចេកទេស ការងារការពារប្រទេស ការងារបន្តធ្វើបដិវត្តន៍សង្គមនិយម ការងារវាយសម្រុកកសាងសង្គមនិយម... ។ល ។

២) ត្រូវបន្តពង្រីងពង្រីកគោលជំហរសមូហភាព គោលជំហរសង្គមនិយម គោលជំហរឯករាជ្យ-ម្ចាស់ការខ្លួនទីពឹងខ្លួន គោលជំហរទទួលខុសត្រូវបដិវត្តខ្ពស់ គោលជំហរពុះពារគ្រប់បែបយ៉ាង ដើម្បីដណ្ដើមជ័យជម្នះបន្តទៅទៀត ដោយខិតខំពង្រីងគោលជំហររាបសាបដិវត្តជាប់ជានិច្ច សាមគ្គីភាពផ្ទៃក្នុងឲ្យបានល្អម៉ត់ចត់ជានិច្ច សាមគ្គីជាមួយអង្គភាព និងមូលដ្ឋានផ្សេងៗឲ្យបានល្អប្រសើរថែមទៀត ។



៣) ត្រូវខិតខំរៀនសូត្រពីវីរភាពបដិវត្តរួមរបស់ប្រជាជនកម្មករ-កសិករសមូហភាពយើងទូទាំងប្រទេស ដើម្បីជំរុញការងារកសាងស្រុកបណ្ដាសមមិត្ត និងកសាងខ្លួនសមមិត្តជាទីស្នេហាទាំងអស់ឲ្យកាន់តែចំរើនឆាប់រហ័សខាងនយោបាយសតិអារម្មណ៍ចាត់តាំងរបស់បក្ស ហើយតាមរយៈនេះជំរុញភារកិច្ចស្រុករបស់បណ្ដាសមមិត្តជាទីស្នេហាទាំងអស់ឲ្យកាន់តែខ្លាំងក្លាតាមផែនការឆ្នាំ១៩៧៧ គ្រប់ផ្នែករបស់បក្សហើយឆ្នាំតៗទៅមុខទៀត ។

៤) ឈរលើលក្ខណៈសម្បត្តិដែលបណ្ដាសមមិត្តបានរៀបចំជាមូលដ្ឋានហើយ ដោយសកម្មប្រយុទ្ធក្នុងរយៈពេលកន្លងមកនេះ សមមិត្តត្រូវជំរុញវាយសម្រុក វាយឲ្យដាច់ខាត៣តោននិង៦តោនក្នុងមួយហិកតារបស់បក្សឆ្នាំ១៩៧៧នេះឲ្យបានដាច់ខាត ហើយឲ្យលើសខ្លះថែមទៀតផង ។

គណៈកម្មាធិការមជ្ឈិមបក្សសូមប្រសិទ្ធពរយ៉ាងកក់ក្ដៅបំផុត ប្រកបដោយមនោសញ្ចេតនាបដិវត្តយ៉ាងជ្រាលជ្រៅបំផុត សូមសមមិត្តជាទីស្នេហាទាំងអស់ទទួលបានជ័យជម្នះជាបន្តបន្ទាប់ជានិច្ចតទៅទៀត ក្នុងការបំពេញភារកិច្ចដ៏ថ្លៃថ្លាដែលបក្សប្រគល់ជូនបណ្ដាសមមិត្ត ។ គណៈកម្មាធិការមជ្ឈិមបក្សមានជំនឿជឿជាក់ថា ស្រុកនិងមូលដ្ឋានដទៃផ្សេងទៀតនឹងសម្រេចបានភារកិច្ចឆ្នាំ១៩៧៧ គ្រប់ផ្នែករបស់បក្សបានល្អដូចស្រុកប្រសូត្រ ស្រុកកំពង់ត្រឡាចលើ និងស្រុកត្រាំកក់ ហើយខិតខំឲ្យរឹតតែល្អជាងថែមទៀតផង ។ សូមបណ្ដាសមមិត្តទទួលអំពីយើងខ្ញុំនូវការវកិច្ចប្រកបដោយភាតរភាពបដិវត្តយ៉ាងកក់ក្ដៅបំផុត ។

ថ្ងៃ ៣០ មិថុនា ១៩៧៧

គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា

## រាជសារ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
## ផ្ញើជូនជនរួមជាតិគ្រប់រូបជាទីរាប់អានស្រលាញ់ដ៏ជ្រាលជ្រៅបំផុត

ភ្នំពេញ ថ្ងៃទី២២ ខែមិនា ឆ្នាំ២០០២

ខ្ញុំសូមគោរពជនរួមជាតិគ្រប់រូប បងប្អូន កូនចៅ ចៅទួត ជាទីរាប់អានស្រឡាញ់ដ៏ជ្រាលជ្រៅជាទីបំផុត ។

មានកាសែតបរទេសមួយចំនួនគេទើបតែនឹងបោះពុម្ពផ្សាយអត្ថបទរបស់គេ សង្ខេបខុសន័យស្រឡះនូវអត្ថបទនៃសាររបស់ខ្ញុំ ដែលផ្ញើថ្វាយសម្តេចព្រះសង្ឃរាជទាំងពីរព្រះអង្គ និងព្រះសង្ឃជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងជូនជនរួមជាតិគ្រប់រូបជាទីរាប់អានស្រឡាញ់ដ៏ជ្រាលជ្រៅជាទីបំផុត នាថ្ងៃទី២១ ខែមិនា ឆ្នាំ២០០២ ។

ខ្ញុំសូមជនរួមជាតិនិងមិត្តបរទេសមេត្តាកុំជឿតាមសេចក្តីសង្ខេបខុសន័យស្រឡះរបស់កាសែតបរទេសទាំងអស់នោះ ហើយមេត្តាអានអត្ថបទទាំងស្រុងនៃសាររបស់ខ្ញុំដែលថ្វាយសម្តេចសង្ឃរាជទាំងពីរព្រះអង្គ និងព្រះសង្ឃជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងជូនជនរួមជាតិគ្រប់រូបជាទីរាប់អានស្រឡាញ់ដ៏ជ្រាលជ្រៅជាទីបំផុត នាថ្ងៃទី២១ ខែមិនា ឆ្នាំ២០០២ ។

ជនរួមជាតិណា ក្នុងឬក្រៅមាតុភូមិ ដែលចង់បានអត្ថបទទាំងស្រុងនៃសាររបស់ខ្ញុំ សូមមេត្តាទាក់ទងនឹងរាជខុទ្ទកាល័យនិងរាជលេខាធិការដ្ឋានព្រះមហាក្សត្រ នៅព្រះបរមរាជវាំង ដែលអាចផ្តល់ជូនបានតាមសេចក្តីត្រូវការ ។

សូមអរព្រះគុណនិងអរគុណជាទីបំផុត ។

## រាជសារព្រះករុណាព្រះបាទសម្តេច ព្រះ នរោត្តម សីហនុ
## ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
## ផ្ញើថ្វាយសម្តេចព្រះសង្ឃរាជទាំងពីរព្រះអង្គ និងព្រះសង្ឃជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត
## និងជូនជនរួមជាតិគ្រប់រូបជាទីរាប់អានស្រឡាញ់ដ៏ជ្រាលជ្រៅជាទីបំផុត

ភ្នំពេញ ថ្ងៃទី២១ ខែមិនា ឆ្នាំ២០០២

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំសូមព្រះអង្គជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងជនរួមជាតិ បងប្អូន កូនចៅ ចៅទួត ជាទីរាប់អានស្រឡាញ់ដ៏ជ្រាលជ្រៅជាទីបំផុត ព្រះរាជមេត្តា ព្រះមេត្តា និងមេត្តាថ្វាយ ប្រគេន និងជូននូវការពិតដូចតទៅនេះ

១១ - ក្រោយដែលលោក លន់ ណុល និងពួកលោក ធ្វើរដ្ឋប្រហារថ្ងៃ១៨ ខែមិនា ឆ្នាំ១៩៧០ ប្រជាពលរដ្ឋច្រើនពាន់នាក់នៅ

ក្នុងខេត្តក្រុងនៃកម្ពុជាមួយចំនួន លោកបានក្រោកឈរឡើងធ្វើបាតុកម្មដោយសន្តិវិធី ទាមទារនូវយុត្តិធម៌ថ្វាយសម្តេចឪ នរោត្តម សីហនុ ដែលគេបានទម្លាក់ដោយខុសច្បាប់និងដោយអយុត្តិធម៌ ។ ចំពោះបាតុករ កូនចៅប្រុសស្រី ដែលជាទីគោរពជាទីស្នេហារបស់ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំ ពួកលោក លន់ ណុល គេប្រើកាំភ្លើងតូចធំនិងរថក្រោះបាញ់សម្លាប់ដោយឥតត្រាប្រណី ។ ពេលនោះ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំនៅក្នុងរដ្ឋធានីប៉េកាំងនៃសាធារណរដ្ឋប្រជាមានិតចិន ។ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំមានទុក្ខសោកក្រៀមក្រំបំផុត និងរន្ធត់ក្នុងហឫទ័យជាអតិបរមា ។

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំពុំបានធ្វើសារសុំឲ្យកូនចៅទាំងអស់ដែលស្រឡាញ់សម្តេចឪ អញ្ជើញចូលព្រៃហើយទៅចុះចូលខ្មែរក្រហមនោះទេ ។ ក្នុងសារដែលទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំផ្សព្វផ្សាយតាមវិទ្យុប៉េកាំង ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំគ្រាន់តែនិយាយដូចតទៅនេះ ៖

"សូមកូនចៅដែលស្នេហាជាតិមាតុភូមិ ស្នេហាឯករាជ អព្យាក្រឹត បូរណភាពទឹកដីនៃកម្ពុជាយើង ចៀសវាងនូវការស្លាប់ដោយធ្វើបាតុកម្មនៅចំពោះមុខទាហានពួកលោក លន់ ណុល ហើយសូមឲ្យកូនចៅណាដែលមានឧត្តមគតិខ្ពង់ខ្ពស់ក្នុងការបម្រើការពារជាតិ ជ្រើសរើសការតស៊ូពីក្នុងព្រៃមកវិញ ដោយមានអាវុធនៅក្នុងដៃ បើកូនចៅនោះលោកចង់តស៊ូដោយមានចំណង់បែបនេះចេញពីដួងហឫទ័យនៃកូនចៅ ។ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំបានបញ្ជាក់ក្នុងសាររបស់ខ្លួនដូនទេ ។ ពាក្យបារាំង *maquis* ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំប្រើនៅក្នុងពេលនោះមានន័យថា ជាព្រៃដែលអ្នកស្នេហាជាតិតស៊ូដើម្បីរំដោះមាតុភូមិ គេប្រើជាមូលដ្ឋានទ័ពរបស់គេ ។

១២-មិនមែនទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំបានបង្កបង្កើតសង្គ្រាមប៉ះពាល់មាតុភូមិកម្ពុជាទេ ។ វរជនដែលមានឋានៈខ្ពង់ខ្ពស់នៅក្នុងរដ្ឋគេនៃលោកសេរី ដែលគេស្នេហាយុត្តិធម៌ ស្នេហាការពិត គេបានធ្វើសេចក្តីថ្លែងការណ៍ជាខទ្បារិកនៅក្នុងប្រទេសគេនោះគឺផ្តល់យុត្តិធម៌ចំពោះទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំ ។

ឧទាហរណ៍ ៖ សេចក្តីថ្លែងការណ៍ជាផ្លូវការនៃលោក BARNARD សមាជិកដ៏ឧត្តមម្នាក់នៃរដ្ឋសភាប្រទេសអូស្ត្រាលី នាថ្ងៃអង្គារ ទី៥ ឧសភា ឆ្នាំ១៩៧០ ។

ឧទាហរណ៍ ៖ សេចក្តីថ្លែងការណ៍នៃលោក MIKE MANSFIELD សមាជិកដ៏ឧត្តមម្នាក់នៃព្រឹទ្ធសភាសហរដ្ឋអាមេរិក ដែលលោកបានធ្វើភ្លាមក្រោយដែលបានទទួលដំណឹងពីភ្នំពេញថាមានរដ្ឋប្រហារ ១៨ មិនា ឆ្នាំ១៩៧០ ។

ចំណែកកាសែតនិងទស្សនាវដ្តីធំៗក្នុងលោកសេរីវិញ ក៏មានអ្នកសរសេរកាសែតល្បីល្បាញ លោកបានសរសេរផ្តល់យុត្តិធម៌ឲ្យទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំដែរ ។

ឧទាហរណ៍ ៖ លោក JACQUES LAURENT ក្នុងទស្សនាវដ្តី PARIS MATCH ខែមិនា ឆ្នាំ១៩៧០ ។

ឧទាហរណ៍ ៖ លោក BERTIL GALLAND ក្នុងកាសែតក្រុង LAUSANNE ប្រទេសស៊ុីស ថ្ងៃអង្គារ ទី១៥ ខែធ្នូ ឆ្នាំ១៩៧០ ។ល។

អស់លោកទាំងអស់នោះបញ្ជាក់ជូនជាតិគេនិងពិភពលោកជ្រាបថា នរោត្តម សីហនុ បានថែរក្សាកម្ពុជាឲ្យស្ថិតនៅក្នុងសន្តិភាព ចៀសវាងសង្គ្រាមវៀតណាមដោយជោគជ័យរហូត ។

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំមិននិយាយពីពួកលោក លន់ ណុល និងសហរដ្ឋអាមេរិកធ្វើអ្វីខ្លះទេ ដើម្បីឲ្យមានជាសង្គ្រាមធំឡើងនៅក្នុងកម្ពុជា ។

ការពិតជាប្រវត្តិសាស្ត្រដែលលោក លន់ ណុល និងសហរដ្ឋអាមេរិកបានធ្វើជាអំពើជាកំហុសធ្ងន់នៅកម្ពុជា គេឯងនៅក្នុងពិភពលោកដែលបានជ្រាបនូវការជ្រៅជ្រះ គេបានសរសេរឬអានកាសែតនិងសៀវភៅដ៏គ្រប់គ្រាន់ហើយ ។ នៅក្នុងឆ្នាំ១៩៧០

ក្រោយរដ្ឋប្រហារពួកលោក លន់ ណុល មាននិស្សិតអាមេរិកាំងច្រើនរូបក្នុងសាកលវិទ្យាល័យអាមេរិកមួយចំនួនក៏បានធ្វើការតវ៉ា និងបះបោរចំពោះរដ្ឋាភិបាលលោកប្រធានាធិបតី NIXON ដែរ ។

១៣-ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំពុំបានទៅចុះចូលពួកខ្មែរក្រហមទេ ។ តាមការពិត ហើយដែលមានលក្ខណៈជាប្រវត្តិសាស្ត្រ គឺពួកខ្មែរក្រហមនេះឯង ដែលមានលោក ខៀវ សំផន លោក ហ៊ូ យន់ និងលោក ហ៊ូ នឹម ជាតំណាង គេបានសរសេរសំបុត្រផ្ញើពីតំបន់ដែលគេរស់នៅទៅទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំដែលនៅទីក្រុងប៉េកាំងដើម្បីចូលក្នុងរណសិរ្សរួបរួមជាតិកម្ពុជានិងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។ ក្រោយមកទៀត ពួកខ្មែរក្រហមគេបានវាយកាប់សម្លាប់ឥស្សរជន ទាំងរាស្ត្រទាំងស្តេច និងប្រជាពលរដ្ឋដែលគេដឹងថានៅស្មោះត្រង់ចំពោះសម្តេចឪ ឲ្យវីរជនទាំងនោះទទួលអនិច្ចកម្មជាបន្តបន្ទាប់ ។ ក្រោយពេលដែលទ័ពខ្មែរក្រហមបានជ័យជំនះមួយរយភាគរយលើរបប លន់ ណុល និងចៅហ្វាយរបស់គេ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំវិលមកកាន់មាតុភូមិវិញ មិនមែនដើម្បីធ្វើប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យនោះទេ គឺដើម្បីតែម្យ៉ាង គឺសូមរួមសុខរួមទុក្ខជាមួយប្រជារាស្ត្ររួមជាតិ ។ អង្គការខ្មែរក្រហមគេបានឲ្យគណៈប្រតិភូរបស់គេមកជួបនឹងទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំ ពីរដងក្នុងខែមីនា ឆ្នាំ១៩៧៦ នៅប្រាសាទខេមរិន្ទ ទទូចសុំឲ្យទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំ ព្រមនៅក្នុងតំណែងជាប្រមុខរដ្ឋ ប្រធានកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំមិនបានព្រមទទួលតំណែងនេះទេ ដោយគោរពដរាបចំពោះប្រជារាស្ត្រស្លូតត្រង់ ។

សព្វថ្ងៃនេះ លោក ខៀវ សំផន លោក នួន ជា លោក អៀង សារី នៅរស់រានមានជីវិតនៅឡើយ ។ ការពិតដែលទូលនិងជំរាបនេះ គឺលោកទាំងបីនេះអាចជាសាក្សីបាន ។

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំសូមអរព្រះរាជគុណ អរព្រះគុណ អរគុណជាទីបំផុត ។

◆◆◆


លោកសេនាប្រមុខ លន់ ណុល នៃរបបសាធារណរដ្ឋខ្មែរ១៩៧០-១៩៧៥

# ទិន្នន័យទីតាំងរួមនៃអំពើប្រល័យពូជសាសន៍

## ការធ្វើផែនទីខាលពិឃាតនៃប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៥-២០០០

(តពីលេខមុន)

| ល.រ | ល.រទីតាំង | ឈ្មោះទីតាំង | ទិន្នន័យរណ្តៅនិងជនរងគ្រោះតាមជាក់ស្តែង | | ទិន្នន័យរណ្តៅនិងជនរងគ្រោះតាមរបាយការណ៍ | | របាយការណ៍ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|
| | | | ប៉ាន់ស្មានរណ្តៅ | ប៉ាន់ស្មានជនរងគ្រោះ | ប៉ាន់ស្មានរណ្តៅ | ប៉ាន់ស្មានជនរងគ្រោះ | |
| ៤០២ | ០៤០៧០១ | ត្រពាំងអំពិល | ជាង៥០០ | ជាង១ម៉ឺន | គ្មាន | គ្មាន | ១៩៩៩ |
| ៤០៣ | ០៤០៧០២ | ត្រពាំងអំពិល | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៩ |
| ៤០៤ | ០៤០៧០៣ | ស្រែជ្រៅ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៩ |
| ៤០៥ | ០៤០៧០៤ | ព្រៃដីស្រុត | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៩ |
| ៤០៦ | ០៤០៧០៥ | ព្រៃដីស្រុត | ២០០ | ៤០០ | គ្មាន | រាប់រយ | ១៩៩៩ |
| ៤០៧ | ០៤០៧០៦ | ព្រៃតាគុច | ១០ | ៣០០-៥០០ | ១០ | ៦០០០-៥០០០ | ១៩៩៩ |
| ៤០៨ | ០៥០៦០៦ | ប្រឡាយទួលតុងឡុង | ៥-៦ | ៣០០-៤០០ | គ្មាន | គ្មាន | ១៩៩៩ |
| ៤០៩ | ០៨០៦០៦ | វត្តខ្នុររកា | ១ | ២០០-២៥០ | គ្មាន | គ្មាន | ១៩៩៩ |
| ៤១០ | ០៨០៦០៧ | ភូមិខ្នុររកា | ១ | ១៦ | ១ | ១៦ | ១៩៩៩ |
| ៤១១ | ០៨០៦០៨ | ត្រពាំងចាប | បឹង | ២១៩០-២៩២០ | គ្មាន | ២១៩០-២៩២០ | ១៩៩៩ |
| ៤១២ | ១០០១០១ | គុកតំបន់២១ | ១ | ៧០០-៨០០ | ១ | ប្រហែល៨០០ | ១៩៩៩ |
| ៤១៣ | ១០០១០២ | ព្រៃត្រសេក | ចំការកៅស៊ូ | ៦០០០-៧០០០ | រាប់រយ | ប្រហែល២០០ | ១៩៩៩ |
| ៤១៤ | ១០០៥០១ | ចំការកៅស៊ូផ្អក | ចំការកៅស៊ូ | ៤០០០-៥០០០ | លើសពី១ | ៤០០០-៥០០០ | ១៩៩៩ |
| ៤១៥ | ១១០២០១ | ត្រពាំងគៀន | គ្មាន | គ្មាន | ១ | ប្រហែល២០០ | ១៩៩៩ |
| ៤១៦ | ១១០២០២ | គុកភ្នំក្រោល | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៩ |
| ៤១៧ | ១២០១០១ | ទួលស្លែង | គ្មាន | ១៥០០០ | គ្មាន | គ្មាន | ១៩៩៩ |
| ៤១៨ | ១២០១០២ | វិទ្យាល័យបឹងត្របែក | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៩ |
| ៤១៩ | ១២០៥០១ | ជើងឯក | ១២៩ | ១៣០០០ | គ្មាន | គ្មាន | ១៩៩៩ |
| ៤២០ | ១២០៥០២ | ជើងឯក | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៩ |
| ៤២១ | ១៤០៥០៥ | ភូមិទួលសា | ៤ | ៣០-៤០ | ៣ | ៣០-៤០ | ១៩៩៩ |
| ៤២២ | ១៦០២០៣ | ភូមិ៣ | ១១ | លើស១០០០ | ច្រើនជាង២ | ប្រហែល៦០០ | ១៩៩៩ |
| ៤២៣ | ១៦០៤០១ | ប្រឡាយសំរោងពែន | ១ | ៤០ | ១ | ៤០ | ១៩៩៩ |
| ៤២៤ | ១៦០២០៤ | ភូមិ៦ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៩ |
| ៤២៥ | ១៧០១០១ | ទួលបុសព្រាល | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៩ |
| ៤២៦ | ១៧០១០២ | ទួលបុសគុយ | ៤ | ៧០គ្រួសារ+៩០នាក់ | ៤ | ២៥០-៦៤០ | ១៩៩៩ |
| ៤២៧ | ១៧០៣០១ | វត្តត្បែង | គ្មាន | គ្មាន | ១ | ១៥០-២៤០ | ១៩៩៩ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤២៨ | ១៧១៤០១ | បេងថ្មីជើង | ១ | ៤០ | ១ | គ្មាន | ១៩៩៩ |
| ៤២៩ | ១៧១៤០២ | គោកតាយា | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៩ |
| ៤៣០ | ១៧១៤០៣ | បេងថ្មីត្បូង | អណ្តូង១ | ២០គ្រួសារ | ១ | ៣៥-៥០ | ១៩៩៩ |
| ៤៣១ | ១៧១៤០៤ | សាលាស្វាយស | ១-៣ | លើស៥០ | ១ | ៥០-៥៧ | ១៩៩៩ |
| ៤៣២ | ១៧១៤០៥ | វត្តស្វាយស | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៩ |
| ៤៣៣ | ១៧១៤០៦ | ព្រៃគោកចំបក់ | ១ | ២៥គ្រួសារ | ១ | ៥០-៥៧ | ១៩៩៩ |
| ៤៣៤ | ២១០៦០៨ | ពោធិ៍ជ្រៃ | ១ | ១០០-២០០ | គ្មាន | គ្មាន | ១៩៩៩ |
| ៤៣៥ | ០៣០១០៥ | ទួលតាសាន | ៤ | ៣០-៤០ | ៤ | ២០-៣០ | ២០០០ |
| ៤៣៦ | ០៣០១០៦ | វត្តប្រើសមាស | ១៥ | ៥០-៧០ | ៣ | ច្រើនជាង១០ | ២០០០ |
| ៤៣៧ | ០៣០១០៧ | ទួលប្រាសាទចាម | ១៥-១៦ | ប្រហែល១០០ | គ្មាន | ប្រហែល១០០ | ២០០០ |
| ៤៣៨ | ០៣០២០៧ | ចំការស្វាយចន្ទី | ៦០ | ៥០០០-៧០០០ | ៦ | ៥០០០-៧០០០ | ២០០០ |
| ៤៣៩ | ០៣០២០៨ | ចំការស្វាយចន្ទី | គ្មាន | គ្មាន | គ្មាន | គ្មាន | ២០០០ |
| ៤៤០ | ០៣០២០៩ | ឡូត៍អ៊ីម១៨ | តិចជាង២០ | ១៥០០ | តិចជាង២០ | ៥០០គ្រួសារ | ២០០០ |
| ៤៤១ | ០៣០២១០ | ឡូត៍អ៊ីម១៨ | ១០ | ២០០០ | គ្មាន | គ្មាន | ២០០០ |
| ៤៤២ | ០៣១៣០៣ | អូរតាគង់ | បឹង | ប្រហែល១០០០ | ១ | ប្រហែល១០០០ | ២០០០ |
| ៤៤៣ | ០៣១៣០៤ | ទួលក្រសាំង | រណ្តៅតូចៗ | ប្រហែល១០០០ | គ្មាន | តិចជាង១០០០ | ២០០០ |
| ៤៤៤ | ០៣១៣០៥ | ត្នោតជួរ | ៧០-៨០ | ២៤០-៣០០ | ៧០-៨០ | ២៤០-៣០០ | ២០០០ |
| ៤៤៥ | ០៣១៣០៦ | មន្ទីរសន្តិសុខមិត្តស៊ុប | គ្មាន | គ្មាន | គ្មាន | គ្មាន | ២០០០ |
| ៤៤៦ | ០៣១៣០៧ | សាលាបឋមសិក្សាឃុំគរ | ៦០ | ប្រហែល២៥០ | ៦០ | ប្រហែល២៥០ | ២០០០ |
| ៤៤៧ | ០៣១៣០៨ | អណ្តូងតាផន | អណ្តូង១ | ប្រហែល១០០ | គ្មាន | ប្រហែល១០០ | ២០០០ |
| ៤៤៨ | ០៣១៣០៩ | មន្ទីរសន្តិសុខស្រុក៧៧លើ | គ្មាន | គ្មាន | គ្មាន | គ្មាន | ២០០០ |
| ៤៤៩ | ០៤០២០២ | ពោធិ៍ពូនភ្នំ | ៧ | ជាង៣០ | ៧-៨ | ៣០-៤០ | ២០០០ |
| ៤៥០ | ០៤០៤០៥ | មន្ទីរគុណវិបត្តិ | គ្មាន | គ្មាន | គ្មាន | គ្មាន | ២០០០ |
| ៤៥១ | ០៤០៤០៦ | ទួលតាសាំ | ៦-១០ | ១០០-១២០ | ១៤-១៥ | ១០០-១២០ | ២០០០ |
| ៤៥២ | ០៤០៤០៧ | ភ្នំកង្កែប | ១៤-១៥ | ៤០០០-៥០០០ | ១៤-១៥ | ៤០០០-៥០០០ | ២០០០ |
| ៤៥៣ | ០៤០៤០៨ | មន្ទីរសន្តិសុខវែង | គ្មាន | ច្រើនជាង១០០ | គ្មាន | ៧០-១០០ | ២០០០ |
| ៤៥៤ | ០៤០៤០៩ | ភ្នំថ្មរៀង | ៤០ | ច្រើនជាង១ម៉ឺន | ច្រើនជាង៤ | ច្រើនជាង១ម៉ឺន | ២០០០ |

**(នៅមានត)**

តួលេខដែលចុះផ្សាយក្នុងលេខនេះសម្រាប់ខេត្តកំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កណ្តាល ក្រចេះ មណ្ឌលគិរី ភ្នំពេញ ព្រៃវែង រតនគិរី សៀមរាប និង ខេត្តតាកែវ ។

◆ ចំពោះពត៌មានមានដែលដាក់ថា "គ្មាន" មានន័យថាពុំមានសាក្សីឬតួលេខ ប៉ុន្តែវត្តមានទីតាំងបានមកពីប្រភពផ្សេងៗ ។

◆ ចំពោះពត៌មានជាក់ស្តែងនិងពត៌មានតាមរបាយការណ៍ មានន័យខុសគ្នាត្រង់ថា ពត៌មានជាក់ស្តែងគឺបានមកពីសាក្សីដែលបញ្ជាក់ប្រាប់នៅទីតាំងកើតហេតុ ។ ពត៌មានតាមរបាយការណ៍មានន័យថា សាក្សីផ្សេងទៀតដែលប្រាប់តួលេខអំពីទីតាំងដដែល ។

# កម្ពុជាធិបាលខ្មែរក្រហម និងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺជាថ្ងៃដែលប្រជាជនកម្ពុជាចាប់ផ្តើមនិងក្លាយខ្លួនជាបណ្តើរៗទៅជាជនរងគ្រោះ និរាសព្រាត់ប្រាស ទទួលការឈឺចាប់ និងបាត់បង់ជីវិត ។ ថ្ងៃដដែលនេះមានអត្ថន័យខុសប្លែកចំពោះមេដឹកនាំនិងកម្មាភិបាលខ្មែរក្រហម ។ ខាងក្រោមនេះជាការបញ្ជាក់របស់មេដឹកនាំនិងកម្មាភិបាលខ្មែរក្រហមមួយចំនួនអំពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

បន្ទាប់ពីទទួលបានជ័យជម្នះទាំងស្រុង ប៉ុល ពត បានថ្លែងទាក់ទងដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក្នុងឱកាសចាត់តាំងកងទ័ពមជ្ឈិមថា "ថ្ងៃនេះជាថ្ងៃបើកទំព័រប្រវត្តិសាស្ត្រដ៏ថ្លៃថ្លាបំផុត! ជាថ្ងៃមហាជោគជ័យនៃបក្សកុម្មុយនិស្តកម្ពុជា ដែលបានរំដោះកសិករកម្មករក្រីក្រឲ្យរួចផុតពីនឹមជិះជាន់អាមេរិកនិងសក្តិភូមិ ហើយជ័យជម្នះនេះមិនដែលធ្លាប់មានឡើយនៅក្នុងប្រវត្តិសាស្ត្រកម្ពុជាក្នុងរយៈពេលជាង២០០០ឆ្នាំកន្លងមក ។ ជ័យជម្នះជាប្រវត្តិសាស្ត្រដែលចារដោយឈាមស្រស់មិនមែនចារដោយទឹកមាសឡើយ" ។ ប៉ុល ពត បញ្ជាក់ប្រាប់កងទ័ពបដិវត្តថា ភារកិច្ចបន្តរបស់កងទ័ពបដិវត្តគឺបន្តការពារនិងកសាងប្រទេស ។

អនុលេខាបក្ស នួន ជា ទទួលបន្ទុកផ្សព្វផ្សាយគោលនយោបាយនិងសេចក្តីសម្រេចណែនាំរបស់បក្ស បានឃោសនាអំពីជ័យជម្នះរបស់បក្ស និងភារកិច្ចបន្តរបស់កងទ័ពបដិវត្តថា ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃជ័យជម្នះជាប្រវត្តិសាស្ត្រលើពួកចក្រពត្តិអាមេរិក សេ.អ៊ី.អា និង កា.ហ្សេ.បេ ។ នួន ជា បានថ្លែងទៅកាន់គណៈប្រតិភូបក្សពលករដាណឺម៉ាកថា ចក្រពត្តិអាមេរិក សេ.អ៊ី.អា និង កា.ហ្សេ.បេ នៅតែបន្តមានផែនការវាយបកបក្សដណ្តើមអំណាចវិញទាំងពីរ ខាងក្នុងនិងខាងក្រៅ ដូច្នេះហើយ "គ្រាន់តែពេលរំដោះភ្លាម យើងជម្លៀសប្រជាជនក្នុងទីក្រុងទាំងអស់ ។ ពេលនោះភ្នាក់ងារសេ.អ៊ី.អា កា.ហ្សេ.បេ និងភ្នាក់ងារវៀតណាម ត្រូវទៅនៅតាមជនបទ ហើយមិនអាចអនុវត្តផែនការដែលបានគ្រោងទុកឡើយ" ។

អៀង សារី អតីតឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការអន្តរជាតិ បញ្ជាក់ថា ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលជាថ្ងៃជ័យជម្នះដ៏មហិមានោះ ខ្លួនពុំមានវត្តមាននៅក្នុងប្រទេសឡើយ ។ អៀង សារី បានឲ្យដឹងថា ពេលនោះខ្លួនគាត់ជាប់រវល់ការងារទាក់ទងនៅប្រទេសចិនរហូតដល់ថ្ងៃទី ២៤ ខែមេសា ទើបខ្លួនបានវិលត្រឡប់មកដល់ប្រទេសកម្ពុជាវិញ ។ គាត់មិនបានចូលរួមសម្រេចផែនការជម្លៀសប្រជាជនឡើយ ។ អៀង សារី បានឲ្យដឹងទៀតថា ផែនការជម្លៀសប្រជាជនចេញពីទីក្រុងជាផែនការរបស់ ប៉ុល ពត ហើយមូលហេតុនិងបំណងនៃការជម្លៀសនេះគឺដើម្បីស្វែងរកនិងចាប់ខ្លួនខ្មាំងរបស់បដិវត្តន៍ ។

ហ៊ា កម្មាភិបាលប្រធានកងវរៈនៅក្នុងកងពល៧០៣ ទទួលបានផែនការជម្លៀសប្រជាជនចេញពីទីក្រុង ប៉ុន្តែ ហ៊ា មិនបានដឹងអំពីមូលហេតុ និងបំណងនៃផែនការជម្លៀសប្រជាជនឡើយ ។ នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហ៊ា បានទទួលផែនការរបស់បក្សឲ្យជម្លៀសប្រជាជនចេញពីទីក្រុងឲ្យអស់ក្នុងរយៈពេល៣ថ្ងៃ ។ មិនបង្អង់យូរ ហ៊ា ចាប់ផ្តើមអនុវត្តផែនការដែលបក្សដាក់ចុះភ្លាម ។ អង្គភាពរបស់ ហ៊ា ត្រូវបានប្រគល់ភារកិច្ចឲ្យទទួលខុសត្រូវជម្លៀសប្រជាជន ដែលមានលំនៅឋាននៅម្តុំរោងភាពយន្តគីរីរម្យឲ្យចេញពីទីក្រុងតាមផ្លូវទៅរោងចក្រកែវ ឆ្ពោះទៅខេត្តកំពង់ស្ពឺ តាកែវ និងកំពត ។ ក្នុងថ្ងៃជម្លៀសនោះ ហ៊ា ក្នុងសម្លៀកបំពាក់ខ្មៅបង់កក្រមាក្រហម ពាក់មួកកន្ទឹបដៃកាន់ឧគ្ឃោសនស័ព្ទ រួមនឹងយុទ្ធជនរួម ក្រុម២-៣នាក់ ប្រដាប់ដោយអាវុធនិងគ្រាប់ពេញខ្លួន ប្រកាសអំពីផែនការបក្សស្នើឲ្យប្រជាជនចេញពីផ្ទះ ។ ហ៊ា បានឲ្យដឹងថា ពេលនោះពិតជាមានក្រុមខ្លះបានបាញ់គំរាមកំហែងប្រជាជន ប៉ុន្តែចំពោះខ្លួនគាត់ផ្ទាល់

គាត់ពុំបានធ្វើបែបនោះឡើយ ។ ហ៊ី គ្រាន់តែដើរពិនិត្យមើលតាមផ្ទះ ហើយប្រកាសផែនការបក្សដែលតម្រូវឲ្យប្រជាជនចេញពីភ្នំពេញតាមសម្រួល ។ ហ៊ី រំឭក សេចក្តីប្រកាសរបស់គាត់ "បងប្អូនប្រជាជនរៀបចំប្រដាប់ប្រដាចេញពីផ្ទះ ចេញពីទីក្រុងចំនួន១អាទិត្យដើម្បីរៀបចំទីក្រុង និងដើម្បីគេចពីការទម្លាក់គ្រាប់បែករបស់ពួកអាមេរិក" ។ នៅវេលាល្ងាចថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក្រុមរបស់ ហ៊ី បាន ឆែកឆេររកឃើញទាហាន លន់ ណុល ប្រមាណជាង១០នាក់ ពួននៅក្នុងផ្ទះត្រង់ម្តុំពេទ្យចិន ។ ហ៊ី បញ្ជាក់ថា ទាហាន លន់ ណុល ទាំងនោះត្រូវកម្ទេចទាំងអស់ ។

ថេង ជាកម្មាភិបាលទទួលខុសត្រូវជម្លៀសប្រជាជននៅម្តុំផ្សារអូរឫស្សីឲ្យចេញតាមក្បាលថ្នល់ឆ្ពោះទៅខេត្តកណ្តាល ។ ថេង បានឲ្យដឹងថា ផែនការដែលបក្សប្រគល់ជូនគាត់ដើម្បីអនុវត្តនាពេលនោះមានចំនួន២គឺ ១)ចាប់ខ្លួនអតីតទាហានប៉ូលិសរបប លន់ ណុល ដែលព្រមចុះចាញ់ និង ២)ជម្លៀសប្រជាជនពីម្តុំផ្សារអូរឫស្សីឲ្យចេញទៅខេត្តកណ្តាលតាមច្រកក្បាលថ្នល់ ។ ថេង បញ្ជាក់ថា ភារកិច្ចទី១ ក្រុមរបស់គាត់សម្រេចបានលទ្ធផលល្អ ដោយបានចាប់និងបញ្ជូនខ្លួនអតីតទាហានប៉ូលិសរបបសាធារណរដ្ឋខ្មែរដែលលាក់ខ្លួននៅប៉ែកខាងជើងវិទ្យាល័យគារាវស្មីចំនួនជាង៥០នាក់ ប្រគល់ឲ្យថ្នាក់លើ ។ ចំណែកភារកិច្ចទី២ ក្រុមរបស់ ថេង ក៏បានអនុវត្តយ៉ាងមានប្រសិទ្ធភាពដែរ ពោលគឺគាត់បានប្រកាសប្រាប់និងជម្លៀសប្រជាជនដែលមានលំនៅស្ថានត្រង់ម្តុំផ្សារអូរឫស្សីឲ្យចេញទៅក្បាលថ្នល់ ហើយយុទ្ធជនទទួលខុសត្រូវនៅក្បាលថ្នល់បានបញ្ជូនប្រជាជនទាំងនោះឆ្ពោះទៅខេត្តកណ្តាលបន្តទៀត ។ ថេង រំឭកហេតុការណ៍ពេលនោះថា នៅខាងត្បូងផ្សារអូរឫស្សី យុទ្ធមិត្តក្នុងក្រុមជាមួយគាត់ម្នាក់បានចាប់ដូនចាស់ម្នាក់ទម្លាក់ពីលើផ្ទះជាន់ទី៤ចុះមកក្រោម ដោយសារតែដូនចាស់នោះប្រឆាំងនឹងផែនការរបស់អង្គការ ។ ថេង បានឲ្យដឹងថាការពិតស្ត្រីចំណាស់ម្នាក់នោះមានជំងឺស្ពឹកដើរមិនរួច ហើយកូនចៅចេញទៅអស់ទុកគាត់ចោលឲ្យនៅក្នុងផ្ទះម្នាក់ឯង ។

បន្ទាប់ពីជម្លៀសចេញពីទីក្រុង ផល្លា យុទ្ធជនក្នុងកងពល ៧០៣ បានប្រទះឃើញសាកសពមួយដេកស្លាប់នៅលើគ្រែដោយរូបកាយស្គាំងស្គមណាស់ទៅហើយ នៅលើខ្លួនប្រាណរបស់សាកសពគ្មានឃើញស្លាកស្នាមអ្វីឡើយ ។ ផល្លា អះអាងថាមូលហេតុនៃការស្លាប់នេះគឺពិតជាដោយសារជំងឺឬដាច់ពោះដោយគ្មានអាហារបរិភោគ ។

ទន្ទឹមនឹងការជម្លៀសភ្លាមនោះ ផែនការបក្សក្នុងការស្វែងរកនិងប្រហារជីវិតខ្មាំង ត្រូវបានដាក់ចុះទៅថ្នាក់ក្រោមដើម្បីអនុវត្ត ។ តាំ អតីតកម្មាភិបាលគណៈឃុំកំពែង ស្រុកព្រៃកប្បាស ខេត្តតាកែវ បានឲ្យដឹងថា គាត់បានទទួលបញ្ជានិងអនុវត្តតាមផែនការរបស់បក្ស ។ នៅពាក់កណ្តាលឆ្នាំ១៩៧៥ គាត់បានចាប់និងបញ្ជូនអតីតទាហាន លន់ ណុល ជាច្រើននាក់ ដែលរស់នៅក្នុងឃុំកំពែង ប្រគល់ឲ្យទៅគណៈស្រុកព្រៃកប្បាស ។

កម្មាភិបាលខ្មែរក្រហមម្នាក់ទៀតឈ្មោះ អែម មីន ហៅ សែន បានទទួលបញ្ជាពីអង្គការក្នុងការស្វែងរកនិងប្រហារជីវិតខ្មាំងដែរ ។ សែន បញ្ជាក់ថា "តាមផែនការបក្សត្រូវរៀបចំទទួលប្រជាជនដែលជម្លៀសចេញពីទីក្រុងភ្នំពេញនិងទីរួមខេត្តនានាទុកប្រជាជនទាំងនេះមួយកន្លែងដោយឲ្យរស់នៅក្នុងភូមិនិងឃុំរបស់ប្រជាជន ។ ចំពោះអ្នកដែលបានបង្កប់ខ្លួនក្នុងចំណោមប្រជាជន ចាំបាច់ត្រូវតែដកចេញយកទៅដាក់កន្លែងមួយផ្សេង បន្ទាប់មកធ្វើការវាយតម្លៃ ស៊ើបអង្កេតពួកនេះឲ្យច្បាស់លាស់ ។ ប្រសិនបើរកឃើញថានរណាជាមន្ត្រី ត្រូវកម្ទេចម្តងមួយៗ" ។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺជាថ្ងៃមហាជោគជ័យរបស់ខ្មែរក្រហម ហើយក៏ជាថ្ងៃដែលមេដឹកនាំខ្មែរក្រហមចាប់ផ្តើមអនុវត្តផែនការបំបែកកម្លាំងដើម្បីស្វែងរកនិងប្រហារជីវិតខ្មាំងរបស់បដិវត្តន៍ ។ ទីបំផុតប្រជាជនកម្ពុជាជាង២លាននាក់ត្រូវបាត់បង់ជីវិតក្រោមផែនការរបស់មេដឹកនាំខ្មែរក្រហម ដែលកំណត់យកថ្ងៃទី១៧មេសា ឆ្នាំ១៩៧៥ ជាថ្ងៃចាប់ផ្តើមអនុវត្តផែនការមហាលោតផ្លោះមហាអស្ចារ្យរបស់ខ្លួន ។ ព្រឹត្តិការណ៍ខាងលើនេះជាការបញ្ជាក់របស់អតីតមេដឹកនាំនិងកម្មាភិបាលខ្មែរក្រហមមួយក្រុមដែលបានចូលរួមបញ្ជា ដឹកនាំ និងអនុវត្តផែនការបម្រើមាគ៌ាមហាលោតផ្លោះមហាអស្ចារ្យរបស់ខ្មែរក្រហម នាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កាលពី២៣ឆ្នាំមុន ។

**អៀ ម៉េងទ្រី**

# បញ្ជីឈ្មោះជនរងគ្រោះដែលបានករម្មចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

**រៀបចំនិងចងក្រងដោយ: យិន នាន**

**(តពីលេខមុន)**

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១៩០ | សារ៉ាប៉ាត់ វ៉ាន់ណៃ (ស្រី) | កាត់ដេរ | តំបន់២៥ | ១១-៤-៧៦ | ?? | ប៉ាគីស្ថាន |
| ១៩១ | ខា ឌីយ៉ា | ចិញ្ចឹមគោ | តំបន់២៥ | ១១-៤-៧៦ | ?? | ប៉ាគីស្ថាន |
| ១៩២ | សារ៉ាប៉ាត់ ស៊ីរីណី (ស្រី) | លក់ដូរ | តំបន់២៥ | ១១-៤-៧៦ | ?? | ប៉ាគីស្ថាន |
| ១៩៣ | ព្រំ គឹមដឿន | វិស្វករ | បាត់ដំបង | ១-៥-៧៦ | ?? | ឈឺក្រពះ |
| ១៩៤ | អួម ផល | កម្មករ | រោងចក្រថ្មពិលថ-១ | ?? | ១-៥-៧៦ | ក្រំ ស្គឹក ចុកទ្រូង |
| ១៩៥ | ដួឡុង វាំងសី | អ្នកនិយាយវិទ្យុ | តំបន់២២ | ?? | ១-៥-៧៦ | ស្គឹក ក្រំ ហើម |
| ១៩៦ | យូ ឆាំងសែ | វិស្វករគីមី | តំបន់២៥ | ?? | ១-៥-៧៦ | ក្រំ ស្គឹក |
| ១៩៧ | យីសាឡេះ យ៉ាស់យ៉ា | ក្រសួងធម្មការ | តំបន់២២ | ?? | ២-៥-៧៦ | ស្គឹក ក្រំ |
| ១៩៨ | សៅ សោម | កងហា | កងពលខត្តរ | ?? | ៣-៥-៧៦ | ឈឺស្លាប់ |
| ១៩៩ | ស៊ីសុវត្ថិ ប៊ុតសារ៉ា | ទាហានសក្តិ២ | តំបន់២៥ | ?? | ៣-៥-៧៦ | ក្រំ ស្គឹក |
| ២០០ | ហែម សាអ៊ុន | គ្រូបង្រៀន | តំបន់២២ | ?? | ៤-៥-៧៦ | |
| ២០១ | គឹម ឌិន | លេខាធិការគិញ | ពោធិសាត់ | ?? | ៤-៥-៧៦ | |
| ២០២ | ថាច់ គឿង | កម្មករ | អគ្គិសនីផ្សារតូច | ?? | ៤-៥-៧៦ | ក្រំ ស្គឹក |
| ២០៣ | សុក រុន | កាប៊ូប៉ាល់សេហ្ | តំបន់២៥ | ?? | ៥-៥-៧៦ | ឈឺស្លាប់ |
| ២០៤ | ស្វាយ មោគ | ពេទ្យតំបន់២៥ | តំបន់២៥ | ?? | ៦-៥-៧៦ | មួល ស្គឹក |
| ២០៥ | ប៊ុត ផាត | វិស្វករនេសាទ | តំបន់២៥ | ?? | ៦-៥-៧៦ | ក្រំ ស្គឹក |
| ២០៦ | ឆួន សាមិត | ប្រជាជន | | ?? | ៧-៥-៧៦ | |
| ២០៧ | មូល វ៉ាន់ឌី ហៅ យ៉ាឡេន | ប្រជាជន | កំពង់សោម | ១៨-៧-៧៦(?) | ៧-៥-៧៦(?) | |
| ២០៨ | សំ ហាយុន | កម្មករ | រោងចក្រកង់ឡាន | ?? | ៧-៥-៧៦ | ឈឺស្លាប់ |
| ២០៩ | (មិនស្គាល់ឈ្មោះ) | ជាតិសៀម | កំពង់សោម | ?? | ៧-៥-៧៦ | ឈឺស្លាប់ |
| ២១០ | (មិនស្គាល់ឈ្មោះ) | ជាតិសៀម | កំពង់សោម | ?? | ៨-៥-៧៦ | ឈឺស្លាប់ |
| ២១១ | សៅ ម៉ន | យុទ្ធជនកង២៦០ | កងពល៧០៣ | ?? | ៨-៥-៧៦ | ស្គឹក ហើម |
| ២១២ | តែម សុផុន | កម្មករ | រោងចក្រកង់ឡាន | ?? | ៩-៥-៧៦ | ឈឺស្លាប់ |
| ២១៣ | លី យ៉ាភៀក | ជាតិយួន | កំពង់សោម | ?? | ៩-៥-៧៦ | ឈឺស្លាប់ |
| ២១៤ | ស៊ីន អ៊ាន | កម្មករ | អគ្គិសនីផ្សារតូច | ?? | ៩-៥-៧៦ | មួល ស្គឹក |
| ២១៥ | យឹម សារិន | កម្មករ | ចាក់អង្រែ | ?? | ១០-៥-៧៦ | ក្រំ ស្គឹក ទល់ |

| | | | | | | |
|---|---|---|---|---|---|---|
| ២១៦ | ង្វៀន យ៉ាវ | ជាតិយួន | កំពង់សោម | ?? | ១០-៥-៧៦ | ឈឺស្លាប់ |
| ២១៧ | ឡេយ៉ាង ង្វៀ | ជាតិយួន | កំពង់សោម | ?? | ១០-៥-៧៦ | ឈឺស្លាប់ |
| ២១៨ | សាវ៉ាន់ ឡៃ | ប្រជាជនមូលដ្ឋាន | តំបន់២៥ | ?? | ១០-៥-៧៦ | ឈឺស្លាប់ |
| ២១៩ | ហ៊ីង ជ្រុន | ប្រជាជន | កំពង់ឆ្នាំង | ?? | ១០-៥-៧៦ | ឈឺស្លាប់ |
| ២២០ | ថៃ វ៉ា ហៅ រ៉ុំ | ភ្នាក់ងារមន្ទីរ១១ | តំបន់២៥ | ?? | ១០-៥-៧៦ | ក្រំ ស្គីក |
| ២២១ | ឡាយ សំអឿន | កូនសិស្ស | ព្រែកហូរ | ១-៩-៧៦(?) | ១១-៥-៧៦(?) | |
| ២២២ | ហ៊ុន ផល | យុទ្ធជន ៩៩ | កងពល៧០៣ | ?? | ១១-៥-៧៦ | ឈឺស្លាប់ |
| ២២៣ | អរ៉ាំង លី | ប្រជាជន | តំបន់២៥ | ?? | ១១-៥-៧៦ | មួលឈាម |
| ២២៤ | យួក ហ៊ីល | បុគ្គលិកឃ្លាំងប្រាក់ | តំបន់២៥ | ?? | ១១-៥-៧៦ | មួលឈាម |
| ២២៥ | ឡាយ សំអឿន ហៅសំអុល | កូនសិស្ស | តំបន់២៥ | ?? | ១១-៥-៧៦ | គ្រុនសន្និចុកស្មុះទ្រូង |
| ២២៦ | ហេង ញ៉ិល ហៅ មឿន | ស្មៀន | សង្កាត់លេខ៥ | ?? | ១២-៥-៧៦ | ស្គីក ចុកស្មុះ ហើម |
| ២២៧ | ប៊ុត ឈឿន | កម្មករ | តម្បាញ ត-២ | ?? | ១២-៥-៧៦ | ក្រំ ស្គីក |
| ២២៨ | ឃ្លោក ដារាភាក់ | វិស្វករបច្ចេកទេស | តំបន់២២ | ?? | ១៣-៥-៧៦ | ក្រំ ស្មុះទ្រូង |
| ២២៩ | ហ៊ុន សារី | នេសាទត្រី | កំពង់សោម | ?? | ១៤-៥-៧៦ | ឈឺស្លាប់ |
| ២៣០ | ចាង ង្វៀងឡឹប | គិញយួន | កំពង់សោម | ?? | ១៤-៥-៧៦ | ឈឺស្លាប់ |
| ២៣១ | ជឹង វ៉ាងយី | គិញយួន | កំពង់សោម | ?? | ១៤-៥-៧៦ | ឈឺស្លាប់ |
| ២៣២ | ឈាវ តិចហ៊្វរ | កូនសិស្ស | ?? | ?? | ១៤-៥-៧៦ | ស្គីក ក្រំ |
| ២៣៣ | ង៉ែត ញ៉ាន់ | កងហា១៣៤ | ?? | ?? | ១៤-៥-៧៦ | ស្គីក ស្មុះ |
| ២៣៤ | យូ ដាន | កម្មករ | អគ្គិសនីផ្សារតូច | ?? | ១៤-៥-៧៦ | ក្រំ ស្គីក |
| ២៣៥ | ពាង ដូ | កម្មករ | រោងចក្រទឹកដោះគោ | ៨-៤-៧៦ | ១៤-៥-៧៦ | ឈឺស្លាប់ |
| ២៣៦ | ង៉ែត ឈុនង៉ាន | យុទ្ធជន១៧០ | ?? | ?? | ១៤-៥-៧៦ | ឈឺស្លាប់ |
| ២៣៧ | នូ ពុំ | វរសេនាតូច២៥៧ | ព្រែកព្នៅ | ?? | ១៤-៥-៧៦ | ឈឺស្លាប់ |
| ២៣៨ | សំ សាសនា | គ្រូបង្រៀន | តំបន់២២ | ២២-២-៧៦ | ១៥-៥-៧៦ | ឈឺស្លាប់ |
| ២៣៩ | ទេព សុខុម | រដ្ឋការ | មុខកំពូល | ២៩-១-៧៦ | ១៥-៥-៧៦ | ឈឺស្លាប់ |
| ២៤០ | គីម សាអែម | កម្មករ | អគ្គិសនីចាក់អង្រែ | ?? | ១៥-៥-៧៦ | ស្គីក ចុកទ្រូង |
| ២៤១ | ពាង ដូ | កម្មករ | រោងចក្រទឹកដោះគោ | ?? | ១៥-៥-៧៦ | ហើម ស្គីក |
| ២៤២ | ង៉ែត ខន | អនុប្រធាននេសាទ | តំបន់២៥ | ?? | ១៥-៥-៧៦ | ស្គីក ឈឺក្រពះ |
| ២៤៣ | ឈាង ថោង | កម្មាភិបាលត-១៣ | បឹងត្របែក | ?? | ១៥-៥-៧៦ | |
| ២៤៤ | ហេន ហ៊ុន ហៅ ហ៊ាន | យុទ្ធជន ត-៩២ | បឹងត្របែក | ?? | ១៥-៥-៧៦ | |
| ២៤៥ | ចិន សៀ ហៅ ហាន | កម្មាភិបាលសាលាត-៩២ | បឹងត្របែក | ?? | ១៥-៥-៧៦ | |
| ២៤៦ | អោ អាន ហៅ រី | ប្រធានយោធាត-៩២ | បឹងត្របែក | ?? | ១៥-៥-៧៦ | |
| ២៤៧ | សឺន សារី ហៅ ប្រេវ | មន្ទីរ ត-១៤ | បឹងត្របែក | ?? | ១៥-៥-៧៦ | |
| ២៤៨ | រដ្ឋ ប៊ូ ហៅ កង | មន្ទីរ ត-១៣ | បឹងត្របែក | ?? | ១៥-៥-៧៦ | **(នៅមានត)** |

# រូបថតឯកសារ




***រូបទី១:*** កង ខេម អាយុ២១ឆ្នាំ(១៩៧៧) កើតនៅភូមិព្រៃតាម៉ែម ឃុំព្រែកស្តី ស្រុក១៨ តំបន់២៥ វណ្ណៈកណ្តាលថ្នាក់ក្រោម ។ ឪពុកឈ្មោះ កង ស្រី ។ ម្តាយឈ្មោះ ទេព នឹម ។ កង ខេម មានបងប្អូន៩នាក់ ។ បានចូលធ្វើបដិវត្ត នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧៣ ។ នៅខែ៦ ឆ្នាំ១៩៧៥ កង ខេម ត្រូវបាន ផ្លាស់មកធ្វើជាយុទ្ធជនមន្ទីរស-២១ ។ បច្ចុប្បន្នមិនដឹងស្លាប់ឬរស់ ។

***រូបទី២:***

◆ គុយ កុល អាយុ២៦ឆ្នាំ(១៩៧៧) កើតនៅភូមិសំរោងក្អែ ឃុំសំរោងធំ ស្រុក១៦ តំបន់២៥ វណ្ណៈភាពអនុធនសិស្ស ។ ឪពុកឈ្មោះ គុយ មុត ជនជាតិខ្មែរ ។ ម្តាយឈ្មោះ ឡុង ប៉ុក ជនជាតិខ្មែរ ។ គុយ កុល មានបងប្អូន៤នាក់ ប្រុស២នាក់ ស្រី២នាក់ ។ គុយ កុល បាន ចូលធ្វើបដិវត្តនៅថ្ងៃទី២៧ ខែ៨ ឆ្នាំ១៩៧៣ នៅព្រែកតាហង់ ឃុំកំពង់កុង ស្រុក ២០ តួនាទីជាយុទ្ធជន ។ នៅខែ៦ ឆ្នាំ១៩៧៥ គុយ កុល បាន ចូលមកបម្រើការនៅមន្ទីរស-២១រហូតមក ។ បច្ចុប្បន្នមិនដឹងស្លាប់ឬរស់ ។




***រូបទី៣:***

◆ គីត តយ អាយុ២០ ឆ្នាំ(ឆ្នាំ១៩៧៧) ស្រុកកំណើត នៅភូមិកំពតពុល ឃុំព្រែកអំបិល ស្រុក២០ តំបន់២៥ វណ្ណៈភាពកសិករកណ្តាល ថ្នាក់ក្រោម ។ ឪពុកឈ្មោះ គីត តុំ ជនជាតិខ្មែរ ។ ម្តាយឈ្មោះ ប៊ូ ហេង អាយុ៤២ឆ្នាំ ជនជាតិខ្មែរ ។ គីត តយ មានបងប្អូន៥នាក់ ប្រុស៣នាក់ ស្រី២នាក់ ។ គីត តយ ចូលបដិវត្តនៅថ្ងៃទី៣ ខែ១៣ ឆ្នាំ១៩៧៣ តួនាទីជាយុទ្ធជននីរសា ។ នៅខែ១១ ឆ្នាំ១៩៧៤ ផ្លាស់មកធ្វើការនៅអគ្គភាព១៤៣ បានកន្លះខែ ក៏ផ្លាស់មកនៅវរសេនាធំ២៦៧ តួនាទីជានីរសាដដែល ។ គីត តយ ធ្លាប់បានទៅរៀនវគ្គបច្ចេកទេសយោធាបាន៦ខែ ទើបមកធ្វើការនៅវរសេនា១៤៣វិញ ក្នុងនាមជា



យុទ្ធជន ។ ខែ១ ឆ្នាំ១៩៧៥ គីត តយ បានមកធ្វើជាយុទ្ធជនពេទ្យនៅមន្ទីរ ស-២១រហូត ។ បច្ចុប្បន្នមិនដឹងស្លាប់ឬរស់ ។




**រូបទី៤:**

◆ ឆឹង ជៀន អាយុ២៣ឆ្នាំ(១៩៧៧) ស្រុកកំណើតនៅភូមិត្បែង ឃុំតាំងក្រសាំង ស្រុក១៤ តំបន់៣១ វណ្ណៈភាពកសិករក្រ ។ ឪពុកឈ្មោះ ឆឹង ។ ម្តាយឈ្មោះ ម៉ិល ប៉ុង ។ មានបងប្អូន៨នាក់ ប្រុស៤នាក់ ស្រី៤នាក់ ។ ឆឹង ជៀន ចូលធ្វើបដិវត្តនៅថ្ងៃ១០ ខែ៩ ឆ្នាំ១៩៧៣ នៅក្នុងស្រុក១៤ តំបន់៣១ ធ្វើជាមេក្រុមអស់រយៈពេល៣ឆ្នាំ ។ ក្រោយមកថ្ងៃទី២៥ ខែ៩ ឆ្នាំ១៩៧៥ បានទៅរៀនសាលាយោធាកងពល៧០៣ នាទីជាមេក្រុមដដែល ដែលឈ្មោះ ទុយ ជាអ្នកដឹកនាំ ។ ក្រោយពីរៀនចប់ថ្ងៃទី១៨ ខែ៣ ឆ្នាំ១៩៧៦ អង្គការដកមកឲ្យធ្វើការនៅមន្ទីស-២១ ។ បច្ចុប្បន្នមិនដឹងស្លាប់ឬរស់ ។




**រូបទី៥:**

◆ រ័ត្ន នឹម ហៅ សោម នឹម អាយុ២៨ឆ្នាំ (ឆ្នាំ១៩៧៧) ភេទស្រី ស្រុកកំណើតនៅភូមិព្រែកថ្មី ឃុំព្រែកថ្មី ស្រុក១៨ តំបន់២៥ វណ្ណៈភាពកសិករក្រ ។ មុនចូលបដិវត្តធ្វើចម្ការ ។ ឪពុកឈ្មោះ សោម រដ្ឋ ធ្វើការនៅសហករណ៍ (របបកម្ពុជាប្រជាធិបតេយ្យ) ។ ម្តាយឈ្មោះ ហ៊ឹម អ៊ិន (ស្លាប់) ។ សោម នឹម បានចូលធ្វើបដិវត្តន៍នៅថ្ងៃទី ១៥-៥-៧៤ ។ បច្ចុប្បន្នរស់នៅខេត្តកណ្តាល ។




**រូបទី៦:**

◆ សេង ចក់ អាយុ២០ឆ្នាំ (១៩៧៧) ស្រុកនៅភូមិកំពង់ទ្រា ឃុំស្អាងភ្នំ ស្រុក២០ តំបន់២៥ វណ្ណៈភាពកសិកកណ្តាលថ្នាក់ក្រោម ។ ឪពុកឈ្មោះ កា សេង ។ ម្តាយឈ្មោះ ជ៉ោ សែម ស្លាប់ ។ សេង ចក់ មានបងប្អូន៧នាក់ ប្រុស៥នាក់ ស្រី២នាក់ ។ សេង ចក់ បានចូលបដិវត្តន៍ថ្ងៃទី៨-៣-១៩៧៤ នៅឃុំស្អាងភ្នំ ដែលមានតួនាទីជាយុទ្ធជនអស់រយៈពេល៨ខែ ។ ក្រោយមក សេង ចក់ បានទៅនៅរៀនសូត្រ រួចបន្តនៅតាមអង្គភាព២៩៦និងអង្គភាព១៣០ ។ រហូតដល់ថ្ងៃទី២៨-១១-១៩៧៥ សេង ចក់ បានផ្លាស់មកមន្ទីរស-២១ ។ បច្ចុប្បន្នមិនដឹងស្លាប់ឬរស់ ។

**លី សុផល**

# កប់បាត់នៅក្នុងបដិវត្តន៍ខ្មែរក្រហម

**«ដាក់វើៗ ខុសដៃយកដៃ ខុសជើងយកជើង មិនដឹងមុខ»** ជាសម្តីរបស់មីង ដួន និយាយសំដៅលើការសម្លាប់រង្គាលអ្នកជម្លៀសពីភ្នំពេញ ។

មុនឆ្នាំ១៩៧៥ កូនចៅរបស់អ្នកស្រុកនៅខេត្តកំពង់ធំ ដែលមានអាយុចាប់ពី១៣ដល់១៨ឆ្នាំ ត្រូវបានខ្មែរក្រហមមកជ្រើសរើសឲ្យចូលបម្រើបដិវត្តន៍របស់ខ្លួន ។ កូនចៅអ្នកស្រុកដែលចូលបម្រើបដិវត្តន៍មិនបានរៀនសូត្រជ្រៅជ្រះទេ ហើយក៏មិនយល់ច្បាស់លាស់អំពីបដិវត្តន៍ថាដូចម្តេចដែរ ។ វ៉ាត់ ដែលត្រូវជាកូនប្រុសរបស់ពូ ជ័យ ឆែម ត្រូវបានប្រធានភូមិឈ្មោះ អឹម មកយកទៅឲ្យបម្រើយោធាខ្មែរក្រហមតាំងពី វ៉ាត់ មានអាយុប្រហែល១០ឆ្នាំម៉្លេះ ។ ពូឆែម មានការងឿងឆ្ងល់យ៉ាងខ្លាំង ហើយចោទសួរទៅប្រធានភូមិវិញថា កូនរបស់គាត់នៅក្មេងណាស់ តើអាចធ្វើយោធាយ៉ាងម៉េចទៅកើត? ។ ប្រធានភូមិឈ្មោះ អឹម បានឆ្លើយតបវិញថា កូនរបស់ពូឆែម មិនមែនក្មេងទេគឺនៅមានអ្នកដទៃទៀតមានវ័យក្មេងៗជាងហ្នឹងដងដែលធ្វើយោធានោះ ។ ក្រៅពីការងារយោធានៅមានការងារផ្សេងទៀតសម្រាប់ក្មេងៗទាំងនោះ




ដូចជាការងារផ្នែកវាយអក្តុលីលេខ (ករណីឈ្មោះ ធា ហៅ សុខ ត្រូវបានអង្គការមកយកទៅបម្រើការងារតាំងពីអាយុបាន ១៦-១៧ឆ្នាំ) នេសាទត្រី (ករណីឈ្មោះ រ៉ុ ចូលបដិវត្តន៍ ក្នុងអាយុប្រហែល១៨-១៩ឆ្នាំ) ។ នៅក្នុងកំឡុងឆ្នាំ១៩៧០ មន្ទីរ ៨៧០របស់អង្គការនៃរបបកម្ពុជាប្រជាធិបតេយ្យគឺស្ថិតនៅក្នុងទឹកដីខេត្តកំពង់ធំ កែ្បរស៊ឹងជីទិត ។ ក្នុងជំនាន់នោះ ខេត្តកំពង់ធំត្រូវបានបែងចែកចូលទៅក្នុងភូមិភាគឧត្តរ ដែលជាស្រុកកំណើតរបស់សមមិត្ត ប៉ុល ពត លេខាបក្សកុម្មុយនិស្តកម្ពុជា ។

ចាប់តាំងពីពេលចូលបម្រើបដិវត្តន៍រហូតដល់ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ កូនចៅរបស់ពូមីង បានមកលេងផ្ទះម្តងឬពីរដងប៉ុណ្ណោះ ជាពិសេសគឺនៅថ្ងៃដែលរបបខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញ ។ កូនប្រុសរបស់ ពូឆែម បានឆៀងចូលលេងផ្ទះម្តងគត់នៅក្នុងខណៈដែលបើកឡានឆ្ពោះទៅខេត្តព្រះវិហារ ។ ការឆៀងចូលលេងផ្ទះរបស់កូនប្រុសពូឆែមឈ្មោះ វ៉ាត់ បានបង្កឲ្យកើតមានព្រឹត្តការណ៍អាណោចអាធ័មមួយ ។ ហេតុការណ៍នេះបានកើតឡើងដោយសារតែប្រធានសហករណ៍មិនអនុញ្ញាតឲ្យប្អូនស្រីរបស់ វ៉ាត់ បានទៅជួបជុំគ្រួសារក្នុងពេលដែលបងប្រុសរបស់ខ្លួនមកលេងផ្ទះដោយកម្រ ។ ដោយមានការខឹងសម្បានឹងប្រធានសហករណ៍ ប្អូនស្រីរបស់ វ៉ាត់ ឈ្មោះ សឿន បានធ្វើអត្តឃាតដោយយកផ្លែឡាមឆូតពោះខ្លួនឯងចំនួន៣០ ផ្លែឡាមរហូតដល់ស្លាប់បន្ទាប់ពីដឹកមកមន្ទីរពេទ្យមួយនៅក្នុងឃុំកំពង់គរ ។ អុឹ កន ត្រូវជាប្អូនបង្កើតរបស់មីង ឃឿន មកលេងផ្ទះបាន(ពីរថ្ងៃ) តែម្តងគត់ ចាប់តាំងពីពេលដែលបានបម្រើបដិវត្តន៍ក្នុងអាយុចន្លោះ១៧-១៨ឆ្នាំ ។ ការដែលបានមកលេងផ្ទះនេះ មិនមែនទទួលបានការអនុញ្ញាតត្រឹមត្រូវឡើយ គឺត្រូវលួចមកនៅពេលដែល កន កំពុងមានរបួសសុសពេញទាំងខ្លួន សម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យមួយ ។ បងស្រីបង្កើតរបស់ អុឹ កន និយាយថា "មកម្តងហ្នឹងរបួសសុសអស់ហើយ ពេញខ្លួនប្រាណ មកនេះរត់ពីកន្លែងពេទ្យមកកន្លែងម៉ែឪមករកបងរកប្អូនណា៎..." ។ អុឹ កន ត្រូវបានមេរបស់ខ្លួនបញ្ជាឲ្យកូនចៅទៅចាប់យកមកវិញ ដែលតាំងពីពេលនោះមកក៏បាត់ដំណឹងឈឹងតែម្តង ។ ដួង ឈិន មិនដែលបានមកលេងផ្ទះម្តងឡើយ ចាប់តាំងពីខ្លួនចូលធ្វើទាហានខ្មែរក្រហម ។ នៅពេលដែលរបបកម្ពុជាប្រជាធិប-តេយ្យដួលរលំនៅដើមខែមករា ឆ្នាំ១៩៧៩ ទើប ដួង ឈិន

បានវិលមកផ្ទះវិញជាមួយនឹងជើងម្ខាងដែលពិការដោយសារគ្រាប់មីនក្នុងសង្គ្រាមខ្មែរក្រហមជាមួយនឹងវៀតណាម ។ ចំណែក ឯឈ្មោះ កុយ ទង និង ខឹម ឈឿ មិនដែលបានមកលេងផ្ទះទាល់តែសោះចាប់តាំងពីចូលបម្រើបដិវត្តន៍ខ្មែរក្រហម មានតែសំបុត្រមួយច្បាប់ម្នាក់ប៉ុណ្ណោះដែលផ្ញើមកក្រុមគ្រួសារ បន្ទាប់ពីនោះមកក៏បាត់ដំណឹងឈឹងរហូតដល់សព្វថ្ងៃនេះ ។ មានតែប្អូនស្រីរបស់ កុយ ទង ទេដែលចាំបាននូវខ្លឹមសារសំបុត្របងរបស់ខ្លួនសរសេរផ្ញើមកក្រុមគ្រួសារ ។ មីង កុយ ដួន រៀបរាប់ថាបងរបស់គាត់ឈ្មោះ កុយ ទង បានផ្ញើសំបុត្រមកផ្ទះតាមរយៈការដ្ឋាននៅពេលដែលភ្នំពេញត្រូវបានរំដោះឆ្នាំ១៩៧៥ ។ មីង ដួន និយាយថា «បងអីទៅជួបទៅ ជួបនឹងប្អូន ព្រោះប្អូនមិនបានមកវិញទេ នៅធ្វើការនឹងគេសិន ចាំមើលសភាពការណ៍ទៅមុខទៀត ។ បើថាម៉ែចៗចាំប្អូនបានធ្វើការងារនឹងគេ ចាំប្អូនមកលេង ។ ប្រាប់បងផ្ញើសំបុត្រមកបង បងបង្អស់ទី១ នោះណា៎...» ។

រហូតមកទល់នឹងថ្ងៃនេះ ឪពុកម្តាយ បងប្អូន ព្រមទាំងញាតិមិត្តនៅតែទន្ទឹងរង់ចាំមើលផ្លូវនៅឡើយ ប៉ុន្តែក្តីសង្ឃឹមរបស់គាត់មានតិចតួចណាស់ ។ មានករណីខ្លះ ឪពុកម្តាយទន្ទឹងចាំមើលផ្លូវកូនរហូតដល់ទទួលមរណភាព នៅតែមិនបានជួបកូនទៀត ។ មីង ម៉ុង ប្អូនស្រីរបស់ រ៉ុ និយាយថា «រហូតទល់ឥឡូវហ្នឹង ទល់ម៉ែខ្ញុំងាប់ ចាំមើលផ្លូវកូនមិនដែលឃើញ» ។ លោកតា ឆែម និយាយថា ពូធ្លាប់បានទទួលដំណឹងអំពីកូនរបស់គាត់ឈ្មោះ វ៉ាត់ កាលពីទស្សវត្សរ៍ឆ្នាំ១៩៨០តាមរយៈឈ្មោះ ឈុំ ។ តាមសម្តីរបស់ ឈុំ ពូឆែម និយាយថា កូនរបស់គាត់រស់នៅក្នុងជំរំសាយធូ ក៏ប៉ុន្តែគាត់និយាយបន្ថែមថា «អត់មានដែរព្រោះទៀតទេ ទទេស្អូន្យសព្វថ្ងៃនេះ» ។ មីង ដួន ធ្លាប់ទទួលដំណឹងកាលពីទស្សវត្សរ៍ឆ្នាំ ១៩៨១ តាមរយៈឪពុកមារបស់មីងឈ្មោះ ហ៊ូ យ៉ន ថាបងប្រុសគាត់ឈ្មោះ កុយ ទង នៅមានជីវិតនៅឡើយ ។ កាលណោះ ពូ យ៉ន រស់នៅភូមិកំពង់ឈើទាល បានដឹកស្រាយកទៅលក់នៅភូមិជីសំពៅ ហើយនៅតាមកំណាត់ផ្លូវពូបានជួបនឹង កុយ ទង ក៏ប៉ុន្តែ កុយ ទង មិនបានស្គាល់ពូថា ជាឪពុកមារបស់ខ្លួនទេ ។ តាំងពីពេលនោះមកមីង ដួន មិនដែលបានទទួលដំណឹងអ្វីទៀតសោះ អំពីបងប្រុសរបស់គាត់ ។ មីង ដួន និយាយថា «...ឲ្យតែព្រួសផ្ករលាន់ត្រឹមហើយ និយាយពីថាសឹងខ្លោចចិត្តនឹកឃើញដល់បងណា៎...» ។




វ៉ាយ សុខ មានសម្បុរខ្មៅ សក់រួញអង្កាជី ខ្ពស់ បានចូលបម្រើបដិវត្តន៍ខ្មែរក្រហមតាំងពីអាយុ ១៣ឆ្នាំ បច្ចុប្បន្នមិនទាន់មានដំណឹងអ្វីបន្តិចបន្តួចនៅឡើយ ។ ឪពុករបស់ វ៉ាយ សុខ ឈ្មោះ វ៉ាយ រីម នៅតែរង់ចាំថ្ងៃដែលកូនរបស់គាត់វិលវិញជានិច្ច ទោះបីជាគាត់គិតថាកូនរបស់គាត់ប្រាកដជាស្លាប់ក៏ដោយ ។ ពូ វ៉ាយ សុខ និយាយដោយក្តីនឹករឭកកូនថា «...ទោះក្រលំបាកម៉េចឲ្យតែនៅជុំគ្នា បាយមួយវែក សណ្តែកមួយក្តួរ ឲ្យតែបានស៊ីទាំងអស់គ្នាណា៎ក្មួយ ។...នឹកឃើញពេលណាឡើង...នឹកឃើញថាភ្លៀងខ្យល់ភ្លៀងផ្គររម្ពងៗ នឹកឃើញកូនចៅដែរ ការហូបចុកវាឆ្អែតមិនឆ្អែតណា៎...» ។ ពូ វ៉ាយ រីម នៅតែមិនអស់ចិត្តថាកូនរបស់គាត់មិនគួរគ្មានដំណឹងសោះ ដោយនិយាយថា «...នៅដល់អូស្ត្រាលីអីនៅណាណីគេផ្ញើសំបុត្រមកម៉ែឪគេអស់ នៅអីថ្ងៃនៅអីណាផ្ញើមកអស់ កូនគេអ្នកនៅ កូនខ្ញុំបាត់...» ។ មីង សំ យឿន បានទៅរកគ្រូទាយអំពីជោគវាសនារបស់ប្អូនឈ្មោះ កន ។ គ្រូទាយបានទស្សន៍ទាយថា អ៊ឹកន នៅរស់នៅឡើយ មិនទាន់ស្លាប់ទេ ។ ទោះបីជាយ៉ាងនេះក៏ដោយ រហូតមកដល់បច្ចុប្បន្ននេះនៅតែបាត់ដំណឹង អ៊ឹកន ដដែល ។ មីង សំ យឿន និយាយថា «គ្មានអត់ស្អូន្យតែហ្នង គ្មានឃើញអីទេ» ។

ចំណែកឈ្មោះ ធា ហៅ សុខ ដែលត្រូវអង្គការខ្មែរក្រហមបញ្ជូនទៅឲ្យបម្រើការងារខាងផ្នែកវាយអង្គុលីលេខនៅភ្នំពេញ តាំងពីអាយុ១៦-១៧ឆ្នាំ បច្ចុប្បន្ននៅរស់នៅឡើយ ។ មិនដឹងថា ធា បានដឹងពីឪពុកម្តាយរបស់ខ្លួនត្រូវបានខ្មែរក្រហមយកទៅសម្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬយ៉ាងណានោះទេ ។ មីង ពុធ អ៊ុន ដែលត្រូវជាម្តាយមីងរបស់ ធា ហៅ សុខ

រៀបរាប់អំពីជីវិតឪពុកម្តាយរបស់ ធា ហៅ សុខ ថា «...ឪពុកធ្លាប់ធ្វើសន្លាក់ ដល់យូរទៅថាយើងជាប់និន្នាការណ៍ គេយកទៅរៀនសូត្រនៅឯចំការលើ




ប្រពន្ធនៅវត្តកណ្តាលនេះ គេរៃប្រពន្ធអស់មួយគ្រួសារទៅ ។ មីកូនហ្នឹងនៅមួយហ្នឹង ដោយសារអង្គការយកទៅធ្វើខាងអង្គលីលេខនៅឯភ្នំពេញ» ។ ក្នុងអំឡុងឆ្នាំ១៩៩៥-៩៦ ឈ្មោះ ធា ហៅ សុខ បានមកលេងម្តាយមីងម្តងនៅភូមិហាន់ទូរ ឃុំជ្រលង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ ចាប់តាំងពីពេលនោះមក ឈ្មោះ ធា មិនដែលបានមកលេងនឹងម្តាយមីងទៀតទេ ។ ឈ្មោះ ធា សព្វថ្ងៃមានគ្រួសារនិងមានកូនចៅរស់នៅម្តុំអូររជក្រោះប៉ៃលិន ហើយបានប្តូរឈ្មោះថា សុខ ឯក ។

បន្ថែមពីលើរឿងរ៉ាវបាត់ខ្លួនរបស់អតីតយុទ្ធជនយុទ្ធនារីខ្មែរក្រហម ខ្ញុំបានទទួលព័ត៌មានមួយចំនួនទៀតទាក់ទងទៅនឹងជីវិតផ្ទាល់ខ្លួនរបស់បងប្អូនឬឪពុកម្តាយដែលរស់នៅឯសមរភូមិក្រោយ ។ ពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ពូ ជ័យ ឆែម បានធ្វើជាចុងភៅដាំស្លឲ្យប្រធានសន្តាគនិងកូនទាហាននៅក្នុងសន្តាគជាប់រហូត ។ កាលណោះប្រធានសន្តាគឈ្មោះ ខាត់ ប៉ុន្តែក្រោយមកក៏ត្រូវខ្មែរក្រហមសម្លាប់ចោល ។ ពូឆែម និយាយថា របបនៃការហូបចុកសម្រាប់សន្តាគគឺអាស្រ័យលើប្រធានជាអ្នកដាក់បញ្ជាថាតើត្រូវដាំបបរឬដាំបាយ ។ ពូ ឆែម បាននិយាយថា «ប្រធានសន្តាគនោះឯង គេថាថ្ងៃណេះបបរ ថ្ងៃណេះដាំ..យើងធ្វើតាមតែគេទៅ» ។ សន្តាគដែលពូ ឆែម រស់នៅជិតនោះមានឈ្មោះថា សន្តាគសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ ។ ក្រៅពីកិច្ចការធ្វើចុងភៅ ពូ ឆែម ធ្លាប់ត្រូវបានប្រធានសន្តាគប្រើឲ្យជួយចងមនុស្សដើម្បីយកទៅសម្លាប់ចោល ។ ពូ ឆែម បានប្រកែកនឹងបញ្ជារបស់ប្រធានសន្តាគដែរ ដោយនិយាយថា «ខ្ញុំថាអត់ជួយទេ មនុស្សអត់ខឹងមិនចេះចងម៉េច» ។ លើសពីនេះទៅទៀត ពូ ឆែម ធ្លាប់ឃើញមានដឹកមនុស្សទាំងរថយន្តៗ នៅឃុំកំពង់គោក្នុងស្រុកប្រាសាទបល្ល័ង្ក ។ ពូឆែម និយាយថា ការដឹកនេះភាគច្រើននៅវេលាម៉ោង៥រសៀល ហើយច្រើនដឹកឆ្ពោះទៅទិសខាងជើង ដែលកន្លែងនោះត្រូវបានហៅថា វយៀវគល់ត្នោត ។ តាមការប៉ាន់ស្មានរបស់ ពូឆែម ថា មនុស្សនៅលើរថយន្តមានចំនួនពី ៣០ទៅ៥០នាក់ ដែលក្នុងនោះរួមមានកូនក្មេងរញ៉ីករញ៉ៃផង ។ អំពើទាំងអស់នេះកើតឡើងបានដោយសារតែមានការចាត់ចែងពីប្រធានសន្តាគថាតើនរណាមួយត្រូវយកទៅសម្លាប់ឬអត់ ។ ពូ ឆែម និយាយថា «ប្រធានសន្តាគគេចាត់ចែងឲ្យយកទៅសម្លាប់ អ្នកណាឲ្យត្រូវគេយកទៅសម្លាប់ ប្រធានគេធ្វើចារទៅអ្នកទៅហៅឈ្មោះនេះឈ្មោះនោះ ម៉ាជំនាន់ហ្នឹង» ។ ការទៅហៅឈ្មោះនោះគឺក្រោមលេសថាត្រូវទៅប្រជុំ ឬប្រើកលល្បិចភរថា ត្រូវផ្លាស់ទៅកន្លែងផ្សេង ឬត្រូវទៅរៀន មនុស្សដែលមកជុំគ្នាបានឡើងឡានទៅតែម្តង ដោយមិនខ្លួនថាត្រូវដឹកយកទៅសម្លាប់ចោលទេ ។ ពូឆែម និយាយថា «ហើយក៏ឡើងជិះឡានទៅ អរគេថាឲ្យផ្លាស់ ព្រោះអីឯណេះស៊ីបបរ ក្រែងទៅឯណោះបានឲ្យស៊ីបាយដឹង? ខ្ទះអរមិនដឹងគេយកទៅអីចុះអី...» ។ នៅចន្លោះម៉ោង៧-៨យប់ រថយន្តដែលដឹកមនុស្សចេញក៏ត្រឡប់មកវិញ ។ ពូឆែម និយាយថា «បើពីម៉ោង៥ ដូចជាម៉ោង៧-៨ ឯណោះបានរថយន្តត្រឡប់មកវិញ...មិនដែលឃើញទេ ម៉ោតែរថយន្តទទេ...» ។ ពូឆែម មិនដែលឮអ្នកណាម្នាក់នៅកន្លែងសន្តាគនិយាយខ្សឹបខ្សៀវគ្នាអំពីរឿងឡានដឹកមនុស្សនេះទេ ពីព្រោះថាសូម្បីតែពូ ឆែម ខ្លួនឯងដែលធ្លាប់ត្រូវបានប្រធានសន្តាគប្រើឲ្យជួយចងមនុស្សក៏ដោយ ក៏មិនត្រូវបានអនុញ្ញាតឲ្យនៅក្បែរកន្លែងរថយន្តដឹកមនុស្សចេញចូលដែរ ។ កិច្ចការនេះមានតែប្រធានសន្តាគនិងកូនចៅដែលបម្រើការងារផ្ទាល់ជាមួយប្រធានសន្តាគទើបអាចដឹងបាន ។ ពូឆែម និយាយថា «...ព្រោះខ្ញុំមានគេឲ្យចូលទៅគេមិនឲ្យទៅជិតទេ ពេលធ្វើការគេមានកន្លែងគេ ធ្វើការទៅចូលក្នុងរោងគេបាត់ទៅ ឯងមិនហ៊ានទៅបៀតទេ...» ។ ឆ្នាំនេះ ពូឆែម មានអាយុ៦៦ឆ្នាំ ប្រកបមុខរបរធ្វើស្រែនិងធ្វើជាជាងដំដែក ។ ប៉ុន្តែនៅក្នុងចិត្តរបស់ ពូឆែម

គឺនៅតែនឹកកូន រ៉ាត់ ដែលបាត់ដំណឹងឈឹង និងនៅតែឈឺចាប់ខ្លោចផ្សាចំពោះកូនស្រីតែមួយរបស់ពូឈ្មោះ សឿន ដែលខឹងនឹងប្រធានសហករណ៍មិនអនុញ្ញាតឲ្យខ្លួនបានមកលេងជាមួយបងប្អូនរហូតដល់ថ្នាក់ធ្វើអត្តឃាតខ្លួនឯងដោយវះពោះនឹងថ្ងៃឡាម៣០ថ្ងៃ ។

ខុសប្លែកពីអ្វីដែល ពូឆែម ដឹងព្ធនិងឃើញថាមានអ្វីកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យអំឡុងឆ្នាំ១៩៧៥-៧៩ ។ មីង កុយ ជួន អាយុ៥១ឆ្នាំ បានជួបប្រទះនិងដឹងរឿងរ៉ាវដែលពាក់ព័ន្ធទៅនឹងការរំលោភបំពានផ្សេងៗ ។ មីង ជួន រៀបរាប់ហេតុការណ៍ដែលបានកើតឡើងចំពោះប្រជាជនដែលជម្លៀសពីភ្នំពេញមករស់នៅក្នុងភូមិរបស់មីង ។ អ្នកមកពីភ្នំពេញជួបការលំបាកខ្លាំង ហើយត្រូវបានបង្ខំឲ្យធ្វើការជាទម្ងន់នៅតាមការដ្ឋាន ។ មីងជួន និយាយថា "...ប៉ិនធ្វើបាបច្រើនអ្នករត់មកពីក្រុងភ្នំពេញ ជំនាន់ដែលគ្នាជម្លៀសចេញម៉ោណ៎...ខុសតែបន្តិចសោះយកគ្នាទៅវ៉ៃចោលឡើងស្ងាត់អស់ហើយភូមិនេះ" ។ មីងជួន និយាយរបៀបរដឹងៗតាមភាសាអ្នកស្រុកថា "អត់មានរស់អីអាលីង ដប់គ្រួសារទៅទាំងអស់ គ្រួសារសុទ្ធតែអ្នកម៉ោពីភ្នំពេញ ឡើងរងាហើយ គ្នាលើកថ្កល់អីចេះ ឯងលើកពីថ្ងៃ យប់ឡើងវ៉ៃឡើងរលីងឆិញទាំងកូនតូចកូនធំ" ។ ការសម្លាប់អ្នកមកពីភ្នំពេញនេះទៀតសោត គឺសម្លាប់បំផុតពូជតែម្តងមិនឲ្យសល់កូនឬប្រពន្ធអ្វីទេ ។ មីងជួន ត្រូវបានអ្នកនៅធ្វើការជាមួយគ្នាចាត់ទុកថាជាមនុស្សមិនចេះខ្លាច ។ មីងជួន មានការងឿងឆ្ងល់ថាចុះហេតុអ្វីក៏ឆាកសម្លាប់ៗ ហើយក៏សួរទៅប្រធានសហករណ៍ឈ្មោះ អឺ ប៉ាក់ ។ មីងជួន និយាយថា "គាត់ថា ម៉ោពីមិត្តឯងស័ក្តិ១ ស័ក្តិ២ហ្នឹង ទុកធ្វើអី ប្តីគេសម្លាប់ទៅហើយទុកប្រពន្ធធ្វើអី..." ។ មីងជួន បានរំឭកសម្តីប្រធានសហករណ៍ឈ្មោះ អឺ ប៉ាក់ បន្តថា "...មូលហេតុម៉ោពីប្តី ស័ក្តិ១ ស័ក្តិ២នោះឯងទុកធ្វើអី ព្រោះអង្គការថ្នាក់លើគេឲ្យជម្រើសចម្រាញ់អាអញ្ចេះឯង កុំឲ្យទុកជិះជាន់.." ។ មីងជួន បានចងចាំថា ក្នុងករណីសម្លាប់មីងថូនិងកូនប្រុសម្នាក់ទៀត គឺបណ្តាលមកពីប្តីរបស់មីងថូ ធ្លាប់ពាក់សក្តិពីក្នុងរបប លន់ ណុល ។ មីងថូ ត្រូវយកទៅសម្លាប់ទាំងយប់ ។ មុននឹងយក មីងថូ ទៅសម្លាប់នៅវេលាយប់នោះ មីងថូបានសុំខ្ចីអាវរបស់ មីង ជួន យកទៅពាក់រហូតទាល់តែប្រធានសហករណ៍ឈ្មោះ គាលីម ស្រែកឲ្យថា "ឲ្យអាវមិត្ត ជួនវិញ" ។ មីងជួន និយាយថា "គាត់ដឹងខ្លួនគាត់តើ គាត់ថាមិនឲ្យដេញចាបទេ ឲ្យខ្ញុំទៅវ៉ៃចោលនោះ ឯងទៅវ៉ៃចោលមុខនេះហើយ មិនបាច់យកទៅវ៉ៃចោលក្នុងព្រៃទេ គ្មានពីណាកប់ទេ..." ។ "គេកាប់អន្ទង់ស្រេចទៅហើយ ម៉ោវិញឃើញអែបផ្លូវ ហើយផ្លូវអីចេះ អន្ទង់អីចេះឯង ប៉ុនកប់មិនទាំងជិតដើងផង ដើងបងថូច្បាស់ ចែសសស្កុះ..." ។ បន្ទាប់ពីមានការសម្លាប់រង្គាលប្រជាជនដែលជម្លៀសពីភ្នំពេញបានកើតឡើងយ៉ាងផុសផុលនោះហើយ មីងម្ចាស់ផ្ទះម្នាក់ដែលមិនស្គាល់ឈ្មោះបាននិយាយប្រាប់មីងជួន ឲ្យប្រយ័ត្នប្រយែងក្នុងការមាត់ក និងថែមទាំងបាននិយាយថា ក្នុងក្រុមរបស់មីងជួន នឹងត្រូវដកមនុស្សម្នាក់ ។ មីង ជួន មានប្រផ្នូលក្នុងចិត្ត ហើយមានការសង្ស័យទៅលើមនុស្សតែម្នាក់គត់ ។ មីងជួន និយាយគ្រាប់សម្តីរបស់មីងម្ចាស់ផ្ទះដែលបាននិយាយប្រាប់ខ្លួនថា "ខ្ញុំពុតម្រុយអត់ស្រួលទេថា កងក្មួយឯងនេះប្រុងដកមួយដែរ..." ។ មីង ជួន ភ្ញាក់ព្រើតនឹងសម្តីមីងម្ចាស់ផ្ទះ ហើយគាត់ភិតភ័យយ៉ាងខ្លាំង ។ ក្នុងពេលនោះមីង ជួន លាន់មាត់ថា "ខ្ញុំថាអ្ហ៊ុយ! ដល់អ្នកណាអីចេះ? ខ្ញុំសង្ស័យបង ថូ មួយទេ បងថូគេគុំយូរណាស់ហើយ..." ។

**ខ៉ាន់ថាន់ ពៅដារ៉ា**

## ពន្យល់ពាក្យខ្មែរក្រហម

◆ ***ធាតុពិតជាប់ជិតស្និទ្ធនឹងមហាជនៈ*** មានមហាជននៅជាមួយបក្ស ។ គណៈកម្មាធិការបក្សមួយនៅក្នុងអង្គភាពមួយ បើគ្មានមហាជននៅជាមួយមិនខ្លាំងទេ ។ នៅជាមួយក្នុងន័យសតិអារម្មណ៍នៅជាមួយ នយោបាយនៅជាមួយ ចាត់តាំងនៅជាមួយ ។ *(ទង់បដិវត្តលេខ៧ កក្កដា ១៩៧៦)*

◆ ***ជាប់ជាមូលដ្ឋានៈ*** ស៊ីជម្រៅទៅក្នុងចលនា គឺជាប់នឹងប្រជាជនកសិករក្រ និងកណ្តាលថ្នាក់ក្រោម ។

*(សៀវភៅរៀនសូត្រ "អំពីការងារពង្រឹងនិងកែលម្អគោលដំហរនិងអាកប្បកិរិយាដឹកនាំនឹងធ្វើការងាររបស់បក្ស")*

**(តពីលេខមុន)** នៅក្នុងចម្លើយសារភាពរបស់ខ្លួន ស៊ុន ទី បានសរសេរកំណត់សម្គាល់ដោយឡែកដល់អង្គការដែលនៅតែសង្កត់ថាគាត់មានកំហុស ហើយបាននិយាយទៀតថាខ្លួនត្រូវបានធ្វើទារុណកម្ម ។ "មុនដំបូងខ្ញុំមិនព្រមឆ្លើយទេ ប៉ុន្តែក្រោយពីគេវាយខ្ញុំនឹងដំបងធំមួយមក ខ្ញុំក៏ប្រឌិតចម្លើយតែម្តងទៅ ។ ខ្ញុំសូមឲ្យបក្សកុំចាប់មនុស្សដែលខ្ញុំរៀបរាប់ឈ្មោះនេះ ។ សមមិត្តយើងសុទ្ធតែមនុស្សល្អទេ ។ ខ្ញុំមិនមែនជាសេ.អ៊ី.អា ឬខ្មែរសេរីទេ" ។ តាមរយៈសម្តីដកស្រង់ពីឯកសាររបស់ ស៊ុន ទី ផ្ទាល់បញ្ជាក់ថាពាក្យសម្តីទាំងនេះមិនដែលលេចចេញទៅខាងក្រៅទេ ។




**សម្លេងពីមន្ទីរ ស-២១**

**វគ្គទី៥: បង្ខំឱ្យឆ្លើយ**

**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

ឧទាហរណ៍ទារុណកម្មមួយចំនួនដែលរៀបរាប់នៅក្នុងបណ្ណសារនេះ និងរៀបរាប់ដោយអ្នកដែលមានវាសនារួចផុតពីសេចក្តីស្លាប់ នៅទីនោះមានដូចខាងក្រោមនេះ÷

*វាយៈ ដោយដៃ ដោយដំបង ដោយមែកឈើ ដោយខ្សែភ្លើង ។ អុចភ្លើងបារី ឆក់ខ្សែភ្លើង ឲ្យស៊ីលាមក ឲ្យផឹកទឹកនោម ឲ្យស៊ីទាំងបង្គួ ព្យួរជើងឡើងលើដាក់ក្បាលចុះក្រោម ព្យួរដៃឡើងលើពេញមួយថ្ងៃ យកម្ជុលចាក់ចូលសាច់ ឲ្យសំពះរូបឆ្កែ (ចាប់ពីឆ្នាំ១៩៧៨មក) ឲ្យសំពះជញ្ជាំង ឲ្យសំពះតុ ឲ្យសំពះកៅអី ចាប់ដកក្រចក ឆូតសាច់ រុញផ្កាប់មុខ យកថង់ខ្ទប់ច្រមុះ ទារុណកម្មដោយទឹក ជ្រមុជទឹក និងដាក់ទឹកឲ្យស្រក់លើក្បាលរយៈពេលយូរ ។*

ប្រភេទទារុណកម្មទាំងនេះមិនបញ្ចូលទារុណកម្មដែលរៀបរាប់តាមរយៈផ្ទាំងគំនូររបស់ វ៉ាន់ ណាត ផងទេ ។ និយាយទៅកាន់អ្នកថតកុនមកពីអាល្លឺម៉ង់ខាងកើត វ៉ាន់ ណាត រំឭកឡើងវិញថា "នេះជាបន្ទប់ដែលខ្ញុំធ្វើការ ។ ជួនកាលខ្ញុំមើលតាមប្រហោងបង្អួចប្រេះ ឃើញហេតុការណ៍ដែលកំពុងកើតឡើងនៅខាងក្រៅ ។ ខ្ញុំឃើញគេចាប់អ្នកទោសជ្រមុជទឹក ។ អ្នកផ្សេងទៀតត្រូវបានចាប់យកទៅសួរចម្លើយដោយគ្មានសម្លៀកបំពាក់ជាប់ខ្លួនឡើយ ។ អ្វីៗដែលខ្ញុំលួចមើល ខ្ញុំព្យាយាមកត់ទុកហើយគូរចេញជារូបភាពទាំងនេះ" ។

ក្នុងចំណោមអ្នកសួរចម្លើយទាំង២១នាក់ដែលត្រូវបានកត់ទុកនៅក្នុងសៀវភៅទូរស័ព្ទនៅមន្ទីរស-២១ មាន១៨នាក់មានពាក់ព័ន្ធក្នុងការធ្វើទារុណកម្មអ្នកទោស ។ ពាក្យទាំងនេះមាននៅក្នុងចម្លើយសារភាពរបស់អ្នកទោស របស់អ្នកសួរចម្លើយផ្ទាល់ ឬនៅក្នុងការប្រជុំស្វ័យទិតៀននានាដែលធ្វើឡើងសម្រាប់បុគ្គលិកគុក ។ ក្នុងចំណោមអ្នកសួរចម្លើយនៅមន្ទីរស-២១ចំនួន២៨នាក់ដែលក្រោយមកត្រូវបានចាប់ខ្លួននោះ មាន១៨នាក់បានសារភាពថាបានធ្វើទារុណកម្មលើអ្នកទោស ។ មាន១១នាក់ថាបានវាយអ្នកទោសទាល់តែស្លាប់ ហើយឆ្មាំគុកម្នាក់ក៏បាននិយាយដូច្នេះដែរ ។ មានចម្លើយមួយចំនួនក្នុងចម្លើយសារភាពទាំងអស់នេះបានឆ្លើយដាក់អ្នកផ្សេងទៀត ដែលជាបុគ្គលិកនៅមន្ទីរស-២១ ប៉ុន្តែឯកសារទាំងអស់នេះមិនមាននៅសល់ទេ ។ បណ្ណសារនេះបញ្ជាក់ថា អ្នកសួរចម្លើយមួយចំនួនបានរៀបចំខ្លួនជាស្រេចក្នុងការធ្វើទារុណកម្ម ។ មានម្នាក់ឈ្មោះ បុត ហេង ក្រោយមកត្រូវបានចាប់ខ្លួនដែរនោះ បានសារភាពថាបានរំលោភផ្លូវភេទជនរងគ្រោះ ហើយថាបានវាយអ្នកទោសទាល់តែស្លាប់ រួមទាំងអ្នកទោសម្នាក់ដែលទទួលរងរបួសធ្ងន់ធ្ងរ ក្រោយពីប៉ុនប៉ងធ្វើអត្តឃាតមិនបានសម្រេច ។

ការរំលោភផ្លូវភេទទៅលើអ្នកទោសជាស្ត្រីប្រហែលជាកើតឡើងញឹកញាប់ ប៉ុន្តែរឿងនេះកម្រមាននិយាយនៅក្នុងចម្លើយសារភាពរបស់បុគ្គលិកគុកណាស់ ។ អ្នកមើលការខុសត្រូវនៅក្នុងគុកច្បាស់ជាមិនយល់ព្រមឲ្យមានអំពើនេះកើតឡើងទេ ដូចជាសៀវភៅកំណត់ហេតុរបស់ ចាន់ បញ្ជាក់ប្រាប់ថា "នៅពេលសួរស្រីៗ ត្រូវតែមានមនុស្សពីរនាក់ ។ កុំផ្តេកគេ

ហើយកុំចាប់សក់ឬបិចថ្ពាល់ឲ្យសោះ» ។

អ្នកដែលមានវាសនានៅរស់បានរំឭកឡើងវិញនូវការវាយដំមកលើរាងកាយរបស់ខ្លួន ។ អ្នកទោសនៅមន្ទីរស-២១ ម្នាក់ឈ្មោះ អ៊ឹង ប៉ិច ដែលបានចាកផុតពីសេចក្តីស្លាប់បាននិយាយប្រាប់លោក ដាវីដ ហក ថា «ចំពោះរឿងវាយវិញ គឺប៉ះអីវាវាយហ្នឹង ដូចជាមែកឈើ ដើមឫស្សី រំពាត់ខ្សែភ្លើងជាដើម ។

ការឆក់ខ្សែភ្លើងត្រូវបានធ្វើឡើងជាទូទៅ រហូតដល់មានសេចក្តីណែនាំដែលមានចំណុចមួយដាក់ថា «កុំស្រែកនៅពេលឆក់ខ្សែភ្លើង» ។ សេចក្តីណែនាំនោះដាក់ថា ពិន័យសម្រាប់ការមិនធ្វើតាមអ្នកសួរចម្លើយគឺវាយ១០រំពាត់ ឬ«ឆក់ខ្សែភ្លើងប្រាំដង» ។ ការចងចាំរបស់ វ៉ាន់ ណាត ប្រហែលជាពិសេសណាស់មើលទៅ÷ «(អ្នកសួរចម្លើយ) យកខ្សែភ្លើងមករុំខ្នោះ ដៃខ្ញុំ ហើយយកម្ជុលខ្វាស់មកភ្ជាប់កន្ទុយខ្សែទៅនឹងខោ ហើយវាក៏អង្គុយចុះវិញ ។ តើឯងនៅចាំទេ? អ្នកណាជាអ្នកចូលរួមក្បត់(អង្គការ) ? ។ ខ្ញុំរកនឹកអ្វីមកនិយាយមិនចេញសោះ ។ វាក៏ភ្ជាប់ខ្សែភ្លើងជាមួយចរន្តភ្លើងមកឆក់ខ្ញុំ ។ ពេលនោះខ្ញុំសន្លប់បាត់ស្មារតី មិនដឹងជាគេឆក់ប៉ុន្មានដងទេ ។ ប៉ុន្តែនៅពេលដឹងខ្លួនឡើងវិញ ខ្ញុំឮសំឡេងពីចម្ងាយសួរល្មើយៗទៀតថាតើអ្នកណាជាខ្សែរបស់ឯង ។ ខ្ញុំមិនអាចនិយាយកើតឡើយ សូម្បីតែពាក្យមួយម៉ាត់ក៏និយាយមិនចេញផង ។ វាបានឆក់ខ្ញុំខ្លាំងណាស់ ទាល់តែខ្ញុំដួលទៅលើឥដ្ឋ អាវខ្ញុំទទឹកញើសជោក...មកដល់ថ្ងៃនេះខ្ញុំមិនដឹងថាហេតុអ្វីបានជាគេចាប់ខ្ញុំទេ» ។

ចំណាររបស់អ្នកសួរចម្លើយទៅលើចម្លើយសារភាពមួយចំនួនបង្ហាញថា ជាញឹកញយ អ្នកទោសតែងតែទ្រូឌទ្រោមរាងកាយនិងឆ្លើយ«យ៉ាងពេញលេញ»នៅពេលខ្លួនត្រូវបានគំរាមកំហែងដោយឆក់ខ្សែភ្លើង ។ អ្នកខ្លះទៀតក្រោយពីឆក់ខ្សែភ្លើងរួចទើបឆ្លើយ ។ អ្នកសួរចម្លើយបានសរសេរថា «អ្នកទោសម្នាក់និយាយថាវាមិនអាចស៊ូទ្រាំជាមួយនឹងការឆក់ខ្សែភ្លើងបានទៀតទេ ហើយថាថ្ងៃមប្រមាត់វារលាយអស់ហើយ» ។ អ្នកទោសផ្សេងទៀតត្រូវធ្វើទារុណកម្មកាន់តែតឹងតែងជាងនេះទៅទៀត ។ អ្នកសួរចម្លើយបានកត់សម្គាល់ថា អាម្នាក់នោះ «វាមិនឆ្លើយទេ ទាល់តែធ្វើទារុណកម្មខ្លាំងទើបវាឆ្លើយ» ហើយម្នាក់ទៀតនៅពេល «ធ្វើទារុណកម្មខ្លាំងទៅជាមិនព្រមឆ្លើយទៅវិញ» ។ អ្នកសួរចម្លើយរបស់ លី ផេន ដែលជាជនបដិវត្តដើមចាស់កត់សម្គាល់ថា «ក្រាញមិនព្រមនិយាយពីសកម្មភាពរបស់វា ដូច្នេះខ្ញុំក៏ប្រើទារុណកម្ម» ។ «នៅពេលវាដឹងខ្លួនឡើងគឺគិតតែពីក្អួត» ។ អ្នកសួរចម្លើយហៅស្ត្រីម្នាក់ថា«ខិលខូចណាស់» ។ «ដោយមិនអាចស៊ូទ្រាំងនឹងការធ្វើទារុណកម្ម វាក៏ស្រោតសារុងចេញធ្វើពុតជាឈឺ» ។ ឌុច ពុំមានត្រាប្រណីទេចំពោះអ្នកណាដែលចចេសមិនព្រមសម្របខ្លួន ។ មានពេលមួយ ឌុច បានប្រាប់ទៅអ្នកសួរចម្លើយម្នាក់ថា «វាយ(អ្នកទោស)រហូតទាល់តែវាឆ្លើយអស់ វាយវាឲ្យនិយាយកាន់តែស៊ីជម្រៅ» ។

ទារុណកម្មម្យ៉ាងទៀតដែលត្រូវបានធ្វើជាញឹកញាប់នៅមន្ទីរស-២១ គឺការ«ថ្វាយបង្គំ» ។

វ៉ាន់ ណាត រំឭកឡើងវិញអំពីការគូររូបឆ្កែដែលមានក្បាលជា ហូជីមិញ បិទជាប់ទៅនឹងជញ្ជាំងសួរចម្លើយ និងការនិយាយស្តីរបស់អ្នកសួរចម្លើយនៅទីនោះ ។ ដូចដែល ចនម៉ាសស្តុន លើកឡើងដូច្នេះដែរ ថាការថ្វាយបង្គំរបៀបនេះគឺជា «ការបញ្ឆោកអំពីឋានៈ» ខ្លាំងជាងការប្រត្តិបត្តិក្នុងការសំពះរបស់ប្រជាជនកម្ពុជាទូទៅទៅទៀត ។ ពាក្យទាំងពីរនេះត្រូវបានប្រើសម្រាប់បញ្ឆោកការធ្វើទារុណកម្មពិសេសនេះ ។ នៅក្នុងសង្គមកម្ពុជាមុនសម័យបដិវត្ត របៀបរបបថ្វាយបង្គំដែលលើកដៃពីរប្រណម្យឡើងទៅលើក្បាល និងដួនកាលក្រាបផ្ទាល់នឹងដី គឺប្រើសម្រាប់ក្រាបថ្វាយបង្គំសម្តែងការគោរពចំពោះព្រះមហាក្សត្រឬព្រះសង្ឃ ឬសម្រាប់គោរពព្រះពុទ្ធបដិមាតែប៉ុណ្ណោះ ។ នៅមន្ទីរស-២១ កាយវិការនេះប្រហែលជាបង្កឲ្យមានការឈឺចាប់ ហើយប្រហែលជាដូចនឹង«យន្តហោះ» ដែលគេបង្ខំអ្នកទោសឲ្យធ្វើតម្រាប់តាមនៅក្នុងបដិវត្តវប្បធម៌ចិន ។ ចំណាររបស់អ្នកសួរចម្លើយម្នាក់និយាយថាបានឲ្យអ្នកទោសសំពះអស់ពេលកន្លះម៉ោង ហើយមានម្នាក់ទៀតនិយាយថា ឲ្យអ្នកទោសថ្វាយបង្គំ«ប្រាំដង» ។ នៅក្នុងករណីខ្លះ «ការថ្វាយបង្គំ»ជាការគួរឲ្យឈឺចាប់គ្រប់គ្រាន់ទៅហើយ ដែលធ្វើឡើងសម្រាប់ចំរាញ់យកចម្លើយសារភាពឲ្យបានពេញលេញ ។

នៅឆ្នាំ១៩៧៨ រូបភាពតំណាងអាមេរិកាំងត្រូវបានថ្វេ

ចូលក្នុងលក្ខណៈដូចគ្នាទៅនឹងរូបរបស់ហូជីមិញដែរ ។ ចំណាររបស់អ្នកសួរចម្លើយម្នាក់នៅលើចម្លើយសារភាពរបស់ ស្វាង គុំ បញ្ជាក់ថារូបទីពីរជារូបរបស់ លីនដុន ចនសុន ។ "ដំបូងនៅពេលដែលយើងចូលទៅដល់កន្លែងសួរចម្លើយ ក្រោយពីខ្ញុំសួរស្រីនោះអំពីប្រវត្តិ និងសួរថាហេតុអ្វីបានជាអង្គការចាប់ខ្លួន វាក៏ស្រែកយំហ៊ូដោយនិយាយថាប្តីរបស់វាជាជនក្បត់ ហើយថាវាមិនបានក្បត់ទេ ។ ខ្ញុំក៏ដាក់ពិន័យដោយឲ្យវាថ្វាយបង្គំរូបឆ្កែដែលមានក្បាលហូជីមិញ និងក្បាលរបស់ ចនសុន ប៉ុន្តែវាមិនព្រមសំពះឡើយ ។ ខ្ញុំក៏វាយវាដែលមិនព្រមនិយាយរឿងនិងមិនគោរពវិន័យរបស់សន្តិបាល ។ វាអស់សង្ឃឹមហើយក៏ចាប់ផ្តើមនិយាយអំពីខ្សែក្បត់" ។

ខាងក្រោមនេះជាអត្ថបទទាំងស្រុងដែលជាចំណារពីរនិយាយអំពី "ការថ្វាយបង្គំ"រូបគំនូរ ។ អត្ថបទទាំងពីរនេះ មួយជារបស់ ចាន់ និងមួយទៀតជារបស់ ទុយ-ប៉ុន ដែលសរសេរនៅក្នុងការប្រជុំជីវភាពនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៨ ។ កំណត់ហេតុទាំងពីរនេះមានភាពខុសគ្នាបន្តិចបន្តួច ហើយមានលក្ខណៈគួរឲ្យកត់សម្គាល់ទៀតផង ។

### អត្ថបទរបស់ ទុយ-ប៉ុន

*"យើងសាកល្បងឲ្យវាថ្វាយបង្គំឆ្កែទាំងពីរ ។ ឆ្កែនេះគឺមានន័យនយោបាយ ។ ឆ្កែទីមួយគឺជាអាមេរិក ។ ឆ្កែទីពីរគឺវៀតណាម ។ នៅពេលវាគោរព វាទទួលស្គាល់ថាវាគាំទ្រអាពីរនេះ ។ តាមទស្សនៈសតិអារម្មណ៍ (យើងទុកអ្នកទោស)មួយជុំ ហើយមិនឲ្យវានៅឡូកឡំជាមួយយើងទេ ។ តាមទស្សនៈអង្គការ យើងបង្ខំឲ្យវាគោរពសន្តិបាល ។ កន្លងមកយើងបានសម្រេចលទ្ធផលល្អណាស់" ។*

នៅចុងបញ្ចប់ ទុយ-ប៉ុន បានដកស្រង់សម្តីរបស់អ្នកឡើងមានយោបល់នៅវគ្គសិក្សានោះដែលនិយាយថា "អ្នកមិនត្រូវវាយអ្នកទោសនៅពេលគេខឹងទេ ។ នៅពេលខឹងវាយមិនឈឺទេ" ។ អ្នកសួរចម្លើយក៏ត្រូវបានជំរុញឲ្យទប់កំហឹង ដូចដែលសៀវភៅរបស់អ្នកសួរចម្លើយម្នាក់បានកត់សម្គាល់ថា "នៅពេលខ្លះយើងធ្វើទាំងកម្រោល ហើយការណ៍នេះធ្វើឲ្យយើងបាត់បង់ម្ចាស់ការ ។ វាធ្វើឲ្យ(អ្នកទោស)មានសតិអារម្មណ៍មិនពេញលេញ និយាយវិលចុះវិលឡើងតែពីរឿងរស់និងស្លាប់" ។ អ្វីដែលត្រឹមត្រូវនិងអ្វីដែលមិនត្រឹមត្រូវក្នុងការចាត់ការរឿងអាយុជីវិតនេះ មិនត្រូវបានលើកមកនិយាយច្បាស់ទេ ។

### អត្ថបទរបស់ ចាន់

*"យើងបង្ខំវាឲ្យគោរពរូបឆ្កែទាំងពីរក្បាល ។ នេះគឺជាវិធីសួរចម្លើយមួយ ។ រូបឆ្កែនេះមានសារសំខាន់ផ្នែកនយោបាយ ។ ឆ្កែទី១ ជាចក្រពត្តិអាមេរិក ។ ឆ្កែទី២ជាខ្មាំងលេបទឹកដី ។ យើងឲ្យគោរពដើម្បីភ្ជាប់វាឲ្យបានណែន ពីព្រោះនៅពេលបានចាប់ខ្លួនវាមក មាន៩០ភាគរយនៅតែគិតថាខ្លួនឯងជាជនបដិវត្តនៅឡើយ ។ នៅក្រោយពេលវាគោរពរូបឆ្កែនោះហើយ គេនឹងដឹងខ្លួនថាគេជាជនក្បត់មិនខាន ។ តាមជំហរសតិអារម្មណ៍ យើងបដិសេធសតិអារម្មណ៍វា ។ តាមគោលជំហរអង្គការ តើគេគោរពសន្តិបាលដែរឬទេ? វិធីៈ ត្រូវនិយាយអ្វីដែលអាចធ្វើឲ្យវាផ្លាស់ប្តូរគំនិតនិងគោរពតាម"បង" ។ បើវាតវ៉ាកុំអាលវាយវា ចាំ១នាទីសិនទើបឲ្យវានិយាយថាវាបានធ្វើការឲ្យឆ្កែទាំងពីរនេះចាប់ពីឆ្នាំណា? នៅអង្គការណា? ប្រយ័ត្នៈ វាអាចនិយាយថា សេ.អ៊ី.អា គ្មានកម្លាំងពិសពុល" ។*

"ការថ្វាយបង្គំ" តាមវិធីនេះបាននាំឲ្យអ្នកទោសស្គាល់ពីទំនាក់ទំនងអំណាចរបស់មន្ទីរស-២១ ។ វាបានបង្ហាញអំពីភាពផ្ទុយគ្នានៅក្នុងការគិតរបស់ខ្មែរក្រហមរវាង"អង្គហេតុ"ដែលត្រូវបានលាក់កំបាំង មានលក្ខណៈទាបបំផុត លក្ខណៈបរទេស និងដែលមានលក្ខណៈក្បត់ ជាមួយនឹង "ការពិត" លើសលប់របស់អង្គការដែលត្រូវបានលាក់កំបាំងប៉ុន្តែអស្ចារ្យ ហើយម្យ៉ាងទៀត រវាងអំណាចទាំងស្រុងរបស់អ្នកសួរចម្លើយនិង"ជនមានកំហុស"ដែលគ្មានអំណាចទាល់តែសោះ ។ ការធ្វើទារុណកម្មប្រភេទនេះក៏បង្ហាញនូវវិន័យក្នុងការសួរចម្លើយដែលធ្វើតាមក្រោយនិងបង្ខំឲ្យអ្នកទោសហៅខ្លួនឯងថាជនក្បត់ ។

វាហាក់ដូចជាថាអ្នកទោសប្រមាណ៩០ភាគរយចាប់ផ្តើមទទួលនូវការសួរចម្លើយដោយហៅខ្លួនឯងយ៉ាងក្លាហានថាជា "ជនបដិវត្ត" ។ អ្នកសួរចម្លើយឆ្ងល់ថាបើជាជនបដិវត្តមែនហេតុអ្វីបានជាគេចាប់ខ្លួនមក? តើគេអាចដាក់លេខរៀងនិងចាក់សោជនបដិវត្តចោលទៅរួចដែរឬ? "ការថ្វាយបង្គំ" គឺជាអំពើ

មួយក្នុងចំណោមអំពើបន្ទាបតម្លៃមនុស្សផ្សេងៗទៀតដែលធ្វើឡើងដើម្បីបង្ខំឲ្យអ្នកទោសទទួលស្គាល់ខ្លួនឯងថាជាសត្វធាតុ ។ ពាក្យចៅហ្វាយនាយបរទេសថា «អញ» ត្រូវបានចាត់ទុកថាជាសត្វ ហើយមានតែសត្វទេដែលអាចគោរពសត្វគ្នាឯង ។ នៅពេលភក្តីភាពរបស់ចៅហ្វាយនាយជាផ្នែកនិងភក្តីរបស់អ្នកទោសចំពោះចៅហ្វាយខ្លួនត្រូវបានបង្ហាញចេញមកច្បាស់ហើយនោះ អ្នកទោសត្រូវបានដកហូតអស់នូវភាពជាជនបដិវត្តនិងភាពជាមនុស្ស ហើយការសួរចម្លើយក៏ចាប់ផ្តើមជជីកសួររក «សកម្មភាពក្បត់» «ផែនការ» និង «ខ្សែក្បត់» ។ ពេលដល់ចំណុចនេះ អ្នកទោសបានក្លាយជាអស់ន័យអស់តម្លៃសុខភាពចុះទ្រុឌទ្រោមក្លាយជាសត្វសម្រាប់គេផលិតឯកសារដែលវារដើងបួនទៅរកសេចក្តីស្លាប់ ។

ដើម្បីដាក់ប្រធានបទទារុណកម្មទៅក្នុងរឿងរ៉ាវប្រវត្តិសាស្ត្រ វាហាក់ដូចជាច្បាស់ណាស់ថា «ការថ្វាយបង្គំ» ការឆក់ខ្សែភ្លើង ការជ្រមុជទឹក ការធ្វើឲ្យថប់ដង្ហើម ការវាយដំ និងទារុណកម្មតាមរូបភាពផ្សេងៗទៀតនៅមន្ទីរស-២១ វាបានលាយបញ្ចូលគ្នារវាង«គំនុំសងសឹកចំពោះបរទេស» ដែលមានលក្ខណៈជាប្រពៃណីជាមួយនឹង«ហេតុផល»និងការស្វែងរកឯកសារកំណត់ប្រវត្តិ និងភ័ស្តុតាងប្រកបដោយភាពព្រឺព្រួចពិតៗ ដែលទាំងអស់នេះនឹងប្រែក្លាយឲ្យទៅជាប្រធានបទប្រវត្តិសាស្ត្រ ។

ស្ថិតក្នុងបរិយាកាសស្ងប់ស្ងាត់និងឃោរឃៅបែបនេះ សកម្មភាពប្រឆាំងនឹងបដិវត្តន៍ទោះជា«ពិត»ឬ«មិនពិត»ក៏ដោយ គឺចាំបាច់ត្រូវតែលាតត្រដាង ហើយកំណត់ប្រវត្តិត្រូវតែសរសេរឲ្យត្រូវគ្នានឹងការសង្ស័យទុក ។ ដូច្នេះជាការពិតណាស់ «ការធ្វើនយោបាយ»ភាគច្រើនមិនបានជំរុញអ្នកសួរចម្លើយឬមិនបានបង្ហាញឲ្យឃើញអំពីកំណត់ប្រវត្តិដែលតម្រូវឲ្យមាននោះទេ ។ តើការធ្វើទារុណកម្មមានភាពគួរឲ្យជឿទុកចិត្តបានទៀតទេ? ចំណុចនេះមិនអាចនិយាយបានទេ ។ ការពិភាក្សាលើបញ្ហានេះមិនមាននៅសល់ឡើយ ។ ការអនុវត្តអំពើនេះមាននៅគ្រប់កន្លែង ។ ខ្ញុំសូមទាញហេតុផលថា ក្រោយពីបំបាត់ភាពជាមនុស្សពី«ខ្មាំង»ដែលជាទម្លាប់តែងតែមានអំពើហិង្សា និងការបណ្តោយតាមកំហឹងរបស់អ្នកសួរចម្លើយនោះ អំពើទារុណកម្មត្រូវបានសាយភាយក្នុងទ្រង់ទ្រាយធំនៅមន្ទីរស-២១ដោយមិនគិតដល់ការឈឺចាប់ ឬបើនិយាយពី«ការពិត»វិញ តម្លៃរបស់វាគឺស្មើនឹង«ការធ្វើនយោបាយដែរ» ។

## សៀវភៅកំណត់ហេតុរបស់អ្នកសួរចម្លើយ

ទំនាក់ទំនងរវាងការធ្វើទារុណកម្មនិង«ការធ្វើនយោបាយ» ដែលមន្ត្រីធ្វើការនៅមន្ទីរស-២១ចង់បាន ត្រូវបានស្តែងចេញច្បាស់តាមរយៈសៀវភៅកំណត់ហេតុសរសេរដៃមិនមានចុះហត្ថលេខា ដែលរៀបចំនៅក្នុងគុកផ្ទាល់តែម្តង ក្នុងចន្លោះខែកក្កដានិងខែកញ្ញា ឆ្នាំ១៩៧៦ ដែលមានអក្សរខៀកសរសេរនៅឆ្នាំ១៩៧៨ នៅទំព័រក្រោយគេបង្អស់ ។ សៀវភៅកំណត់ហេតុនេះអាចសរសេរឡើងដោយកម្មាភិបាលធ្វើការនៅមន្ទីរស-២១ ដែលប្រហែលជាអ្នកដែលត្រូវបានកម្ចាត់ចោលនៅឆ្នាំ១៩៧៦ ឬអាចឆ្នាំ១៩៧៧ ហើយបានបាត់ឬត្រូវគេទុកចោលអស់ពីរបីឆ្នាំក្រោយទៀត ។ នៅក្នុងទំព័រដែលមាននិយាយអំពីទារុណកម្មនិងការធ្វើនយោបាយ កំណត់ហេតុនេះសរសេរថា «យើងត្រូវគិតថាបញ្ហាទុកឲ្យ(អ្នកទោស)រស់ឬឲ្យវាសរសេរចម្លើយចេញមក ឬសម្លាប់វាចោល ទាំងអស់នេះគឺត្រូវតែសម្រេចដោយបក្ស ។ ពោលគឺយើងធ្វើអ្វីដែលយើងអាចធ្វើបានដូចជាចាំទទួលចម្លើយជាដើម ។ ការប្រើទារុណកម្មគឺជាមធ្យោបាយបន្ទាប់បន្សំទេ ។ តាមបទពិសោធន៍របស់យើងកន្លងមកជាមួយកម្មាភិបាលសួរចម្លើយគឺថា គេហាក់ដូចជាប្រកាន់យកតែការធ្វើទារុណកម្ម ។ គេផ្តោតលើការធ្វើទារុណកម្មច្រើនជាងធ្វើការឃោសនា ។ ធ្វើដូច្នេះមិនត្រឹមត្រូវទេ ។ យើងត្រូវប្រាប់ផ្លូវត្រូវដល់អ្នកទាំងនោះ» ។

កំណត់ហេតុនេះបន្តទៀតថា នៅពេលចាំបាច់ខានមិនបានហើយសឹមធ្វើ ហើយការធ្វើទារុណកម្មនេះទៀតសោតគួរតែពន្យារពេលក្នុងករណីខ្លះ ទាល់តែស្រង់យកចម្លើយសារភាពបានចប់សព្វគ្រប់ច្បាស់លាស់សិនចាំធ្វើ ។

«ខ្មាំងមិនអាចចៀសផុតពីការធ្វើទារុណកម្មទេ គ្រាន់តែថាវាតិចឬច្រើនប៉ុណ្ណោះ ។ យើងត្រូវចាត់ទុកថាទារុណកម្មគឺជាវិធានការមួយចាំបាច់ ។ ចំណែកការធ្វើនយោបាយក៏ត្រូវធ្វើដែរ ប៉ុន្តែនៅពេលដែលយើងបង្ខំឲ្យវាឆ្លើយតាមការធ្វើនយោបាយ ហើយវាមិនព្រមឆ្លើយទើបប្រើទារុណកម្ម ។ ទាល់តែយើងសង្កត់ខាងនយោបាយហើយទើបការធ្វើទារុណកម្មមានប្រសិទ្ធភាព... ។

ជាងនេះទៀត ការធ្វើនយោបាយធ្វើឲ្យអ្នកទោសឆ្លើយបានច្បាស់លាស់ ទោះជាត្រូវ ឬមិនត្រូវធ្វើទារុណកម្មតាមក្រោយក៏ដោយចុះ” ។

ខាងលើនេះបញ្ជាក់ថាទារុណកម្មគួរតែប្រើហើយក្លាយជាវិធានការដ៏មាន“ប្រសិទ្ធភាព”ទៀតផង ក្រោយពីស្រង់យកចម្លើយសារភាពចប់សព្វគ្រប់ហើយ ដែលប្រហែលជាការទទួលស្គាល់ថាអ្នកធ្វើការនៅមន្ទីរស-២១ចាំតែធ្វើទារុណកម្មលើអ្នកទោសក្នុងកម្រិតណាមួយ ហើយថាប្រហែលជាទារុណកម្មខ្លះ ដែលធ្វើឡើងក្នុងលក្ខណៈជាការពិសោធន៍ទិសថសាស្ត្រអាចមានលក្ខណៈសមស្របជាងគេទាំងអស់ នៅពេលការធ្វើឯកសារត្រូវបានបញ្ចប់សព្វគ្រប់អស់ហើយ ។ មិនតែប៉ុណ្ណោះសោត នេះក៏បញ្ជាក់ដែរថា អ្នកទោសដែលត្រូវទទួលរងនូវអំពើទារុណកម្មអាចជារង្វាន់បន្ថែមសម្រាប់អ្នកធ្វើការនៅមន្ទីរស-២១ ក្រោយពីខ្លួនបានចម្លើយរួចរាល់អស់ហើយ ។ ថាតើពាក្យ“ប្រសិទ្ធភាព”មានន័យយ៉ាងណានោះ ក៏នៅតែមិនច្បាស់នៅឡើយទេ ។ ម្យ៉ាងវិញទៀត អ្នកសួរចម្លើយមិនត្រូវបានដាក់ទណ្ឌកម្មអ្វីឡើយ ទោះបីជាធ្វើឲ្យអ្នកទោសឈឺចាប់យ៉ាងណាក៏ដោយ វៀរលែងតែអ្នកទាំងនោះធ្វើឲ្យអ្នកទោសបាត់បង់ជីវិត ។ សៀវភៅកំណត់ហេតុមានព្រលយពាក្យទាក់ទងនឹងវិធីសាស្ត្រដែលអ្នកសួរចម្លើយអាចយកមកឃោសនា លួងលោម និងសម្រួលចិត្តអ្នកទោសដោយមិនចាំបាច់ធ្វើទារុណកម្ម ។ សៀវភៅនេះសរសេរទៀតថា “គោលបំណងមួយក្នុងការធ្វើទារុណកម្មគឺត្រូវរកចម្លើយពីវា ហើយត្រូវធ្វើចិត្តឲ្យរីករាយ...មិនត្រូវធ្វើទាំងកម្រោលនិងក្តៅក្រហាយទេ ។ ការវាយគឺសម្រាប់ធ្វើឲ្យវាភ័យតែប៉ុណ្ណោះ ប៉ុន្តែតាមពិតមិនសម្លាប់ទេ ។ នៅពេលណាក៏ដោយឲ្យតែវាយវា ត្រូវកុំភ្លេចពិនិត្យមើលសុខភាពវាឲ្យស្រួលបួលជាមុនសិន ហើយពិនិត្យរំពាត់ទៀតផងតើត្រូវយកធំឬតូច ។ កុំស្ទុះទៅរកតែសម្លាប់ភ្លាមឲ្យសោះ” ។

ទារុណកម្មនៅមន្ទីរស-២១ វិចិត្រករៈ វ៉ាន់ ណាត អតីតអ្នកទោសនៅមន្ទីរស-២១



សារនេះបញ្ជាក់ថា អ្នកទោសដែលត្រូវបានធ្វើទារុណកម្មធ្វើឲ្យអ្នកសួរចម្លើយមួយចំនួន “រីករាយ” ចំណែកអ្នកផ្សេងទៀតធ្វើឡើងទាំង“ក្តៅក្រហាយ” ឬរកតែសម្លាប់“ខ្មាំង”របស់បក្ស ។ មិនតែប៉ុណ្ណោះសោត ប្រសិនបើរំពាត់នោះមានលក្ខណៈអាចទទួលយកបានហើយ ការវាយទៅលើអ្នកទោសដែលមានសុខភាពមាំទាំរហូតជិតស្លាប់ គឺត្រូវបានចាត់ទុកថាជាការត្រឹមត្រូវ ។ អំពើឃោរឃៅរបៀបនេះស្តាប់ទៅមិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលទេ ដោយសារតែការបំបាត់ភាពជាមនុស្សរបៀបនេះកើតមានឡើងទូទៅនិងជាវប្បធម៌របស់គុកទៅហើយ ។ ប៉ុន្តែពេលនៅពេលរឿងទាំងអស់នេះត្រូវបានយកមកសរសេរយ៉ាងលម្អិតហើយមិនលម្អៀងទៀតនោះ មើលទៅគួរឲ្យញាក់សាច់មែនទែន ។ នៅពេលដឹងខ្លួនថាខ្លួនឯងធ្វើជ្រុលដៃហើយនោះ ក៏បានសរសេរថយបន្តិចមកវិញថា÷

“ត្រូវតែដឹងថាធ្វើនយោបាយគឺវាសំខាន់ចាំបាច់ណាស់ ។ ចំណែកឯការធ្វើទារុណកម្មវិញ គ្រាន់តែជារឿងបន្ទាប់បន្សំប៉ុណ្ណោះ ។ នយោបាយតែងតែនាំមុខគេជានិច្ច ។ សូម្បីតែនៅពេលធ្វើទារុណកម្មក៏យ៉ាងអីចឹងដែរ ត្រូវតែឃោសនាឲ្យជាប់ជានិច្ច” ។

**(នៅមានត)**

# កាំភ្លើងធំសំណល់ពីការទម្លាក់គ្រាប់



លោកអ៊ឹ ផ្យស ប្រៃ

# បែកនៅប៉ុស្តិ៍ដាក់ដាំ



និយាយដល់ការទម្លាក់គ្រាប់បែកនៅខេត្តមណ្ឌលគិរី ធ្វើឲ្យខ្ញុំនឹកឃើញនូវព្រឹត្តិការណ៍មួយដែលបានកើតមានចំពោះប៉ុស្តិ៍ដាក់ដាំដែលត្រូវទទួលរងនូវការទម្លាក់គ្រាប់បែកយ៉ាងធ្ងន់ធ្ងរនៅក្នុងខេត្តនេះកាលពីឆ្នាំ១៩៦៩ ។ ឃុំដាក់ដាំស្ថិតនៅក្នុងស្រុកអូររាំង ខេត្តមណ្ឌលគិរី ភូមិភាគឦសាន ជាប់នឹងព្រំប្រទល់ប្រទេសវៀតណាម ។ ក្នុងអំឡុងពេលសង្គ្រាមវៀតណាម ខេត្តមណ្ឌលគិរីស្ទើរតែទាំងមូលត្រូវទទួលរងគ្រោះដោយការទម្លាក់គ្រាប់បែកបេ-៥២ ហើយស្រុកអូររាំង ទទួលក៏រងការទម្លាក់គ្រាប់បែកយ៉ាងធ្ងន់ធ្ងរដែរ ។ មនុស្សជាច្រើននាក់ត្រូវស្លាប់បាត់បង់ជីវិត និងមនុស្សមួយចំនួនត្រូវរងរបួស ផ្ទះ សម្បែង សម្ភារប្រើប្រាស់និងសម្ភារយោធាមួយចំនួនទៀតត្រូវខូចខាត ដោយសារការទម្លាក់គ្រាប់បែកបេ-៥២ ។

លោកអ៊ឺ ផ្សេស ប្រៃ អាយុ ៥២ឆ្នាំ ជនជាតិព្នង បច្ចុប្បន្នជាប្រធានឃុំដាក់ដាំ ដែលធ្លាប់បានឆ្លងកាត់ហេតុការណ៍នាពេលនោះបានឲ្យដឹងថា នៅប៉ុស្តិ៍ដាក់ដាំ នៅពេលមានការទម្លាក់គ្រាប់បែកក្នុងឆ្នាំ១៩៦៩ មានមនុស្សចំនួន៤០នាក់ ត្រូវបាត់បង់ជីវិត ។ ក្នុងចំណោមមនុស្សដែលស្លាប់ មានទាហាន៣០នាក់ស្លាប់ក្នុងរណ្តៅតែមួយរួមគ្នា ទាហានបាញ់កាំភ្លើងធំ៦នាក់បានស្លាប់ក្នុង

ពេលដែលយន្តហោះទម្លាក់គ្រាប់កម្ទេចទីតាំងកាំភ្លើងធំ និងមនុស្ស៤នាក់ផ្សេងទៀតជាប្រជាជន។ ក្រៅពីការបាត់បង់ជីវិតមនុស្ស អគារសិក្សានៃសាលាបឋមសិក្សាដាក់ដាំមួយខ្នង រថយន្ត និងសម្ភារយោធាមួយចំនួនធំ ត្រូវខូចខាត។

ខាងក្រោមនេះជាការរៀបរាប់និងការណែនាំដោយសង្ខេបអំពីពីប្រភេទកាំភ្លើងធំមួយគ្រឿងសម្រាប់បាញ់យន្តហោះដែលត្រូវទទួលរងនូវការកម្ទេចដោយការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកនៅឆ្នាំ១៩៦៩ បន្សល់ទុកនៅអតីតប៉ុស្តិ៍ដាក់ដាំស្ថិតនៅក្នុងឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី។ កាំភ្លើងនេះជាប្រភេទកាំភ្លើងបាញ់យន្តហោះ ម៉ាកអឹម ១០២ ធុន១០៥ មីលីម៉ែត្រ។

កាណុងកាំភ្លើងនេះមានទំហំមុខកាត់ ១០៥ មីលីម៉ែត្រ ប្រវែងកាណុងៈ ២,៥៧ ម៉ែត្រ ទម្ងន់ៈ ១៩៣៨ គីឡូក្រាម កម្រិតកម្ពស់ៈ ពីដក៦(-៦)ដឺក្រេ ទៅបូក៦៥(+៦៥)ដឺក្រេ កម្រិតទទឹងៈ ៤៦ ដឺក្រេ រយៈចម្ងាយៈ ១១៤៣០ម៉ែត្រ កម្រិតល្បឿនៈ ៤៧២ ម៉ែត្រក្នុងមួយវិនាទី។

កាំភ្លើងធំម៉ាកអឹម១០២ ធុន១០៥ មីលីម៉ែត្រ ជាកាំភ្លើងប្រភេទអឹម២ថ្មី ដែលត្រូវបានយកមកប្រើប្រាស់នៅប្រទេសវៀតណាមក្នុងពេលមានសង្គ្រាម។ កាំភ្លើងនេះតែងតែដឹកជញ្ជូនតាមឧទ្ធម្ភាគចក្រ។ កាំភ្លើងនេះអាចដាក់ឲ្យដំណើរការនៅក្នុងមូលដ្ឋានកាំភ្លើងធំថ្មីមួយ ដោយត្រូវឈូសឆាយដីធ្វើជាខឿននិងដាក់បាវដីខ្សាច់ព័ទ្ធជុំវិញ។

កាំភ្លើងធំធុន ១០៥មីលីម៉ែត្រ អាចត្រូវស្ទូចដោយឧទ្ធម្ភាគចក្រ ដាក់ចូលទៅក្នុងមូលដ្ឋានកាំភ្លើងធំលើកំពូលភ្នំមួយក្បែរទីតាំងជាប់ព្រំប្រទល់។ អ្វីៗទាំងអស់សម្រាប់មូលដ្ឋានកាំភ្លើងដាច់ស្រយាលនេះ ត្រូវតែស្ទូចដោយឧទ្ធម្ភាគចក្រដាក់ចូលទៅក្នុង និងលើកចេញក្រៅ។ ជាបណ្តើរៗ សំណុំនៃកាំភ្លើងធំ គ្រាប់រំសេវ និងឧបករណ៍ដទៃទៀត ក្លាយជាជម្រកអ្នកកាន់កាំភ្លើងធំទាំងនោះ។

គម្របខ្លីនៃកន្លែងបាញ់វិលត្រូវបានផ្តល់ដោយគ្រាប់កាំភ្លើងត្បាល់។ នៅពេលដែលទីតាំងមួយត្រូវបានសម្អាតកាំភ្លើងធុន១០៥មីលីម៉ែត្រនេះត្រូវបានស្ទូចដាក់ដោយឧទ្ធម្ភាគចក្រ។ ដោយបង្កើតបាននូវមូលដ្ឋានកាំភ្លើងធំមួយ អង្គភាពប្រតិបត្តិការអាចចេញទៅតាមតំបន់ជុំវិញ ដើម្បីស្រាវជ្រាវរកនិងកម្ទេចអង្គភាពប្រតិបត្តិការអាចរំពៃមើលសត្រូវនៅតាមជនបទ រហូតទាល់តែរកឃើញទីតាំងរបស់សត្រូវ។

បន្ទាប់មកអង្គភាព ប្រតិបត្តិការអាចទាក់ទងតាមដែនទីហើយទាក់ទងទៅខាងកាំភ្លើងធំឲ្យបាញ់ស្កាត់។ កាំភ្លើងធំធុន ១០៥មីលីម៉ែត្រ អាចផ្លាស់ប្តូរបាននៅក្នុងសមរភូមិសម្រាប់ឲ្យអ្នកកាន់កាំភ្លើងធំប្រើតាមល័ក្ខខ័ណ្ឌភូមិសាស្ត្រនៃដីខ្ពង់រាប។ កាំភ្លើងធំធុន១០៥ មីលីម៉ែត្រ អាចសណ្តោងដោយរថយន្ត ប៉ុន្តែជាធម្មតានៅវៀតណាម កាំភ្លើងនេះត្រូវបានស្ទូចដោយឧទ្ធម្ភាគចក្រ។ យើងអាចលើកឡើងដាក់លើកំពូលភ្នំមួយក្នុងព្រៃស្បាត ដោយប្រើងប្រែងអស់ពីសមត្ថភាពហើយអាចធ្វើការវាយប្រហារនៅពេលណាក៏បាន។ វាជាការល្អដែលថាយើងមានមូលដ្ឋានកាំភ្លើងធំដើម្បីគាំទ្រអាចបាញ់ផ្តត់កាំភ្លើងធុន១០៥មីលីម៉ែត្រនៅក្នុងប៉ុន្មាននាទីដោយការហៅតាមបណ្តាញវិទ្យុទាក់ទង។

ការបញ្ជាឲ្យបាញ់ផ្តត់ចែកចេញជាបួនដំណាក់កាលៈ

១) ចំណុចជាក្រុមមួយកំពុងមានបញ្ហា។ អ្នកសង្កេតការណ៍ខាងមុខបានណែនាំមន្ត្រីវិទ្យុទាក់ទងរបស់ខ្លួនឲ្យបញ្ជូនព័ត៌មានអំពីទីតាំងនិងចម្ងាយមកទីតាំងកាំភ្លើងធំវិញ។

២) ផ្នែកខាងមូលដ្ឋានគាំទ្រកាំភ្លើងធំ មជ្ឈមណ្ឌលទីតាំងកាំភ្លើងធំត្រូវត្រួតពិនិត្យនូវការគណនាអំពីប្រតិបត្តិការកាំភ្លើងធំជាបន្ទាន់ លើក្តារគម្រោងសម្រាប់វាស់វែង បន្ទាប់មកកំណត់នូវរយៈកម្ពស់និងចំណាំងផ្លាតពិតប្រាកដទៅឲ្យកងកាំភ្លើងធំ។

៣) បន្ទាប់ពីមានសញ្ញាផ្សេងមូលដៅចំណុចស៊ីបក្នុងកាំភ្លើងធំ១០៥មីលីម៉ែត្រ ទាហាន៧នាក់បញ្ចូលគ្រាប់កាំភ្លើងទៅក្នុងប្រហោងដាក់គ្រាប់កាំភ្លើងចាប់ផ្តើមបាញ់កម្ទេចទីតាំងដែលនៅឆ្ងាយនោះ។

៤) បន្ទាប់ពីការបាញ់ស្កាត់យ៉ាងខ្លាំងក្លាដោយកាំភ្លើងធំរួចមក ឧទ្ធម្ភាគចក្រដែលបំពាក់ដោយកាំភ្លើងយន្តហោះ សំដៅទៅទីតាំងនៃគោលដៅដើម្បីធ្វើទុក្ខបុកម្នេញឲ្យសត្រូវដកថយ។

**ថ្លង សុភារិទ្ធ**

# ហ៊ឹម ហ៊ុយ ចង់បានយុត្តិធម៌




ហ៊ុម ហ៊ុយ បាន និយាយថា "ខ្ញុំនឹងទៅឆ្លើយបំភ្លឺនៅក្នុងសវនាការជំនុំជម្រះក្តីអំពើឧក្រិដ្ឋកម្មដែលខ្ញុំបានប្រព្រឹត្តចំពោះអ្នកទោសនៅគុកទួលស្លែង" ។ កាលពី២៥ឆ្នាំមុន ហ៊ុយ មានតួនាទីជាអនុប្រធានកងការពារអ្នកទោសនៅមន្ទីរស-២១(គុកទួលស្លែង) ។ គាត់និយាយបន្តថា "ខ្ញុំមិនចង់ធ្វើអ្វីខុសទេប៉ុន្តែមកពីពួកគេ (ឌុច និង ហ៊ី) ជាអ្នកគាបសង្កត់ខ្ញុំឲ្យបម្រើការងាររបស់គេ" ។

នៅឆ្នាំ១៩៧៧ ហ៊ុយ បានបម្រើការជាយុទ្ធជនកងការពារមន្ទីរស-២១ ។ នៅឆ្នាំ១៩៧៨ ឃឹម វ៉ាត ហៅ ហ៊ី អនុប្រធានមន្ទីរស-២១បានចាត់តាំង ហ៊ុយ ឲ្យធ្វើជាអនុប្រធានកងការពារមន្ទីរស-២១ ។ នៅមន្ទីរស-២១ ហ៊ុយ បានបំពេញតួនាទីសំខាន់ៗដូចជា ចុះទៅចាប់អ្នកទោសយាមអ្នកទោស និងបញ្ជូនអ្នកទោសពីមន្ទីរស-២១ទៅសម្លាប់នៅវាលពិឃាតបឹងជើងឯក ។ ហ៊ុយ បានសារភាពថា គាត់ធ្លាប់សម្លាប់អ្នកទោសចំនួន៥នាក់គត់ដោយវាយនឹងដែកក្បៀរទេះ ។

ហ៊ុយ បានរំឭកឡើងវិញពីមូលហេតុដែលនាំឲ្យគាត់ហ៊ានសម្លាប់អ្នកទោសទាំង៥នាក់ថា នៅពេលដឹកអ្នកទោសទៅដល់ជើងឯក ហ៊ី បានសួរ "ហ៊ុយ ឯងដាច់ខាតឬមិនដាច់ខាត?" ។ ហ៊ុយ និយាយថា ខ្ញុំត្រូវបង្ខំចិត្តឆ្លើយ"ដាច់ខាត" ពីព្រោះបើខ្ញុំមិនដាច់ខាតគេសង្ស័យថា"ខ្មាំង" ហើយគេនឹងយកខ្ញុំទៅសម្លាប់ ។ "គេមិនសម្លាប់តែខ្ញុំម្នាក់ទេ គេនឹងបន្តស្រាវជ្រាវរកបងប្អូនខ្ញុំទាំងអស់យកទៅសម្លាប់" ។ ហ៊ុយ និយាយទៀតថា ឌុច ក៏ធ្លាប់បញ្ជាគាត់ឲ្យសម្លាប់អ្នកទោស ។ ឌុច ជាជនបដិវត្តន៍ដ៏កាចសាហាវ ។ ឌុច ធ្លាប់បញ្ជាឲ្យឆ្មាំមន្ទីរស-២១ ចាប់ប្អូនថ្លៃរបស់ខ្លួនចំនួនពីរនាក់យកទៅសម្លាប់ចោល ។

ហ៊ុយ បានរៀបរាប់ពីដំណើរការបញ្ជូនអ្នកទោសពីមន្ទីរស-២១ និងរបៀបសម្លាប់អ្នកទោសនៅវាលពិឃាតបឹងជើងឯកថា អ្នកទោសត្រូវដាក់ខ្នោះដៃនិងចងមុខដោយក្រណាត់ខ្មៅនៅមុនពេលបញ្ជូនយកទៅសម្លាប់ ។ នៅពេលទៅដល់វាលពិឃាតបឹងជើងឯក កងសន្តិសុខត្រូវដាក់អ្នកទោសចុះពីឡានបញ្ចូលទៅក្នុងផ្ទះ ហើយចាប់ផ្តើមឲ្យ"ពួកសម្លាប់អ្នកទោស"បណ្តើរអ្នកទោសចេញម្តងមួយៗ ។ ហ៊ុយ មានភារកិច្ចកត់ឈ្មោះអ្នកទោសដោយផ្ទៀងផ្ទាត់តាមចំនួនអ្នកទោស ។ បញ្ជីឈ្មោះអ្នកទោសត្រូវបញ្ជូនទៅឲ្យ សួស ធី ជាកម្មាភិបាលផ្នែកឯកសារនៃមន្ទីរស-២១ ។ អ្នកទោសដែលបានហៅឈ្មោះត្រូវនាំយកទៅអង្គុយលុតជង្គង់នៅខាងមុខរណ្តៅដែលជីករួចជាស្រេច ។ ហ៊ុយ បាននិយាយថា "គេវាយនិងអារ-កអ្នកទោសរួចហើយ ទើបដោះខ្នោះដៃរុញទម្លាក់ទៅក្នុងរណ្តៅ" ។ តេង ជាអ្នកមើលការខុសត្រូវចំពោះការសម្លាប់អ្នកទោសនៅវាលពិឃាតបឹងជើងឯក ។ តេង បានទទួលតួនាទីជាអ្នកគ្រប់គ្រងលើយុទ្ធជនមួយក្រុមនៅទីនោះ ។

មន្ទីរស-២១ជាមន្ទីរឃុំឃាំងថ្នាក់មជ្ឈិមដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការស្វែងរកចម្លើយនិងកម្ទេច"ខ្មាំង"ទាំងខាងក្នុងនិងខាងក្រៅ ដែលមានផែនការបំផ្លិចបំផ្លាញបក្សកុម្មុយនិស្តកម្ពុជា ។ ឌុច ប្រធានមន្ទីរស-២១បានមើលការខុសត្រូវប្រចាំថ្ងៃ នូវដំណើការប្រព្រឹត្តទៅរបស់មន្ទីរស-២១ និងសាខារបស់មន្ទីរស-២១ ។ ហ៊ី មានតួនាទីជាអនុប្រធានមន្ទីរស-២១ ដែលនៅមើលការខុសត្រូវបន្ទាប់ពី ឌុច ។ នុន ហ៊ុយ ហៅ

ហ៊ុយ ស្រែ ជាប្រធានមន្ទីរស-២១យ ជាសាខាមួយរបស់មន្ទីរ ស-២១ ។

នៅខែមេសា ឆ្នាំ១៩៧៧ ហ៊ុយ ស្រែ បានធ្វើបញ្ជីអ្នកទោសស្ត្រីមានផ្ទៃពោះចំនួន១១នាក់ដែលនឹងត្រូវកម្ទេច បញ្ជូនទៅមន្ទីរស-២១ ។ នៅត្រង់ផ្នែក“ឋាតុភាពផ្សេងៗ” ហ៊ុយ ស្រែ បានសរសេរអក្សរដៃបញ្ជាក់នៅខាងមុខឈ្មោះនីមួយៗថា “ជិតឆ្លងទន្លេ”មានចំនួន៨នាក់ និង“អគ្គការកម្ទេច”មានចំនួន៣នាក់ ។ នៅត្រង់ផ្នែកខាងក្រោម ហ៊ុយ ស្រែ បានសរសេរថា “ក្នុងនេះមានកុមារតូចៗខ្លះផង” ។

យន្តការចាប់និងសម្លាប់អ្នកទោសនៅមន្ទីរស-២១ ស្ថិតនៅក្រោមការត្រួតពិនិត្យយ៉ាងជិតដល់របស់សេនាធិការកងទ័ពខ្មែរក្រហម ។ យោងតាមសេចក្តីសម្រេចនៃការប្រជុំគណៈអចិន្ត្រៃយ៍នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ សុន សេន បានទទួលបន្ទុកសេនាធិការនិងសន្តិសុខ ។ ក្រៅពី សុន សេន, នួន ជា គឺជាបុគ្គលដែលមានតួនាទីធំបង្គួរក្នុងការសម្រេចជោគវាសនាអ្នកទោសនៅមន្ទីរស-២១ ។

ដោយមើលឃើញពីភាពលំបាកវេទនានិងការសម្លាប់ជាបន្តបន្ទាប់ ហ៊ុយ បានឡើងសុំការអនុញ្ញាតពី សុន សេន ចេញពីមន្ទីរស-២១ ដើម្បីត្រឡប់ទៅបម្រើនៅក្នុងអគ្គភាពកងទ័ពវិញ ។ សំណូមពររបស់ ហ៊ុយ ត្រូវបាន សុន សេន បដិសេធ ។ នៅមុនពេលចូលមកបម្រើការនៅមន្ទីរស-២១ ហ៊ុយ មានតួនាទីជាប្រធានក្រុមនៃកងវរសេនាតូចពិសេសលេខ៧០៤ កងពលលេខ ៧០៣ ។ ហ៊ុយ បាននិយាយថា សុន សេន ធ្លាប់ទៅបង្រៀនវគ្គនយោបាយនិងលក្ខន្តិកៈបក្សដល់យុទ្ធជន និងកម្មាភិបាលនៅមន្ទីរស-២១ ។

ហ៊ុយ បានហៅមន្ទីរស-២១ថាជា“កន្លែងចូលហើយគ្មានថ្ងៃចេញ” ។ មិនចំពោះតែអ្នកទោសទេ សូម្បីយុទ្ធជននិងកម្មាភិបាលដែលបម្រើការនៅមន្ទីរស-២១មួយចំនួនក៏មានវាសនាដូចគ្នាដែរ ។ ចាប់តាំងពីឆ្នាំ១៩៧៧ កម្មាភិបាលនៅមន្ទីរស-២១មួយចំនួនត្រូវចាប់ខ្លួននឹងយកទៅសម្លាប់ជាបន្តបន្ទាប់ ។ ការសម្លាប់កម្មាភិបាលមន្ទីរស-២១ បានចាប់ផ្តើមកើតឡើងទន្ទឹមនឹងការប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហមនិងកងទ័ពវៀតណាមនៅតាមព្រំដែន ។ ហ៊ុយ និយាយថា យុទ្ធជនអង្គភាពកងការពារអ្នកទោសមានចំនួនជាង២០០នាក់ មកដល់ចុងឆ្នាំ១៩៧៨ នៅសល់ប្រមាណ៥០នាក់តែប៉ុណ្ណោះ ។ គាត់បានបញ្ជាក់ថា មូលហេតុនៃការចាប់និងសម្លាប់កម្មាភិបាលនៅមន្ទីរស-២១ ដោយសារកម្មាភិបាលទាំងនោះត្រូវ“ខ្មាំងឆ្លើយដាក់” ។

ហ៊ុយ និយាយថា “ជារៀងរាល់ថ្ងៃខ្ញុំខ្វល់ខ្វាយខ្លាចគេឆ្លើយដាក់ ។ បើគេឆ្លើយដាក់ គេនឹងចាប់យើងដាក់គុក” ។ ហ៊ុយ បានរំឭកឈ្មោះមនុស្សជាច្រើននាក់ដែលធ្លាប់បម្រើការនៅក្នុងកងពលលេខ៧០៣ជាមួយគាត់ ។ មនុស្សដែលគាត់រំឭកឡើងវិញសុទ្ធសឹងតែត្រូវបានចាប់ខ្លួននិងសម្លាប់នៅមន្ទីរស-២១ ។ មនុស្សទាំងអស់នេះហើយដែលធ្វើឲ្យគាត់មានការព្រួយបារម្ភពីព្រោះគាត់ខ្លាចមនុស្សទាំងអស់នេះឆ្លើយដាក់ថា គាត់ជាប់ពាក់ព័ន្ធខ្សែរយៈក្បត់ជា សេ.អ៊ី.អា និងសន្តិសម្ព័ន្ធ ។

កម្មាភិបាលមន្ទីរស-២១ដែលត្រូវចាប់ខ្លួនដោយសារខ្មាំងឆ្លើយដាក់មានដូចជា ណុប នួន, គី ជន, ស្លួន, ដូ និង ប៉ូច ។ ឌុច បានបញ្ជាឲ្យចាប់ខ្លួននិងសម្លាប់កម្មាភិបាលទាំងអស់នេះ ។ ចម្លើយសារភាពរបស់អ្នកទោសទាំង៥នាក់នេះបានតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ហ៊ុយ និយាយថា មនុស្សទាំង៥នាក់ខាងលើគឺជាមនុស្សដែលគាត់មានការរាប់អានស្និទ្ធស្នាលដូច្នេះហើយទើបធ្វើឲ្យគាត់កាន់តែមានការព្រួយបារម្ភខ្លាំងឡើងៗ ។

នៅឆ្នាំ១៩៧៣ ហ៊ុយ បានចូលបម្រើកងទ័ពបដិវត្តន៍ ។ ក្នុងខណៈពេលបម្រើការនៅមន្ទីរស-២១ ហ៊ុយ បានធ្វើប្រវត្តិរូបសង្ខេបចំនួន៩ទំព័រ ។ ហ៊ុយ បានសរសេរនៅក្នុងឯកសារប្រវត្តិរូបបញ្ជាក់អំពីមូលហេតុដែលនាំឲ្យគាត់ចូលបម្រើបដិវត្តន៍ថា “ខ្ញុំចូលបដិវត្តមកពីខ្ញុំមានការឈឺចាប់នឹងពួកអាណានិគមនិយមចាស់ថ្មី និងពួកនាយទុន សក្តិភូមិ ប្រតិកិរិយា ចក្រពត្តិ ដែលជិះជាន់ឈ្លានពានធ្វើបាបប្រជាជន ។ មូលហេតុដូច្នេះហើយបានជាយើងខ្ញុំមានស្មារតីភ្ញាក់រឭកមកចូលរួមក្នុងជួរបដិវត្ត បម្រើបដិវត្ត វាយចក្រពត្តិអាមេរិក រំដោះវណ្ណៈ រំដោះប្រជាជន” ។

បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមនៅឆ្នាំ១៩៧៩ ហ៊ុយ ត្រូវបានគណៈកម្មាធិការស្រុកកោះធំ ហៅយកទៅអប់រំ

រៀនសូត្ររស់រយៈពេលជាងមួយឆ្នាំពីបទជាប់ពាក់ព័ន្ធនឹងរបបខ្មែរក្រហម ។ ហ៊ុយ បានវិលត្រឡប់មករស់នៅជួបជុំប្រពន្ធនិងកូនវិញ បន្ទាប់ពីត្រូវបានដោះលែងពីមន្ទីរឃុំឃាំងស្រុកកោះធំ ។

ហ៊ុយ តែងតែនិយាយដដែលៗអំពីការងាររបស់គាត់នៅមន្ទីរស-២១ថា "ខ្ញុំធ្វើនេះគឺធ្វើដើម្បីរស់ ។" "រឿងនេះខ្ញុំមិនមែនជាអ្នកទទួលខុសត្រូវទេ ព្រោះគេបញ្ជាលើខ្ញុំ ។ បើខ្ញុំមិនធ្វើគេសម្លាប់ខ្ញុំ" ។ គាត់និយាយថា ប្រសិនបើគាត់ហ៊ានរត់ ឌុច នឹងសម្លាប់ឪពុកម្តាយនិងបងប្អូនគាត់ ។ ហ៊ុយ និយាយដោយម៉ឺងម៉ាត់ថា គាត់នឹងឡើងឆ្លើយបំភ្លឺជាសាធារណៈ នៅពេលដែលដំណើរការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមត្រូវការរូបគាត់ ។

ឆន្ទៈរបស់ ហ៊ុយ មានភាពដូចគ្នាទៅនឹងមេដឹកនាំខ្មែរក្រហមកំពូលៗមួយចំនួន ។ ថ្មីៗនេះ សួង ស៊ីគឿន អ្នកនាំពាក្យចលនាបគ្រួបបង្រួមជាតិប្រជាធិបតេយ្យបាននិយាយជាសាធារណៈនៅក្នុងវិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិក ក្នុងបំណងទាមទារឲ្យបង្កើតតុលាការការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ។

សួង ស៊ីគឿន បាននិយាយថាគាត់ចង់ឲ្យតុលាការវិនិច្ឆ័យទោសចំពោះអតីតមេដឹកនាំខ្មែរក្រហម ដើម្បីឲ្យមានភាពជ្រះស្រឡះអំពីអតីតភាពរបស់គាត់ ។ ក្នុងពេលជាមួយគ្នា សួង ស៊ីគឿន បាននិយាយដកស្រង់សម្តី អៀង សារី អតីតរដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបខ្មែរក្រហមថា "អៀង សារី ត្រៀមខ្លួននឹងឡើងឆ្លើយបំភ្លឺនៅក្នុងសវនាការជំនុំជម្រះក្តី" ។

នៅពេលថ្មីៗនេះ ដាន ថនចាន់ អតីតអ្នកទោសម្នាក់ទៀតនៅមន្ទីរស-២១ បានទទួលមរណភាពនៅក្នុងមន្ទីរពេទ្យឯកជនមួយក្នុងទីក្រុងភ្នំពេញ ។ មរណភាពរបស់ ដាន ថនចាន់ បានធ្វើឲ្យ វ៉ាន់ ណាត និង ជុំ ម៉ាញ ដែលជាអតីតអ្នកទោសនៅមន្ទីរស-២១ដែរនោះ មានការរន្ធត់ចិត្តយ៉ាងខ្លាំង ។ វ៉ាន់ ណាត និង ជុំ ម៉ាញ បាននិយាយថា គាត់នៅតែទន្ទឹងរង់ចាំយុត្តិធម៌ ។ គាត់ចង់ឃើញការជំនុំជម្រះទោសមេដឹកនាំខ្មែរក្រហមនៅមុនពេលគាត់ស្លាប់ ។

កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០២ កែ ពក អាយុ ៧២ឆ្នាំ អតីតលេខាភូមិភាគឧត្តរនិងជាសមាជិកគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជា បានស្លាប់នៅអន្លង់វែងដោយសារជំងឺដាច់សរសៃឈាមក្នុងខួរក្បាល ។ កែ ពក បានស្លាប់នៅក្នុងខណៈពេលដែលអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាកំពុងមានភាពមិនចុះសម្រុង ចំពោះការបង្កើតតុលាការជំនុំជម្រះទោសមេដឹកនាំខ្មែរក្រហម ។ កែ ពក ជាបុគ្គលម្នាក់ក្នុងចំណោមមេដឹកនាំកំពូលនៃរបបខ្មែរក្រហម ដែលត្រូវទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋកម្មដែលកើតឡើងក្នុងអំឡុងពេលកាន់អំណាចនៃរបបខ្មែរក្រហម ។

ការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោសគឺជាការផ្តល់យុត្តិធម៌ពិតប្រាកដដល់ជនរងគ្រោះនិងជនដែលរស់ ។ ដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងក្លាយទៅជាគំរូដល់មេដឹកនាំជំនាន់ក្រោយ ហើយធ្វើឲ្យប្រទេសកម្ពុជាមានការអភិវឌ្ឍប្រកបដោយចីរភាព ។ ការខកខានមិនបាននាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោសនឹងធ្វើឲ្យយុត្តិធម៌មិនអាចមានសម្រាប់ប្រជាជនកម្ពុជាជារៀងរហូត ហើយប្រវត្តិសាស្ត្រខ្មែរនឹងត្រូវដឹកកប់ដោយជនអន្ធពាល ។ **ហ៊ុយ វណ្ណៈ**

## ពន្យល់ពាក្យខ្មែរក្រហម

◆ ***យោធាបដិវត្តល្អៈ*** យោធាដែលបំពេញភារកិច្ចគ្រប់មុខបានល្អ ដោយគ្មានលក្ខខណ្ឌ ពេលមាន ពេលអត់ ពេលស្រួល ពេលលំបាក ពេលឈ្នះ ពេលចាញ់ជាបណ្តោះអាសន្ន ពេលឈ្នះទាំងស្រុង ចូលទីក្រុងក៏គ្មានលក្ខខណ្ឌ ។

***(កំណត់ហេតុលេខ ១៨៥)***

សូមសរសេរលិខិត
ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហមមកកាន់
**ទស្សនាវដ្តី "ស្វែងរកការពិត"**
ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ឬតាមទូរសារលេខៈ (៨៥៥) (២៣) ២១០៣៥៨
ឬ Email: dccam@bigpond.com.kh

# តុលាការនៅទីម័រខាងកើតៈ
# ក្រុមប្រឹក្សាអ្នកច្បាប់ពិសេសខាងព្រហ្មទណ្ឌកម្រិតធ្ងន់

## (តពីលេខមុន) ១) ការចាប់ផ្តើមដំបូង

ច្បាប់លេខ២០០០/១៥ ត្រូវបានអនុម័តឡើងដោយគ្មានអមដោយថវិកាសម្រាប់ចំណាយក្នុងគម្រោងព្រហ្មទណ្ឌកម្រិតធ្ងន់ ។ ទោះជាយ៉ាងនេះក៏ដោយ កិច្ចការត្រូវបានសង្ឃឹមថានឹងចាប់ផ្តើមយ៉ាងឆាប់បំផុត ។ កាលនោះមានជួបបញ្ហាលំបាកយ៉ាងខ្លាំងក្នុងការ“ក្រោកយកអេឡង់រត់” ដោយគ្មានទាំងគ្រឿងសម្ភារបុគ្គលិក ឬបរិវេណការិយាល័យ (បុគ្គលិកនិងសម្ភារខ្លីមកពីមន្ទីរផ្សេងៗ) ។ មានទំនាស់ទៅលើបញ្ហាថាតើមន្ទីរណាខ្លះរបស់រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើតដែលទទួលខុសត្រូវការងារសំខាន់ៗ ។ ពេលវេលានិងកិច្ចខិតខំប្រឹងប្រែងយ៉ាងច្រើនត្រូវបានចំណាយក្នុងពេលប៉ុន្មានខែដំបូង ក្នុងការស្វែងរកឯកសារនិងភស្តុតាងដែលស្ថិតនៅភ្នាក់ងារផ្សេងៗពីគ្នាក្រោមចំណុះរដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើត ។ សំណុំរឿងរបស់កងជីវពលថ្នាក់ក្រោមដែលត្រូវបានឃុំខ្លួនអស់មួយរយៈនិងដែលកំពុងតែចាប់ខ្លួនជាបណ្តើរៗតាមច្បាប់ និងភ្នាក់ងារនានាដែលមានសមត្ថកិច្ចចេញដីកាបង្គាប់របស់រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើត កាលនោះត្រូវតែដំណើរការតាមនីតិវិធីជាបន្ទាន់បំផុត ។ នៅពេលការិយាល័យព្រហ្មទណ្ឌកម្រិតធ្ងន់ចេញប្រតិបត្តិការ មានធនធានតិចតួចបំផុតដែលអាចរកបាន ។ ការណ៍នេះបានរារាំងមិនឲ្យមានការស៊ើបអង្កេតដែលមានប្រសិទ្ធភាពចប់ចុងចប់ដើមទៅលើបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងនៅទីម័រខាងកើត និងនាំដល់ការផ្តោតជាសំខាន់ទៅលើការកាត់សេចក្តីលើបទឧក្រិដ្ឋក្រោមច្បាប់ក្នុងស្រុកជាជាងលក្ខណៈអន្តរជាតិ ។

ដូច្នេះសំខាន់ត្រូវមានធនធានគ្រប់គ្រាន់ និងបុគ្គលិកបម្រើការងារដែលមានជំនាញច្បាស់លាស់សម្រាប់ដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហម ហើយកំណត់ឲ្យបានច្បាស់ទៅលើការកំណត់អំណាចនិងការទទួលខុសត្រូវ ។ ទោះបីជាមានឬមិនមានការចូលរួមពីសំណាក់អង្គការសហប្រជាជាតិក៏ដោយ រដ្ឋាភិបាលកម្ពុជាចាំបាច់ត្រូវតែធានាឲ្យបានពិតប្រាកដនូវខ្ទង់ថវិកាសម្រាប់ចំណាយទៅលើតុលាការនេះ ។ ដូចដែលបានបង្ហាញជូនបទពិសោធន៍របស់ទីម័រខាងកើតរួចហើយថា គម្រោងនេះមិនអាចដំណើរការទៅបានទេប្រសិនបើខ្វះថវិកា ។ គួរតែមាន“ពេលអនុគ្រោះ” ដើម្បីឲ្យស្ថាប័ននានាលេចចេញជារូបរាងឡើង និងមានបុគ្គលិកគ្រប់គ្រាន់មុនពេលប្រតិបត្តិការចាប់ផ្តើម ។ អ្នកចូលរួមបំពេញការងារទាំងអស់ត្រូវជ្រាបថា តម្រូវការចង់បានលទ្ធផលលឿនទាន់ចិត្តលុះត្រាតែគម្រោងការនេះជាយន្តការដើម្បីយុត្តិធម៌ដែលមានសារសំខាន់និងមានប្រសិទ្ធភាព ។ ថ្វីដ្បិតតែការងារនេះត្រូវបានដំណើរការលើផ្នែកប្រមូលនិងវិភាគភស្តុតាងឯកសារដោយស្ថាប័ននានាដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជាហើយក៏ដោយ ប៉ុន្តែឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងឧក្រិដ្ឋជាលក្ខណៈអន្តរជាតិផ្សេងៗទៀតតម្រូវឲ្យមានការស៊ើបអង្កេតដែលមានលក្ខណៈស្មុគស្មាញយ៉ាងខ្លាំងនិងស៊ីពេលយ៉ាងយូរសម្រាប់ការជំនុំជម្រះក្តី ។ បញ្ហាស៊ើបអង្កេតចោទប្រកាន់ឬកាត់សេចក្តីបទឧក្រិដ្ឋដូចបានរៀបរាប់នេះមិនមែនជាការងាយ ហើយក៏មិនអាចធ្វើទៅបានលឿនដែរ ។ ពេលចាំបាច់ត្រូវមានប្រភពគ្រប់គ្រាន់ដែលជាកត្តាសំខាន់បំផុតសម្រាប់អ្នកស៊ើបអង្កេតសម្រាប់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត ហើយអង្គជំនុំវិសាមញ្ញផ្ទាល់ត្រូវទទួលបាននូវលក្ខណៈសម្បត្តិនេះ ដើម្បីឲ្យខ្លួនមានលទ្ធភាពអាចបំពេញតួនាទីអាជីពឲ្យស្របទៅតាមបទដ្ឋានអន្តរជាតិ ។

## ២) ពង្រឹងប្រព័ន្ធព្រហ្មទណ្ឌ

គម្រោងការងារព្រហ្មទណ្ឌកម្រិតធ្ងន់នៅទីម័រខាងកើតទទួលផលវិបាកយ៉ាងខ្លាំងដោយសារគម្រោងនេះជាផ្នែកមួយនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌមួយទន់ខ្សោយ ។ ចំណុចខ្សោយមួយចំនួនគឺមិនអាចចៀសបាន ។ មានចំណុចខ្លះកើតឡើងដោយសារវាជាកិច្ចការធំពេក ដែលរដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើតត្រូវធ្វើ នៅពេលខ្លួនសម្រុក

បង្កើតប្រព័ន្ធយុត្តិធម៌មួយដែលទើបតែងើបចេញពីគំនរផេះផង់បន្សល់ទុកដោយប្រទេសឥណ្ឌូនេស៊ី ។ មានបុគ្គលជាច្រើនមានអារម្មណ៍ថា រដ្ឋបាលបណ្ដោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើតបន្តធ្វើកិច្ចការនេះទៅតាមតម្រូវការនយោបាយក្នុងការបង្កើតប្រព័ន្ធមួយ ដោយគ្មានចក្ខុវិស័យជាយុទ្ធសាស្ត្របុប្ចន់មេច្បាស់លាស់ គ្មានការពិគ្រោះពិភាក្សាជាមួយជនជាតិទីម័រខាងកើតដែលជាម្ចាស់ទឹកម្ចាស់ដី និងគ្មានការផ្ដោតយកចិត្តទុកដាក់ឲ្យបានគ្រប់គ្រាន់ទៅលើការអភិវឌ្ឍសមត្ថភាពមូលដ្ឋានបុភាពដែលអាចសម្រេចបាននៃប្រព័ន្ធនេះ ។ កម្សោយនៃរដ្ឋបាលតុលាការត្រូវបានរកឃើញថា ជាប្រភពបង្កឲ្យមានចំណុចខ្វះខាតនៃប្រព័ន្ធតុលាការ រួមទាំងការផងរព្រហ្មទណ្ឌកម្រិតធ្ងន់មួយផង ។ ការបកប្រែផ្ទាល់មាត់និងការបកប្រែសរសេរជាផ្លូវការ៤ភាសាមិនទាន់មានគុណភាពនិងបរិមាណគ្រប់គ្រាន់ ។ ដោយគ្មានកំណត់ជាលាយលក្ខណ៍អក្សរត្រឹមត្រូវ កន្លងមកមានជួបបញ្ហាធំៗមួយចំនួនទាក់ទងដល់ការចងក្រងឯកសាររបស់តុលាការ ។ រដ្ឋបាលតុលាការនិងការបង្កើតកន្លែងចុះបញ្ជីឯកសារមិនត្រូវបានយកចិត្តទុកដាក់ ចំណែកឯ ចៅក្រម នៅទីបញ្ចប់បែរជាក្លាយទៅជាអ្នករដ្ឋបាលទៅវិញ ។ គ្មានការការពារសាក្សី ឬកម្មវិធីជំនួយការឬផ្ដល់ជាយោបល់ដល់ជនរងគ្រោះទេ ។ រីឯបទបញ្ញត្តិឲ្យមានខ្ទង់ចំណាយសម្រាប់សាក្សីក៏គ្មាន ។ សម្ភារឧបករណ៍សម្រាប់ធ្វើកោសល្យវិច័យនៅត្រូវការចាំបាច់នៅឡើយតាំងពីពេលនោះមកដល់សព្វថ្ងៃ ។

ដើម្បីប្រឈមមុខដោះស្រាយការលំបាកដ៏ធំធេងក្នុងការកាត់សេចក្ដីក្រោមច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ចាំបាច់ត្រូវការការកំណែទម្រង់ជាបន្ទាន់ ដើម្បីពង្រឹងតុលាការកម្ពុជានិងភ្នាក់ងារស៊ើបអង្កេត ។ មនុស្សសំខាន់ៗជាច្រើនរូប ដូចជាតំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានឲ្យយោបល់រួចមកហើយអំពីមធ្យោបាយក្នុងការអភិវឌ្ឍន៍ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ។ តាមពិតរដ្ឋាភិបាលបានរៀបចំរួចមកហើយនូវផែនការអភិបាលកិច្ចដើម្បីឈានទៅកែទម្រង់វិស័យតុលាការ ប៉ុន្តែឥទ្ធិពលមិនទាន់ដឹងថាមានកម្រិតត្រឹមណាទេ ។ ប្រសិនបើមិនអនុវត្តទៅតាមចំណុចទាំងអស់នេះ កំណែទម្រង់គួរតែចាប់ផ្ដើមទៅលើស្ថាប័ននានាដែលទាក់ទងដោយផ្ទាល់ទៅនឹងគម្រោងបង្កើតតុលាការខ្មែរក្រហម ។

ច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមសង្ឃឹមថានគរបាលយុត្តិធម៌កម្ពុជានឹងចុះប្រតិបត្តិការស៊ើបអង្កេតបទឧក្រិដ្ឋដែលមានលក្ខណៈស្មុគស្មាញទាក់ទងទៅនឹងអំណាចកំពូលរបស់រដ្ឋដោយវិលទៅរកសម័យកាលរវាងឆ្នាំ១៩៧៥ - ១៩៧៩ និងដោយផ្អែកទៅលើច្បាប់អន្តរជាតិ ។ កិច្ចការទាំងពីរនេះ នគរបាលយុត្តិធម៌មិនធ្លាប់ឆ្លងកាត់ឡើយ ។ មានរបាយការណ៍សាធារណៈសំខាន់ៗជាច្រើន (ដូចជារបាយការណ៍របស់អង្គការឃ្លាំមើលការអនុវត្តសិទ្ធិមនុស្សជាដើម) ដែលបញ្ជាក់ថា សូម្បីតែការស៊ើបអង្កេតធម្មតាក៏នគរបាលយុត្តិធម៌ មានការលំបាកទៅហើយ ។ វិធីម្យ៉ាងក្នុងការដោះស្រាយបញ្ហានេះគឺអាចយកអ្នកស៊ើបអង្កេតដែលជានគរបាលយុត្តិធម៌ឲ្យមកទទួលការបណ្ដុះបណ្ដាលជំនាញ ដែលជាផ្នែកមួយនៃអង្គភាពពិសេសស៊ើបអង្កេតតែទៅលើបទឧក្រិដ្ឋកម្មក្រោមសមត្ថកិច្ចរបស់តុលាការ ។ អង្គភាពនេះជាផ្នែកមួយរបស់ក្រសួងមហាផ្ទៃតាមច្បាប់ និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះរាជអាជ្ញា ។ ជំនួយការអន្តរជាតិក្នុងការអភិវឌ្ឍលើសមត្ថភាពជំនាញពិសេសនេះអាចមានសារសំខាន់ ហើយក្រសួងគួរតែពិចារណានិងអនុញ្ញាតឲ្យអ្នកស៊ើបអង្កេតអន្តរជាតិដែលមានជំនាញច្បាស់លាស់ ធ្វើការជាមួយនិងធ្វើជាទីប្រឹក្សាដល់អ្នកស៊ើបអង្កេតជនជាតិកម្ពុជាក្នុងដំណើរការទាំងមូលពីដើមដល់ចប់ ។ គ្រឿងសម្ភារធ្វើកោសល្យវិច័យត្រូវការពង្រឹងជាចាំបាច់ ។ ត្រូវតែឲ្យអាទិភាពទៅលើជំនាញការដូចជារោគសាស្ត្រវិទូនិងនរវិទូ ក៏ដូចជាអ្នកជំនាញការខាងពិនិត្យកន្លែងកើតហេតុ ប្រសិនបើរណ្ដៅសាកសពរួមត្រូវជីកកាស់ ហើយបូជនីយដ្ឋានត្រូវប្រែឲ្យទៅជាភស្តុតាងជាក់ស្ដែងសម្រាប់ការចោទប្រកាន់លើរឿងក្ដីព្រហ្មទណ្ឌ ។

អ្នកមានអាជីពជាជនជាតិខ្មែរដែលចូលរួមនៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម នឹងតម្រូវឲ្យមានការបណ្ដុះបណ្ដាលត្រឹមត្រូវជាមុន និងធ្វើការបណ្ដើរ ហ្វឹកហ្វឺនបណ្ដើរ មិនមែនសម្រាប់តែនគរបាលយុត្តិធម៌ទេ ។ និយាយរួម គ្រប់ផ្នែកទាំងអស់ត្រូវតែពង្រឹងឲ្យបានជាបន្ទាន់ ។ បុគ្គលិកផ្នែកច្បាប់ដែលត្រូវ

ជ្រើសរើសឲ្យបម្រើការក្នុងតុលាការ ចាំបាច់ត្រូវទទួលការបណ្តុះបណ្តាល ដែលផ្តោតសំខាន់ទៅលើច្បាប់សាធារណៈអន្តរជាតិ ច្បាប់មនុស្សធម៌អន្តរជាតិ ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។ ចៅក្រមស៊ើបអង្កេតនិងព្រះរាជអាជ្ញាតម្រូវឲ្យមានការបណ្តុះបណ្តាលដើម្បីបង្កើនជំនាញស៊ើបអង្កេតបទព្រហ្មទណ្ឌទៅលើករណីទាំងឡាយណាដែលមានលក្ខណៈមិនធម្មតានិងមានភាពស្មុគស្មាញ និងជំនាញកសាងសំណុំរឿងសម្រាប់ការចោទប្រកាន់ ។ ដោយសារថាអាចមានសម្ពាធដ៏ធ្ងន់មកលើគម្រោងបង្កើតតុលាការនេះឲ្យធ្វើការជាបន្ទាន់ពេលមាន "ភ្លើងខៀវ" បុគ្គលិកជនជាតិខ្មែរដែលនឹងត្រូវធ្វើការជាមួយតុលាការ គួរតែត្រូវជ្រើសតាំងឲ្យបានកាន់តែឆាប់កាន់តែល្អដើម្បីមានឱកាសគ្រប់គ្រាន់ក្នុងការបង្កើនសមត្ថភាព ។ ចំណែកកិច្ចការសំខាន់មិនគួរចាប់ផ្តើមទេ រហូតដល់ពេលណាដែលបុគ្គលិកទាំងនោះទទួលបានការហ្វឹកហ្វឺនគ្រប់គ្រាន់ ។ បុគ្គលិកទាំងនោះនឹងមានតម្រូវការឲ្យបណ្តុះបណ្តាលបន្ថែមជាបណ្តើរៗពេលកំពុងបំពេញកិច្ចការ និងតម្រូវការអ្នកជំនាញការច្បាប់អមតុលាការនិងអយ្យការដែលត្រូវតែជ្រើសតាំងឲ្យបានឆាប់តាមតែអាចធ្វើទៅបាន ដើម្បីឲ្យជួយដល់គម្រោងការនេះចាប់ពីដើមទីទៅ ។

ច្បាប់ខ្មែរក្រហមចែងឲ្យមានការបង្កើតការិយាល័យរដ្ឋបាលមួយ ។ បុគ្គលម្នាក់អាចសន្និដ្ឋានថា ការិយាល័យនេះគឺដើម្បីជាកន្លែងតម្កល់ឯកសារសម្រាប់ផ្តល់ឲ្យការិយាល័យចៅក្រម ការចោទប្រកាន់និងការការពារខ្លួន ។ ក៏ប៉ុន្តែការទទួលខុសត្រូវរបស់ការិយាល័យរដ្ឋបាលដូចដែលបានចែងក្នុងមាត្រា៣០គឺត្រឹមតែគ្រប់គ្រងចៅក្រមជម្រះក្តី ចៅក្រមស៊ើបអង្កេតនិងព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញប៉ុណ្ណោះ ។ ត្រង់នេះនឹងចោទជាបញ្ហាថាតើអ្នកណាជាអ្នកទទួលខុសត្រូវផ្នែករដ្ឋបាលតុលាការនិងបញ្ហាផ្សេងៗទៀត ដូចជាការបំលាស់ទីរបស់ជនជាប់ឃុំឲ្យចេញឬចូលបាន តើអ្នកណាធានាគ្រប់គ្រងមន្ទីរឃុំឃាំងរៀបចំថវិកាតុលាការ ថែរក្សាអគារនិងបរិវេណជុំវិញតុលាការចងក្រងឯកសារសម្រាប់សាធារណជនធ្វើការជាមួយប្រព័ន្ធឃោសនា កន្លែងបកប្រែគ្រប់គ្រងឯកសារតុលាការ និងឯកសាររបស់ភាគីក្តី និងសម្រង់រឿងក្តី ។ ចុះអំពីការតម្កល់ទុកភ័ស្តុតាងប្រកបដោយសុវត្ថិភាពវិញ? រដ្ឋបាលនៃតុលាការដែលមានលក្ខណៈគ្រប់គ្រាន់ត្រូវតែអភិវឌ្ឍ ហើយរដ្ឋាភិបាលអាចគិតពិចារណាក្នុងការពង្រីកការទទួលខុសត្រូវរបស់ការិយាល័យរដ្ឋបាលឲ្យលើសអំពីអ្វីដែលបានចែងនៅក្នុងមាត្រា៣០ ដោយបង្កើតនូវការិយាល័យផ្ទៃក្នុងសម្រាប់តម្កល់ឯកសារឬក៏រចនាសម្ព័ន្ធជាលក្ខណៈស្ថាប័នដាច់ដោយឡែកមួយ ។ ច្បាប់នេះចាំបាច់ត្រូវធ្វើឲ្យមានការបកប្រែជាភាសាប្រើក្នុងតុលាការដោយសរសេរនិងផ្ទាល់មាត់ (ភាសាខ្មែរ បារាំង រុស្ស៊ី និងអង់គ្លេស) ។ ចំណែកឯដំណាក់កាលជំនុំជម្រះក្តីនានាត្រូវកត់ជាលាយលក្ខណ៍អក្សរឲ្យបានត្រឹមត្រូវ ។ ច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមចែងថា "អង្គជំនុំជម្រះវិសាមញ្ញ..." ការពារឲ្យបានត្រឹមត្រូវចំពោះជនរងគ្រោះនិងសាក្សី ។ នៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃនេះមិនទាន់មានកម្មវិធីបែបនេះទេ ។ អង្គភាពដែលមានការតាំងចិត្តខ្ពស់និងមានឯករាជ្យភាពខាងការការពារជនរងគ្រោះនិងសាក្សី ចាំបាច់ត្រូវតែបង្កើតឡើងដោយមានបុគ្គលិកដែលមានការហ្វឹកហ្វឺនត្រឹមត្រូវ ។ គួររំឭកដែរថា នៅតុលាការព្រហ្មទណ្ឌអន្តរជាតិបង្កើតឡើងសម្រាប់ប្រទេសយូហ្គោស្លាវីនិងរ៉្វាន់ដា ការទទួលខុសត្រូវក្នុងការជួយឲ្យតុលាការនិងភាគីក្តីដែលមានការការពារដល់សាក្សីនិងជនរងគ្រោះត្រូវធ្លាក់មកលើការិយាល័យក្រឡាបញ្ជី ។

ទីកន្លែងមួយចំនួនត្រូវបានពិនិត្យដើម្បីជ្រើសរើសយកជាកន្លែងជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញ ។ នេះប្រហែលមកពីកិច្ចការតុលាការនេះមិនមែនជាផ្នែកមួយដែលមានលក្ខណៈជាស្ថាប័នរបស់តុលាការក្រុងភ្នំពេញដែលមានស្រាប់ តុលាការខេត្ត-ក្រុង (តុលាការកំពូលនិងសាលាឧទ្ធរណ៍) និងមកពីការដែលថាគ្មានកន្លែងណាមួយក្នុងចំណោមកន្លែងទាំងនេះអាចដំណើរការអង្គជំនុំជម្រះវិសាមញ្ញបានទេបើនិយាយអំពីទំហំ ។ សព្វថ្ងៃនេះ អគារទាំងអស់នេះមានលក្ខណៈតូចចង្អៀត ប្រើហួសកំណត់អាយុកាលចាស់ទ្រុឌទ្រោម និងខ្វះលក្ខណៈសន្តិសុខនិងសមត្ថភាពខាងបច្ចេកវិទ្យា ដែលជាការចាំបាច់សម្រាប់តុលាការកាត់ទោសខ្មែរក្រហមដូចជាគ្រឿងសម្ភារបរិក្ខារ (សម្រាប់ការបកប្រែភាសារផ្សេងៗក្នុងពេលជាមួយគ្នាជាដើម) ។ ឥឡូវនេះកំពុងតែរកមើលអគារថ្មីៗ ហើយអគារទាំងនេះចាំបាច់ត្រូវដាក់គ្រឿងតុបតែងថ្មីដើម្បី

ឲ្យសមស្របទៅនឹងតម្រូវការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ អគារទាំងនេះនឹងត្រូវធ្វើឲ្យមានតុល្យភាពរវាងការចូលទៅទាក់ទងជាសាធារណៈនិងសន្តិសុខ ។ ប៉ុន្តែមិនត្រូវភ្លេចថា ការិយាល័យសហចៅក្រមស៊ើបអង្កេត ការិយាល័យសហព្រះរាជអាជ្ញា និងទីប្រឹក្សាស្មាក្តីក៏ត្រូវការកន្លែងអង្គុយដែរ ។ ការដាក់ឲ្យការិយាល័យចៅក្រម និងភាគីក្តីម្ខាងនៅជាមួយគ្នាមិនមែនជាការសមស្របទេ ។ ការដែលអយ្យការ ការិយាល័យក្រឡាបញ្ជី និងការិយាល័យចៅក្រមនៃតុលាការព្រហ្មទណ្ឌ បង្កើតឡើងសម្រាប់ប្រទេសយូហ្គោស្លាវី ស្ថិតនៅបរិវេណអគារជាមួយគ្នានៅឈើឌីលក្រុង១ នៅទីក្រុងឡាអេ បាននិងកំពុងតែមានការមិនពេញចិត្តយ៉ាងខ្លាំងចាប់តាំងពីតុលាការនេះចាប់កំណើតរហូតមកដល់សព្វថ្ងៃ ។

### ៣) ការផ្តល់នៅស្ថាប័នទាំងនេះនូវមធ្យោបាយក្នុងការបំពេញភារកិច្ចរបស់ខ្លួន

ជួនកាលការគិតគូរតាមផ្លូវនយោបាយមានន័យថាគ្រាន់តែអត្ថិភាពនៃស្ថាប័នមួយគឺជាការគ្រប់គ្រាន់សម្រាប់បំពេញចិត្តអ្នកចាំឲ្យពិន្ទុទៅហើយ ។ ចៅក្រម អានតូនីអូ កាសេ ប្រធានទី១ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិបង្កើតឡើងសម្រាប់ប្រទេសយូហ្គោស្លាវី តែងលើកឡើងជារឿយៗថា “តុលាការគឺមិនដែលមានន័យអ្វីក្រៅពីខ្វាក្រដាស” ជាមធ្យោបាយសម្រាលគំនិតសាធារណៈពិភពលោកដែលមានការខឹងក្រេវក្រោធចំពោះអំពើឃោរឃៅដែលកំពុងតែត្រូវបានប្រព្រឹត្តឡើងនៅក្នុងប្រទេសបូស្នៀ-ហឺស៊ីហ្គោវីណា ។ តាមរយៈការអធិប្បាយខាងលើនេះឃើញថា ការគ្រប់គ្រងប្រភពមធ្យោបាយជាការសំខាន់បំផុតសម្រាប់គ្រប់គ្រងប្រសិទ្ធភាពនៃស្ថាប័នណាមួយ ។

កង្វះធនធានរបស់គម្រោងសិក្សាឧក្រិដ្ឋកម្មកម្រិតធ្ងន់នៅទីម័រខាងកើត បានជះឥទ្ធិពលផ្សេងៗទៅលើស្ថាប័ននេះ ។ ឧទាហរណ៍ វាបាននាំឲ្យជនសង្ស័យជាច្រើនត្រូវដោះលែងឲ្យរួចខ្លួន ហើយបុគ្គលដទៃទៀតត្រូវបានកាត់ទោសជាឧក្រិដ្ឋកម្មក្នុងស្រុកជាជាងឧក្រិដ្ឋកម្មអន្តរជាតិ ។ ក្រៅពីនេះវា មានឥទ្ធិពលទៅលើលទ្ធភាពរបស់ការផារព្រហ្មទណ្ឌកម្រិតធ្ងន់ក្នុងការស៊ើបអង្កេតឲ្យបានពេញលេញនូវអ្វីដែលបានកើតឡើងនៅក្នុងឆ្នាំ១៩៩៩ នេះមិនគិតដល់ឆ្នាំមុនការចូលកាន់កាប់ទឹកដីនេះផង ។ មានតែរឿងក្តីឆ្នាំ១៩៩៩មួយផ្នែកប៉ុណ្ណោះដែលត្រូវបានស៊ើបអង្កេតដោយក្រុមការផារនេះ ហើយមានការរីកចម្រើនតិចតួចណាស់ទាក់ទងនឹងការកសាងសំណុំរឿងថ្នាក់ដឹកនាំប្រឆាំងនឹងបុគ្គលមួយចំនួនដូចជាឧត្តមសេនីយ៍វីរ៉ាន់តូ ។ ទីប្រឹក្សាការពារកូនក្តីមិនត្រូវបានប្រគល់នូវមធ្យោបាយផ្សេងៗសម្រាប់បំពេញរឿងក្តីរបស់ខ្លួនឲ្យបានពេញលេញគ្រប់គ្រាន់ឡើយ ។ ចៅក្រមនៃក្រុមប្រឹក្សាតុលាការព្រហ្មទណ្ឌពិសេសមិនត្រូវបានជ្រើសរើសចេញពីអ្នកដែលមានជំនាញច្បាស់លាស់ខាងច្បាប់អន្តរជាតិ ហើយមិនបានផ្តល់នូវកន្លែងសិក្សាស្រាវជ្រាវ ឬឲ្យក្រឡាបញ្ជីជួយសិក្សាស្រាវជ្រាវផ្នែកច្បាប់ ។ ការធានាវត្តមានរបស់សាក្សីនៅក្នុងតុលាការគឺស្ថិតក្នុងលក្ខណៈជាសុបិននៅឡើយ ។ ចំណែកការធានាសន្តិសុខដល់ការធ្វើដំណើររបស់អ្នកទោសពីកន្លែងឃុំខ្លួនចូលមក តុលាការក៏ស្ថិតក្នុងសភាពដូចគ្នានេះដែរ ។ រហូតមកដល់ពេលសាងសង់បន្ទប់តុលាការទំនើប ក៏នៅមិនទាន់មានឧបករណ៍និងប្រដាប់ប្រដាសម្រាប់ធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរដើម្បីកត់ត្រាដំណាក់កាលជំនុំជម្រះក្តីឲ្យបានសុក្រឹតនៅឡើយ ។ ផលប៉ះពាល់ដោយសារកង្វះខាតសេវាកម្មបកប្រែផ្ទាល់មាត់ឬបកប្រែសរសេរ មានលើកឡើងខាងលើរួចហើយ ។

ប្រសិនបើស្ថាប័ននានាដែលទាក់ទងជាមួយអង្គជំនុំជម្រះវិសាមញ្ញត្រូវបានបង្កើតឡើងគ្រាន់តែឲ្យ“ល្អមើល”ដោយគ្មានទទួលបាននូវធនធានគ្រប់គ្រាន់ដើម្បីបំពេញភារកិច្ចបានពេញលេញនោះទេ គម្រោងការនេះគ្មានអ្វីគួរឲ្យសង្ស័យទេថានឹងមិនអាចផ្តល់យុត្តិធម៌បានឡើយ ។ ទង្វើបែបនេះនឹងនឹងផ្តល់នូវអំពើអយុត្តិធម៌សម្រាប់ជនរងគ្រោះនិងគ្រួសាររបស់ជនរងគ្រោះ ។ យោងតាមទំហំនៃអំពើឃោរឃៅដែលត្រូវបានប្រព្រឹត្តឡើងក្រោមរបបខ្មែរក្រហម វាជាការសំខាន់បំផុតដែលគ្រប់ស្ថាប័នដែលពាក់ព័ន្ធទាំងអស់នៅក្នុងគម្រោងនេះត្រូវបានផ្តល់នូវឯកសារមានន័យនិងការគាំទ្រ ផ្នែកនយោបាយ (នេះមិនសំដៅទៅលើការជ្រៀតជ្រែកឡើយ) និងបែបបទប្រើប្រាស់អំណាចច្បាស់លាស់ ។ ប្រសិនបើមានជំនាញការបរទេសចូលរួមដែលចាំបាច់ត្រូវមានសេវាបកប្រែ ដើម្បីឲ្យអ្នកជំនាញការនោះប្រើជំនាញរបស់ខ្លួនឲ្យបានពេញលេញ ។ កំហុសមួយក្នុងចំណោមកំហុសនានានៅក្នុង

ប្រព័ន្ធតុលាការសព្វថ្ងៃគឺថា នគរបាលយុត្តិធម៌ ចៅក្រមស៊ើបអង្កេត និងព្រះរាជអាជ្ញា មិនត្រូវបានផ្តល់ភ័ស្តុភារគ្រប់គ្រាន់ដើម្បីឲ្យខ្លួនមានលទ្ធភាពបំពេញបេសកកម្មស៊ើបអង្កេតបានពេញលេញ ហើយជារឿយៗអ្នកទាំងនេះតែងតែបង្ខំចិត្តប្រើប្រាស់ធនធានរបស់ខ្លួនផ្ទាល់ដូចជារថយន្ត (សាំង...។ល។) ។ នេះជាមូលហេតុនាំឲ្យការស៊ើបអង្កេតមានលក្ខណៈមិនប្រក្រតី ។

ក្រៅពីចំណុចសំខាន់និងការគាំទ្រដ៏មានន័យចំពោះស្ថាប័នដូចដែលបានរៀបរាប់ខាងលើនេះ នៅមានបញ្ហាសំខាន់មួយទៀតដែលត្រូវសង្កត់ធ្ងន់ គឺការខ្វះធនធានដែលមិនត្រូវឲ្យប្រើប្រាស់ធ្វើជាលេសក្នុងការប្រតិបត្តិមិនបានត្រឹមត្រូវនោះទេ ។ ចំណុចនេះទាក់ទងទៅដល់ផ្នែកខាងក្រោមនេះទៀត ដែលពាក់ព័ន្ធដល់គុណភាពរបស់បុគ្គលិក ។ បុគ្គលិកចំនួនតិចតែមានសមត្ថភាពគ្រប់គ្រាន់ រួមជាមួយយុទ្ធសាស្ត្រប្រាកដនិយមនិងទាក់ទងគ្នាអាចធ្វើកិច្ចការបានច្រើន ។

### ៤) គ្រប់គ្រងស្ថាប័នខ្លាំងៗដែលអាចបំពេញតាមអាណត្តិរបស់ខ្លួន

បទដ្ឋានអន្តរជាតិតម្រូវឲ្យមានឯករាជ្យភាពរបស់រដ្ឋអាជ្ញានិងតុលាការដែលមិនត្រូវស្ថិតក្រោមឥទ្ធិពលអ្វីមួយឡើយ ។ ប្រព័ន្ធសម្របសម្រួលនឹងផ្តល់នូវយុត្តិធម៌ដែលមានស្លាកស្នាមបន្តិចបន្តួចដែលនាំឲ្យមានសៅហ្មង ហើយរាល់កិច្ចខិតខំប្រឹងប្រែងចាំបាច់ត្រូវតែធ្វើឡើងដើម្បីជ្រើសរើសបុគ្គលិកណាដែលមិនស្ថិតក្រោមឥទ្ធិពលមិនប្រក្រតី ។

បទពិសោធន៍របស់ទីម័រខាងកើតគឺថា គុណភាពរបស់បុគ្គលិកធ្វើការដែលត្រូវបានផ្តល់ឲ្យ គឺជាការសំខាន់បំផុតសម្រាប់នាំដល់ជោគជ័យក្នុងដំណើរការស្វែងរកយុត្តិធម៌ ។ ឧទាហរណ៍ នគរបាលដែលគ្មានបទពិសោធន៍ខាងស៊ើបអង្កេត (នគរបាលចរាចរ អ្នកធ្វើការខាងរដ្ឋបាលជាដើម) ត្រូវបានអង្គភាពនគរបាលស្ថិតិជ្រើសតាំងឲ្យចូលធ្វើការងារនៅក្នុងអង្គភាពព្រហ្មទណ្ឌកម្រិតធ្ងន់ ហើយមានភារកិច្ចចុះស៊ើបអង្កេតក្នុងករណីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ការប៉ះទង្គិចគ្នាជាបន្តបន្ទាប់មិនចេះដាច់ជាមួយអង្គភាពព្រហ្មទណ្ឌកម្រិតធ្ងន់ បាននាំឲ្យមានចោទប្រកាន់អំពីអសមត្ថភាព ការគ្រប់គ្រងមិនត្រឹមត្រូវ កង្វះខាតទំនាក់ទំនង និងគ្មានការចាត់តាំងដឹកនាំ គ្មានយុទ្ធសាស្ត្រ ឬនយោបាយ ។ ដោយសារបរិយាកាសពិបាកធ្វើការបែបនេះ ធ្វើឲ្យអ្នកស៊ើបអង្កេតនិងបុគ្គលិកផ្នែកច្បាប់ជាច្រើននាក់ដែលមានសមត្ថភាពគ្រប់គ្រាន់ សុំលាលែងពីតំណែង ។ ចំណុចខ្សោយពីរដែលបញ្ជាក់ច្បាស់តាមរយៈអង្គការក្រៅរដ្ឋាភិបាលនិងរបាយការណ៍ពីប្រព័ន្ធឃោសនានានាទៅលើកម្សោយនៃភាពដឹកនាំនៃគម្រោងការសិក្សាបទព្រហ្មទណ្ឌកម្រិតធ្ងន់គឺ៖ ទី១ ការខកខានមិនបានអភិវឌ្ឍគោលនយោបាយទាក់ទងនឹងអំពើឃោរឃៅដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងចន្លោះឆ្នាំ១៩៧៥-១៩៧៩ ដែលនាំឲ្យអាជ្ញាធរព្រហ្មទណ្ឌកម្រិតធ្ងន់ខកខានទាំងស្រុងក្នុងការចុះស៊ើបអង្កេតនិងកាត់សេចក្តីអំពើឃោរឃៅនៅសម័យនោះ ហើយទី២ ការខ្សោះធនធានដោយសារការកាត់ទោសថ្នាក់ដឹកនាំកងជីវពលថ្នាក់ក្រោម ច្រើនជាងការកសាងសំណុំរឿងប្រឆាំងនឹងថ្នាក់ដឹកនាំធំៗ ។ អ្នកសង្កេតការណ៍ក៏បានសម្តែងនូវការព្រួយបារម្ភទៅលើការខិតខំស្វែងរកការគាំទ្ររបស់រដ្ឋបាលបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅទីម័រខាងកើត ក្រោមផ្លាកបង្រួបបង្រួមផ្សះផ្សាពីសំណាក់មេដឹកនាំកងជីវពលដែលកំពុងតែរស់នៅលើទឹកដីទីម័រខាងលិច ។ កិច្ចការនេះត្រូវបានធ្វើឡើងក្នុងគោលបំណងចម្បងមួយ គឺធានាបាននូវការវិលត្រឡប់មកវិញនៃជនភៀសខ្លួនរាប់ដល់១ម៉ឺននាក់ ដែលសព្វថ្ងៃនេះកំពុងតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងជីវពល ។ ប៉ុន្តែមានមជ្ឈដ្ឋានមួយចំនួនចោទសួរអំពីផលប៉ះពាល់ទៅលើយុទ្ធសាស្ត្រនិងសេចក្តីសម្រេចរបស់អង្គភាពព្រហ្មទណ្ឌកម្រិតធ្ងន់ ដោយលើកឡើងនូវការខកខានមិនបានចោទប្រកាន់មេដឹកនាំកងជីវពលដែលចូលរួមក្នុងកិច្ចចរចាផ្សះផ្សាបង្រួបបង្រួម ។ គម្រោងការងារព្រហ្មទណ្ឌកម្រិតធ្ងន់នេះក៏ជួបប្រទះនូវផលវិបាកយ៉ាងធ្ងន់ធ្ងរដោយហេតុថា អង្គភាពព្រហ្មទណ្ឌកម្រិតធ្ងន់គ្មានអ្នកដឹកនាំអចិន្ត្រៃយ៍ (ទាំងការិយាល័យទទួលបន្ទុកនិងរដ្ឋអាជ្ញារងទី១ បានឈប់ធ្វើការក្រោយពីបានប្រឡូកការងារអស់រយៈពេលប៉ុន្មានខែ ដោយលើកឡើងអំពីការជ្រៀតជ្រែកផ្នែកនយោបាយដែលមិនអាចទទួលយកបាន) ។

**(នៅមានត)**

**ស៊ូហ្សាណា លីនតុន**

# ខ្មែរគំនិតដើម្បីរក យុត្តិធម៌ពិតប្រាកដមួយ

**ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០២**

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃសន្និសីទកាសែតរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ នៅអគារធិការដ្ឋានអង្គការសហប្រជាជាតិ**



**សំណួរៈ** មកទល់នឹងពេលនេះមានរយៈជាងមួយខែទៅហើយចាប់តាំងពីលោក កូហ្វី អាណាន់ បានធ្វើសេចក្តីថ្លែងការណ៍យ៉ាងដាច់ណាត់បិទទ្វារឈប់ពិភាក្សាលើបញ្ហាតុលាការខ្មែរក្រហម ។ មានមជ្ឈដ្ឋានជាច្រើនបាននិយាយថាខ្លួនគេមិនពេញចិត្តទាល់តែសោះចំពោះសេចក្តីសម្រេចបែបនេះ ។ តើលោកមានបានបើកសំណុំរឿងសាជាថ្មីដែរឬទេ ហើយលោកឃើញមានឱកាសណាមួយដើម្បីឈានទៅដល់កិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាលកម្ពុជាដែរឬទេ?

**លោកអគ្គលេខាៈ** មានឯកអគ្គរដ្ឋទូតជាច្រើនបានមកជួបខ្ញុំពិភាក្សាអំពីបញ្ហានេះ ។ ឯកអគ្គរដ្ឋទូតទាំងនោះមានចំណាប់អារម្មណ៍ថា យើងគួរតែថ្លឹងថ្លែងពិចារណាសាជាថ្មី ។ ខ្ញុំបានឲ្យយោបល់ទៅអស់លោកអគ្គរដ្ឋទូតទាំងនោះទៅវិញថា ខ្ញុំគិតថាដើម្បីឲ្យកាន់តែមានប្រសិទ្ធភាព យកល្អអស់លោកគួរតែអញ្ជើញទៅទីក្រុងភ្នំពេញបញ្ចុះបញ្ចូលយ៉ាងណាឲ្យសម្តេច ហ៊ុន សែន ផ្លាស់ប្តូរជំហរនិងឥរិយាបថ ព្រមទាំងបញ្ជូននូវសញ្ញាឲ្យបានច្បាស់លាស់ថាសម្តេចពិតជាមានចំណាប់អារម្មណ៍ចង់បានតុលាការមួយដែលគួរឲ្យទុកចិត្តបាន ដែលស្របទៅនឹងបទដ្ឋានអន្តរជាតិ ។ ពោលគឺគេត្រូវចាប់ផ្តើមពីទីនោះជាមុនសិន ។

◆◆◆

**ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២**

**សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា**



ក្រុមការងារសម្រាប់ប្រតិបត្តិការជាមួយអ្នកជំនាញការច្បាប់បរទេសនិងការរៀបចំដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម

សេចក្តីថ្លែងការណ៍របស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិស្តីអំពីបញ្ហាតុលាការខ្មែរក្រហមដែលថ្លែងនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០២ បង្ហាញឲ្យឃើញនូវការយល់ខុស

មួយចំនួនមកលើជំហររបស់រាជរដ្ឋាភិបាលកម្ពុជា ដែលយើងសូមបញ្ជាក់ឲ្យបានច្បាស់ជាសង្ខេបថា ដើម្បីឲ្យការចរចាចាប់ផ្តើមសាជាថ្មី គឺមានមូលដ្ឋានមួយៗច្បាស់លាស់ ។ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវបានដកស្រង់សម្តីថា កម្ពុជាត្រូវតែបង្ហាញពីបំណងប្រាថ្នាដែលគួរឲ្យទុកចិត្តបានថាចង់ឲ្យមានតុលាការឧក្រិដ្ឋសង្គ្រាម ហើយថាកម្ពុជាជាអ្នករារាំងកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើតគម្រោងមួយដែលនឹងធានាឲ្យមានការជំនុំជម្រះក្តីដោយយុត្តិធម៌ស្របទៅនឹងបទដ្ឋានអន្តរជាតិ ។

ប៉ុន្តែដោយសារតែចង់បានតុលាការដែលអាចជឿទុកចិត្តបានដោយឈរលើបទដ្ឋានដែលទទួលស្គាល់ដោយអន្តរជាតិនេះហើយ បានជានៅឆ្នាំ១៩៩៧ កម្ពុជាបានសុំជំនួយឧបត្ថម្ភនិងឲ្យមានការចូលរួមពីអង្គការសហប្រជាជាតិនៅក្នុងដំណើរការជម្រះក្តីនេះ ហើយការណ៍នេះនៅតែបន្តបង្កើតជាមូលដ្ឋានសម្រាប់ការចរចារបស់ភាគីកម្ពុជានៅក្នុងបំណងល្អដដែល ។

ច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមដែលជាផ្លែផ្កាចេញពីការចរចាកន្លងមកទាំងអម្បាលម៉ាន ផ្តល់នូវការថ្លឹងថ្លែងរវាងអំណាចធ្វើការសម្រេចចិត្តរបស់ចៅក្រមខ្មែរនិងបរទេស ចៅក្រមស៊ើបអង្កេតនិងព្រះរាជអាជ្ញា និងផ្តល់នូវការធានាសិទ្ធិរបស់ចុងចោទ ។ កម្ពុជាបានសម្តែងនូវសុឆន្ទៈក្នុងការបញ្ជាក់ឲ្យបានច្បាស់នូវសិទ្ធិទាំងនេះ ដែលកាន់តែមានភាពលម្អិតនៅក្នុងអត្ថបទសហប្រតិបត្តិការ ។ អង្គការសហប្រជាជាតិមិនទាន់បានបញ្ជាក់ឲ្យបានច្បាស់នៅឡើយទេ ថាតើចំណុចណាខ្លះនៅក្នុងច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមរបស់កម្ពុជាមិនចូលបទដ្ឋានដែលទទួលស្គាល់ដោយអន្តរជាតិ ហើយអង្គការសហប្រជាជាតិ ក៏មិនទាន់បានឆ្លើយតបទៅនឹងសំបុត្ររបស់រាជរដ្ឋាភិបាលកម្ពុជាចុះថ្ងៃទី ២២ ខែមករា ឆ្នាំ២០០២ដែរ ។ នៅក្នុងខ្លឹមសារលិខិតនោះមានការឆ្លើយតបយ៉ាងលម្អិតទៅនឹង១១ចំណុចដែលលើកឡើងដោយឯកឧត្តម ហេន កូរែល ។

លោកអគ្គលេខាធិការអង្គការសហប្រជាជាតិក៏ត្រូវបានដកស្រង់សម្តីថា កម្ពុជាបញ្ជាក់ច្បាស់ថា ច្បាប់បង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងយកកិច្ចព្រមព្រៀងជាមួយអង្គការសហប្រជាជាតិទៅលើដំណើរការជម្រះក្តីទាំងមូលធ្វើជាគោល ។ តាមការពិតកម្ពុជាមិនដែលនិយាយដូច្នេះទេ ។ រាជរដ្ឋាភិបាលកម្ពុជាតែងតែទទួលស្គាល់កាតព្វកិច្ចជាអន្តរជាតិរបស់ខ្លួន ហើយបរមានុភាពនៃឯកសារមួយទៅលើឯកសារមួយទៀតមិនមែនជាចំណុចមានបញ្ហាទេ ។

កម្ពុជាឃើញភាពដាច់ដោយឡែកគ្នាកាន់តែច្បាស់រវាងភាពដើមនិងគោលបំណងនៃច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមនិងអត្ថបទសហប្រតិបត្តិការ ។ ឯកសារទាំងពីរនេះគ្មានណាមួយស្ថិតនៅក្រោមបន្ទាប់ណាមួយទេ ។ មិនគួរឲ្យមានការផ្ទុយមតិគ្នារវាងឯកសារទាំងពីរនេះឡើយ ។ ឯកសារទាំងពីរនេះគួរតែដើរទន្ទឹមគ្នា ហើយជួយបំពេញចំណុចខ្វះខាតគ្នាទៅវិញទៅមកជាមួយនឹងច្បាប់ដែលកំណត់នូវយុត្តាធិការនិងសមត្ថកិច្ចនៃអង្គជំនុំជម្រះវិសាមញ្ញក៏ដូចជាសមាសភាពរចនាសម្ព័ន្ធគ្រប់គ្រងនិងនីតិវិធីនៃការធ្វើសេចក្តីសម្រេច ។ ផ្ទុយទៅវិញ អត្ថបទសហប្រតិបត្តិការដែលនឹងត្រូវឆ្លងកាត់នីតិវិធីនៃការឲ្យសច្ចាប័នដោយរដ្ឋសភាជាតិ នឹងត្រូវកំណត់ថាតើរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិរួមសហប្រតិបត្តិការគ្នាដើម្បីអនុវត្តតាម“ខ”ដែលមានចែងនៅក្នុងច្បាប់នោះ ទាក់ទងនឹងការចូលរួមរបស់បរទេសនៅក្នុងដំណើរការនេះយ៉ាងដូចម្តេចខ្លះ ។

នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០២ ឯកឧត្តមប្រធានក្រុមការងារសម្រាប់សហប្រតិបត្តិការជាមួយអ្នកជំនាញការច្បាប់បរទេសនិងការរៀបចំដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម បានសរសេរលិខិតទៅឯកឧត្តម ហេន កូរែល ដោយសម្តែងនូវការស្រងាកចិត្តចំពោះការប្រកាសដកខ្លួនរបស់អង្គការសហប្រជាជាតិលែងចូលរួមចរចា ហើយសម្តែងនូវសេចក្តីសង្ឃឹមអស់ពីចិត្តថាអង្គការសហប្រជាជាតិនឹងត្រឡប់មកវិញ បង្ហើយឲ្យបានរួចរាល់ចប់ចុងចប់ដើមនូវអត្ថបទសហប្រតិបត្តិការ និងបង្កើតឡើងនូវអង្គជំនុំជម្រះវិសាមញ្ញដូចដែលបានគ្រោងទុក ។

ឯកឧត្តមប្រធានក្រុមការងារមានប្រសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាចិត្តថានឹងរកផ្លូវដើម្បីទម្លាយភាពទាល់ច្រកនាពេលបច្ចុប្បន្ននេះ ហើយសង្ឃឹមជឿជាក់ថាសេចក្តីថ្លែងការណ៍នេះនឹងបញ្ជាក់ច្បាស់អំពីសភាពពិតនៃជំហររបស់កម្ពុជាមិនខាន ។

(ប្រែសម្រួលក្រៅផ្លូវការដោយ **សួ ប៊ុនស៊ូ**)




## ប្រវត្តិរូបភាពផែនទីលលាដ៍
## សាកសពជនរងគ្រោះឆ្នាំ១៩៧៩




## សកម្មភាពរុះរើ
## ផែនទីលលាដ៍
## សាកសព
## ជនរងគ្រោះ
## ឆ្នាំ២០០២



# ផែនទីស្រាវជ្រាវ ដាក់ជំនួសផែនទីលលាដ៍



# សាកសពជនរងគ្រោះ




ចាប់តាំងពីឆ្នាំ១៩៩៥មកទល់នឹងឆ្នាំ២០០០ មជ្ឈមណ្ឌលឯកសារកម្ពុជាមានលទ្ធភាពចងក្រងបាន ឯកសារជាលក្ខណៈវិទ្យាសាស្ត្រតាមប្រព័ន្ធផ្កាយរណប នូវទីតាំងគុកនៃរបបខ្មែរក្រហមបានចំនួន១៦៧កន្លែង ទីតាំងវាលពិឃាតចំនួន៣៨៣កន្លែងដែលមានរណ្តៅសាកសពរួមចំនួន១៩៨៤០កន្លែង និងទីតាំងបូជនីយដ្ឋានតម្កល់អដ្ឋិធាតុជនរងគ្រោះចំនួន៧៧កន្លែង ។ ក្រុមស្រាវជ្រាវនៃការងារនេះចំនួន៤រូបគឺ ដាត កុសល, ស៊ិន យិន, ផេង ពង្សរ៉ាស៊ី និង អ៊ូច សំអឿន ក្រោមការជួយជ្រោមជ្រែងពីបុគ្គលិកជាច្រើនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ការស្រាវជ្រាវបានប្រព្រឹត្តទៅនៅក្នុងស្រុកចំនួន១២៩ ក្នុងចំណោមស្រុកទាំង១៧០ នៃខេត្ត-ក្រុងចំនួន២៤ (រាប់បញ្ចូលទាំងក្រុងកែបនិងក្រុងប៉ៃលិន) ។

**ផេង ពង្សរ៉ាស៊ី**

◆◆◆

## វាលពិឃាតឆ្នាំ១៩៧៥-១៩៧៩

### កំណត់សំគាល់ និង ស្ថិតិ (១៩៩៥-២០០០)

បូជនីយដ្ឋានប្រល័យពូជសាសន៍៧៧កន្លែង

*Genocide memorial 77*

មន្ទីរសន្តិសុខ (គុក) ១៦៧កន្លែង

*Security office (prison) 167*

ទីតាំងវាលពិឃាត ៣៨៣ កន្លែង

*Killing site 343*

រណ្តៅសាកសពរួម ១៩៨៤០រណ្តៅ

*Mass grave 19,440*

# ទ្រឹស្តីនៃភាពជាអ្នកដឹកនាំៈ សមមិត្ត ប៉ុល ពត

***សេចក្តីផ្តើម***

ប៉ុល ពត មានឈ្មោះដើមថា សាឡុត ស ។ ប៉ុល ពត កើតនៅខែមករា ឆ្នាំ១៩២៥ ។ ចាប់តាំងពី ប៉ុល ពត បានឡើងកាន់អំណាចមកទល់នឹងពេលនេះ មានសំណេរច្រើនរាប់មិនអស់និយាយអំពី ប៉ុល ពត។ នេះសបញ្ជាក់ឲ្យឃើញអំពីទំហំនៃប្រតិកម្មរបស់មនុស្សជាតិចំពោះការដឹកនាំរបស់ជនផ្តាច់ការឃោរឃៅដែលធ្វើឲ្យប្រជាជនកម្ពុជាស្លាប់បាត់បង់ជីវិតអស់ជាងមួយលាននាក់នៅទសវត្សរ៍ឆ្នាំ១៩៧០ ។ អំពើអាក្រក់ប្រឆាំងនឹងប្រជាជនឯង និងភាពទុយ៌សដែល ប៉ុល ពត ប្រព្រឹត្តមកលើជនរងគ្រោះ ត្រូវបានចងក្រងជាឯកសារយ៉ាងល្អិតល្អន់ ប៉ុន្តែមិនស្ថិតនៅក្នុងវង្វង់និក្ខេបបទនេះទេ ។ ផ្ទុយទៅវិញ និក្ខេបបទនេះផ្តោតសំខាន់តែទៅលើគំនិតរបស់ ប៉ុល ពត ដែលជាអ្នកដឹកនាំនយោបាយដែលមានអំណាចទាក់ទាញ ។ ការពិពណ៌នារបស់ខ្ញុំដែលថា ប៉ុល ពត ជាមេដឹកនាំដ៏មានប្រជាប្រិយភាព គឺមិនចង់សំដៅកាត់បន្ថយទំហំនិងភាពធំសម្បើមនៃឧក្រិដ្ឋកម្មរបស់ ប៉ុល ពត ទេ ហើយក៏មិនចង់ធ្វើឲ្យឃ្លាតចាកពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋកម្មទាំងអស់នេះដែរ ។ ការប៉ុនប៉ងសំដៅធ្វើអ្វីៗដែលរៀបរាប់មកនេះ គឺបង្កើតអយុត្តិធម៌យ៉ាងធ្ងន់ធ្ងរចំពោះព្រលឹងជនរងគ្រោះស្លូតត្រង់ដែលបានបាត់បង់ជីវិតនៅក្រោមការដឹកនាំរបស់ ប៉ុល ពត និងចំពោះការពិតនៃប្រវត្តិសាស្ត្រ ។

អំពើអសម្បជ្ជញ្ញៈនិងការឈឺចាប់ទាំងអស់ដែលកើតឡើងនៅក្នុងអំឡុងពេលឡើងកាន់អំណាច ប៉ុល ពត បានធ្វើឲ្យប្រជាជនមានអារម្មណ៍ខឹងយ៉ាងខ្លាំងចំពោះបុរសម្នាក់នេះដែលគ្មានធ្វើអ្វីក្រៅពីនាំឲ្យប្រជាជនចំនួន៧លាននាក់ធ្លាក់ចូលក្នុងវាលពិឃាតឡើយ ។ ក៏ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏នៅតែពិបាកពន្យល់ថាតើបុរសម្នាក់នេះដែលមានអ្នកខ្លះនិយាយថា "សាហាវជាងហ៊ីត្លែ" និង"ឧក្រិដ្ឋជនប្រល័យពូជសាសន៍" អាចឡើងមកដឹកនាំចលនានយោបាយនិងចលនាប្រដាប់អាវុធរហូតដល់ដឹកនាំជាតិទាំងមូលដោយរបៀបណា ។ ជ័យជម្នះតាមកម្លាំងយោធានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បានបើកផ្លូវឲ្យ ប៉ុល ពត អនុវត្តនូវទស្សនៈ"សម្ភូហនិយមស្អាតស្អំបរិសុទ្ធ" នៅទូទាំងប្រទេស ។

តើកត្តាអ្វីខ្លះដែលធ្វើឲ្យ ប៉ុល ពត ក្លាយជាមេដឹកនាំមានប្រជាប្រិយនៅក្នុងក្រសែភ្នែករបស់អ្នកដើរតាមខ្លួន? តើហេតុអ្វីបានជា ប៉ុល ពត ដែលស្ទើរតែបាត់អាជីពនយោបាយនៅពេលត្រូវបណ្តេញចេញពីអំណាចនៅឆ្នាំ១៩៧៩ និងនៅពេលដែលឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជនខ្លួនឯងត្រូវបានពិភពលោកពុសុសសាយហើយនោះ នៅតែមានលទ្ធភាពបន្តទទួលបាននូវការគោរពពីសំណាក់កូនចៅសំខាន់ៗរហូតដល់ ប៉ុល ពត ខ្លួនឯងបញ្ចប់ដង្ហើមចុងក្រោយនៅឆ្នាំ១៩៩៨? ដើម្បីឆ្លើយនឹងសំណួរទាំងនេះចាំបាច់ត្រូវយល់អំពីបាតុភូតអំណាចទាក់ទាញលក្ខខណ្ឌនានា ដែលជារឿយៗធ្វើឲ្យអ្នកដឹកនាំមានអំណាចនិង បុគ្គលិកលក្ខណៈដែលពិសេសៗរបស់អ្នកដឹកនាំដែលមានប្រជាប្រិយភាព។ ដើម្បីស្វែងអំពីយល់ ប៉ុល ពត ថាជាមេដឹកនាំ ដែលមានអំណាចទាក់ទាញ ដែលអាចធ្វើឲ្យកូនចៅដើរតាមខ្លួនពេញចិត្តពេញថ្លើម ជាការចាំបាច់គឺត្រូវតែសិក្សាអំពី ប៉ុល ពត ក្នុងបរិបទជាក់ស្តែងនៅកម្ពុជា ។

***ទ្រឹស្តីនៃភាពជាអ្នកដឹកនាំដែលមានអំណាចទាក់ទាញ***

ពាក្យថាអំណាចទាក់ទាញបានមកពីពាក្យដើមជាភាសាក្រិចដែលមានន័យថា "និស្ស័យ" ។ អស់រយៈពេលជាច្រើនឆ្នាំកន្លងមក សង្គមវិទូបានវិភាគនិងទាញហេតុផលទៅលើដើមកំណើតនៃអំណាចទាក់ទាញ និងហេតុអ្វីបានជាមនុស្សលោកចេះតែទោរទន់ទៅរកមេដឹកនាំដែលមានអំណាចទាក់ទាញយ៉ាងដូច្នេះ ។ សង្គមវិទូដ៏ល្បីល្បាញឈ្មោះ ម៉ាក្ស វើបប៊ែរ គឺជាបុគ្គលទីមួយដែលបានសិក្សាទ្រឹស្តីអំណាចទាក់ទាញនៃអ្នកដឹកនាំ ។ យោងតាមលោក វើបប៊ែរ សង្គមកិច្ចត្រូវបានគ្រប់គ្រងនិងដឹកនាំដោយជំនឿជាទូទៅមួយរបស់សមាជិកសង្គមដែលមានសណ្តាប់ធ្នាប់

សង្គមធម្មានុរូប ។ ភវនីយភាព (ភាពដែលអាចកើតមានឡើង) ដែលនឹងមានការបង្ហាញទិសចរិយាធម៌សង្គមផ្នែកសណ្តាប់ធ្នាប់នោះ បង្កើតបានជាមូលដ្ឋានគ្រឹះនៃអំណាចរបស់វា ។ លោក វើបឺរ សន្និដ្ឋានថា មានវិធី៣យ៉ាងក្នុងការប្រែក្លាយពលានុភាពទៅជាអំណាចធម្មានុរូប ។ ទីមួយគឺមានហេតុផល ទីពីរផ្អែកតាមប្រពៃណី និងទីបីមានអំណាចទាក់ទាញ ។ លោកសន្និដ្ឋានទៀតថា ប្រភេទអំណាចនីមួយៗនេះមានសុពលភាពប្លែកៗពីគ្នា ។ បទបញ្ជាដែលស្តែងចេញមក ដូចជាស្ថាប័នអប់រំ ឬតុលាការដែលសម្រេចទៅលើអង្គច្បាប់ ជាកត្តាធ្វើឲ្យមានអំណាចសមហេតុផល ។ អំណាចតាមប្រពៃណីកើតឡើងនៅពេលដែលទំនាក់ទំនងរវាងមេដឹកនាំនិងកូនចៅក្រោមបង្គាប់ដូចជាឪពុកម្តាយនិងកូនចៅ លោកគ្រូអ្នកគ្រូនិងសិស្សានុសិស្ស ឬនាយទាហាននិងពលទាហាន ត្រូវចងភ្ជាប់ដោយប្រពៃណីដ៏យូរលង់មកហើយ ។ មូលដ្ឋានអំណាចប្រពៃណី និងហេតុផលជាទម្រង់អំណាច គ្មានប្រសិទ្ធភាពក្នុងការនាំមកនូវការផ្លាស់ប្តូរសង្គមឬអង្គការទេ ។

ផ្ទុយមកវិញ អំណាចទាក់ទាញគឺជាផ្នែកមួយនៃការបញ្ចេញនូវទំនោរបែកគំនិតនៅក្នុងសង្គម ។ ផ្ទុយទៅនឹងអំណាចនីត្យានុកូលឬអំណាចប្រពៃណី អំណាចទាក់ទាញគឺជាប្រតិនិក្ខេបបទនៃសកម្មភាពធម្មតា ហើយតំណាងឲ្យបំណងប្រាថ្នាក្នុងការឆោតឆៅ បង្អាក់ និងផ្លាស់ប្តូរសណ្តាប់ធ្នាប់សង្គមដែលមានអានុភាព ។ វាជាផ្នែកមួយក្នុងការស្វែងរកការពិតតាមរយៈការពិភាក្សា និងតាមរយៈការទាញហេតុផលរវាងការចាំបាច់របស់មនុស្សជាតិដែលចង់បានរចនាសម្ព័ន្ធ និងតម្រូវការចាំបាច់របស់មនុស្សជាតិដែលចង់បានការផ្លាស់ប្តូរប្រែប្រួលនិងការបញ្ចូលរបៀបថ្មីៗនៅក្នុងសង្គម ។ អំណាចទាក់ទាញគឺខុសប្លែកពីអំណាចចេញពីហេតុផលនិងប្រពៃណី ដែលអំណាចនេះមិនមែនបង្កើតឲ្យមានតាមរយៈបទបញ្ជាឬប្រពៃណីដែលមានរួចហើយនោះទេ ប៉ុន្តែចេញពីការទុកចិត្តពិសេសដែលមេដឹកនាំមានអំណាចទាក់ទាញអន្ទោកអន្ទោលកូនចៅឲ្យដើរតាមខ្លួន ចេញពីអំណាចពិសេសដែលខ្លួនបង្ហាញចេញមក និងគុណភាពពិសេសដែលមេដឹកនាំមាន ។ យោងតាមលោក វើបឺរ វាជាការពិបាកសម្រាប់មេដឹកនាំដែលមានអំណាចទាក់ទាញក្នុងការថែរក្សាអំណាចរបស់ខ្លួន ពីព្រោះអ្នកដើរតាមខ្លួនត្រូវតែបន្តធ្វើឲ្យអំណាចនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។ មេដឹកនាំនេះត្រូវតែបង្ហាញជាប្រចាំចំពោះអ្នកដើរតាមខ្លួន នូវកាយវិការដឹកនាំដើម្បីពង្រឹងធម្មានុរូបនៃអំណាចរបស់ខ្លួន ។

មានស្នាដៃនិពន្ធជាទ្រឹស្តីមួយចំនួនបានពន្យល់កត្តាសំខាន់ៗដែលនាំឲ្យការដឹកនាំប្រកបដោយភាពទាក់ទាញ ។ គំនិតចិត្តវិទ្យារបស់យើងទាក់ទងនឹងការយល់ថាខ្លួនឯងមានតម្លៃ ឬការឲ្យតម្លៃមកលើខ្លួនឯង គឺជាមុខងារមួយបញ្ជាក់ពីឋានៈនៃអត្តសញ្ញាណរបស់យើងដែលមានវត្ថុក្រៅគំនិតច្បាស់លាស់ ។ វត្ថុក្រៅគំនិតអាចមានរូបរាងច្បាស់ដូចជាឋានៈសង្គមដែលយើងមាន (ឬរថយន្តដែលយើងបើកបរ) ឬវត្ថុក្រៅគំនិតដែលគ្មានរូបរាងច្បាស់លាស់ (មានដូចជាជំនឿឬបុព្វហេតុ) ។ នៅពេលដែលស្ថានភាពវត្ថុក្រៅគំនិតដែលយើងលើកមកនេះចេះតែកើនឡើង ការឲ្យតម្លៃទៅលើខ្លួនឯងក៏ចេះតែកើនឡើងទៅតាមនោះដែរ ។ នៅពេលស្ថានភាពនៃវត្ថុក្រៅគំនិតចេះតែថយទៅៗ ការឲ្យតម្លៃទៅលើខ្លួនឯងក៏ចេះតែថយទៅដែរ ។ មេដឹកនាំដែលមានប្រសិទ្ធភាពធ្វើឲ្យវត្ថុក្រៅគំនិតកាន់តែកើនឡើងខ្ពស់ ដែលជាការធ្វើឲ្យការឲ្យតម្លៃលើខ្លួនឯងរបស់អ្នកដើតាមខ្លួនកាន់តែមានកម្រិតខ្ពស់ឡើង ។ នៅពេលអ្នកដើរតាមស្គាល់ចិត្តមេដឹកនាំរបស់ខ្លួន ហើយមេដឹកនាំបង្កើនការជឿជាក់របស់កូនចៅដែលដើរតាមខ្លួន ពេលនោះអ្នកដើរតាមចាត់ទុកថាមេដឹកនាំរបស់គេគឺជាមេដឹកនាំដែលមានអំណាចទាក់ទាញ ។ ការយល់ឃើញទៅលើអំណាចដែលមានលក្ខណៈទាក់ទាញ មានសារសំខាន់តែរវាងមេដឹកនាំនិងកូនចៅដែលដើរតាមប៉ុណ្ណោះ ។ ការដែលអ្នកដែលមិនមែនកូនចៅមានគំនិតទៅលើមេដឹកនាំ ពិតជាមានកម្រិតទាក់ទងតិចតួចណាស់នឹងសញ្ញាណនៃអំណាចទាក់ទាញ ។ យោងតាមលោក វើបឺរ មនុស្សលោកមានតម្រូវការចាំបាច់ខុសពីធម្មតា ជាពិសេសនៅពេលមានភាពតានតឹងនិងវិបត្តិនៅក្នុងសង្គមមួយ ហើយមេដឹកនាំដែលអាចបំពេញតម្រូវការចាំបាច់ទាំងនេះត្រូវបានចាត់ទុកជាមេដឹកនាំដែលមានអំណាចទាក់ទាញ ។ មេដឹកនាំដែលមានអំណាចទាក់ទាញជួយកូនចៅឲ្យសម្រេចបាននូវភាពលើសលប់ តាមរយៈការប្រែក្លាយទៅជាតំណាងនៃគុណភាពដែលកូនចៅចង់បាន ។

មេដឹកនាំដែលមានអំណាចទាក់ទាញ ចេញមុខជារឿយៗ នៅក្នុងពេលមានវិបត្តិសង្គម ។ តើអ្វីទៅជាគុណភាពនិងលក្ខណៈសម្បត្តិទូទៅនៃមេដឹកនាំដែលមានអំណាចទាក់ទាញ? មេដឹកនាំដែលមានអំណាចទាក់ទាញមានលទ្ធភាពអាចយកការគិតនិងគំនិតស្មុគ្រស្មាញចម្រាញ់ឲ្យទៅជាខ្លឹមសារសាមញ្ញៗងាយយល់ដូចជាការប្រើសញ្ញាការផ្តុំផ្តួននិងប្រៀបធៀប ។ មេដឹកនាំដែលមានអំណាចទាក់ទាញ ក្រសោបនូវការប្រថុយគ្រោះថ្នាក់ និងមានអារម្មណ៍ថាឥតន័យបើគ្មានបួននឹងគ្រោះថ្នាក់ ។ មិនតែប៉ុណ្ណោះ មេដឹកនាំចេះឆក់ឱកាសដោយគ្មានព្រួយបារម្ភថានឹងទទួលបរាជ័យឡើយ ។ មេដឹកនាំដែលមានអំណាចទាក់ទាញ ប្រយុទ្ធប្រឆាំងនឹងកិច្ចការដែលមានសព្វថ្ងៃនិងគតិបណ្ឌិតសាមញ្ញៗ ។ យោងតាមលោក វើបប៊័រ មេដឹកនាំដែលមានអំណាចទាក់ទាញច្រានចោលនូវគោលដៅដែលមានហេតុផលនិងគោលដៅសេដ្ឋកិច្ចនិងបទបញ្ញានានា ដោយជ្រើសរើសយកសកម្មភាពទាំងឡាយណាដែល "គ្មានហេតុផល" ប៉ុន្តែមានលក្ខណៈឲ្យតម្លៃទៅលើមនុស្ស ហើយចំណុចមួយដែលជាសញ្ញានៃភាពជាអ្នកដឹកនាំមានអំណាចទាក់ទាញគឺស្ថិតនៅលើសមត្ថភាពរបស់មេដឹកនាំក្នុងការបន្សល់ទុកនូវការសម្រេចដ៏សំខាន់មួយទៅលើវចនាសម្ព័ន្ធជាប្រពៃណីដែលប្រែក្លាយទៅជាស្ថាប័នដែលអ្នកដឹកនាំរូបនេះមិនទទួលស្គាល់ ។ មេដឹកនាំដែលមានអំណាចទាក់ទាញ គឺមានសមត្ថភាពយល់ពីជម្រៅចិត្ត ។ អ្នកដឹកនាំទាំងនេះព្យាយាមមើលពិភពលោកតាមរយៈភ្នែករបស់កូនចៅខ្លួន ។ ចំណុចចុងក្រោយគឺថា អ្នកដឹកនាំដែលមានអំណាចទាក់ទាញបញ្ចេញយោបល់ប្រឆាំង បន្ទុំ និងចាក់ឆ្កឹះកូនចៅ ដើម្បីចង់ដឹងថាតើកូនចៅទាំងនោះមានសេចក្តីក្លាហាននិងការតាំងចិត្តដល់កម្រិតណា ។ អ្នកដឹកនាំដែលមានអំណាចទាក់ទាញ ពូកែខាងនិយាយអំពីតម្លៃសង្កត់ធ្ងន់លើការសន្យាធ្វើអ្វីមួយកំណត់កម្រិតអ្វីៗខ្ពស់ៗ ដាក់ទម្ងន់ទៅលើគំនិតបំពេញបេសកកម្ម មានគំនិតសុទិដ្ឋិនិយមអំពីអនាគត សម្តែងការជឿទុកចិត្ត លះបង់ផ្ទាល់ខ្លួនផ្តល់នូវការលើកទឹកចិត្តចំពោះកូនចៅ និងមានជំនឿស៊ប់ទៅលើឧត្តមគតិ ។

## ការឡើងមកកាន់អំណាចរបស់ ប៉ុល ពត

កម្ពុជាសម័យក្រោយអាណានិគមគឺជាសង្គមមួយដែលចាក់ឫសយ៉ាងជ្រៅទៅក្នុងគំនិតឋានានុក្រមនិយមដែលឲ្យមនុស្សម្នាក់ប្រើអំណាចតែឯងយ៉ាងចាស់ដៃ ។ ចាប់ពីឆ្នាំ១៩៤៥ រហូតដល់១៩៧០ សម្តេចព្រះ នរោត្តម សីហនុ ដែលដឹកនាំកម្ពុជាមុនដំបូងបង្អស់ ក្នុងព្រះនាមជាព្រះមហាក្សត្រ បន្ទាប់មកជាប្រមុខរដ្ឋ ។ វចនាសម្ព័ន្ធនយោបាយកម្ពុជាក្នុងអំឡុងសម័យដែលដឹកនាំដោយសម្តេច សីហនុ បានប្រគល់ "អំណាចទៅលើជនមួយក្តាប់តូចដែល...កេងប្រវ័ញ្ចប្រជាជន ភាគច្រើននៅគ្រប់ស្រទាប់វណ្ណៈ" ។ ជីវិតរស់នៅពោរពេញទៅដោយអំពើ "ញាតិបក្សនិយម និងអំពើពុករលួយ" ។ ប្រទេសកម្ពុជាគឺជាប្រទេសកសិកម្ម ដែលមានសេដ្ឋកិច្ចរីកចម្រើនមិនលើសពីវិស័យកសិកម្មនិងឧស្សាហកម្មតូចៗផ្សេងទៀតដែលប្រើកម្លាំងពលកម្មឡើយ ។ ដោយគ្មានមូលដ្ឋានសេដ្ឋកិច្ចខ្លាំង នាំឲ្យជីវភាពរស់នៅរបស់ប្រជាជនមានកម្រិតទាប ។ កម្រិតសេដ្ឋកិច្ចដែលមានគម្លាតពីគ្នារវាងបណ្តុំពួកវរជនដែលកាន់អំណាចមានទ្រព្យសម្បត្តិហូរហៀរ និងប្រជាកសិករក្រីក្រ ធ្វើឲ្យមានតវ៉ាយ៉ាងខ្លាំងសុំឲ្យមានការផ្លាស់ប្តូរវិស័យសង្គមនិងនយោបាយ ក្នុងគោលបំណងឆក់អំណាចនយោបាយនិងសេដ្ឋកិច្ចពីពួកអ្នកកាន់អំណាចយកទៅចែករំលែកដល់អ្នកក្រខ្សត់ ។

ការឈានជើងចូលឆាកនយោបាយកម្ពុជារបស់ ប៉ុល ពត គឺជំរុញដោយបំណងប្រាថ្នាក្នុងការនាំមកនូវការផ្លាស់ប្តូរសង្គមនិងនយោបាយ ដើម្បីប្រយោជន៍ប្រជាជនក្រីក្រ ។ ក្រោយពីបានចំណាយពេលអស់រយៈពេល៣ឆ្នាំនៅសាកលវិទ្យាល័យមួយនៅប្រទេសបារាំង និងបន្ទាប់ពីបានទទួលមនោគមវិជ្ជាកុម្មុយនិស្តនៅប្រទេសបារាំងមក ក្នុងឆ្នាំ១៩៥៣ ប៉ុល ពត ក៏បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ ។ ប៉ុល ពត យល់ឃើញថា "លទ្ធិកុម្មុយ-និស្តគឺជាវិធីសាស្ត្រមួយឈុត" ដែលនឹងនាំឲ្យមានការផ្លាស់ប្តូរសង្គមនិងនយោបាយនៅកម្ពុជា ។

ដើម្បីបញ្ចូលលទ្ធិកុម្មុយនិស្តទៅក្នុងផ្នត់គំនិតរបស់ជនរួមជាតិនៅឆ្នាំ១៩៥៦ ប៉ុល ពត ចាប់យកអាជីពជាគ្រូបង្រៀនភាសាបារាំងនិងភូមិវិទ្យានៅវិទ្យាល័យឯកជនមួយ នៅទីក្រុងភ្នំពេញដែលជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។ ការបង្រៀនបានធ្វើឲ្យ ប៉ុល ពត មានឱកាសបញ្ចេញទេពកោសល្យនយោបាយ

ដែលទើបតែដុះពន្លក ក្នុងការទាក់ទាញយុវវ័យឲ្យចូលក្នុងចលនាកុម្មុយនិស្ត ។ មានការរំពឹកឡើងវិញជាច្រើនចាត់ទុកថា ជំនាញរបស់ ប៉ុល ពត គឺជាគ្រូបង្រៀន ។ ក្នុងការសម្រេចចិត្តដើរតួនាទីនេះ ប៉ុល ពត បានផ្អែកលើការគោរពយ៉ាងជ្រាលជ្រៅរបស់ជនជាតិខ្មែរមានចំពោះលោកគ្រូអ្នកគ្រូ ដែលបានឆ្លុះបញ្ចាំងអស់រយៈកាលជាច្រើនសតវត្សរ៍ ដែលកាលណោះ វិស័យអប់រំស្ថិតនៅក្នុងកណ្តាប់ដៃពួកព្រាហ្មណ៍ ឬព្រះសង្ឃក្នុងព្រះពុទ្ធសាសនា និងលោកគ្រូអ្នកគ្រូដែលមានឋានៈខ្ពង់ខ្ពស់នៅក្នុងសាធារណរដ្ឋទីបីរបស់បារាំងដែលក្នុងរបបនោះ ប៉ុល ពត ត្រូវបានទទួលការទំនុកបម្រុង ។ នៅក្នុងប្រព័ន្ធអប់រំកម្ពុជា សូម្បីតែគ្រូគណិតវិទ្យាក៏បង្រៀនអំពីក្រមសីលធម៌ដែរ ។ ជាប្រពៃណីកូនសិស្សត្រូវគោរពលោកគ្រូអ្នកគ្រូ ដូចជាគោរពបងប្អូនដែលមានវ័យចំណាស់ជាងខ្លួនដែរ ។ បងប្រុសឬគ្រូបង្រៀនកម្រនឹងផ្តល់នូវការគោរពដោយកក់ក្តៅនិងចិត្តប្រណីណាស់ ប៉ុន្តែបើមានមែននោះធ្វើឲ្យកិត្តិយសរបស់គ្រូបង្រៀនកើនឡើងទ្វេ ។ ជាមួយកូនសិស្ស ប៉ុល ពត ហាក់ដូចជាទទួលបាននូវជោគជ័យថាជាលោកគ្រូ "ចម្រើនវិជ្ជា" ។

អ្នកដែលស្គាល់ប៉ុលពតកាលពីសម័យនោះយល់ឃើញថា ប៉ុល ពត ជាគ្រូ"បង្រៀនល្អ...ជាកិត្តិជនដែលគួរឲ្យចាប់អារម្មណ៍" ។ សំឡេងធូន់និងកាយវិការស្លូតបូតមិនឆេវឆាវ នាំឲ្យប្រជាប្រិយភាពរបស់ ប៉ុល ពត ឡើងមួយកម្រិតទៀត ។ ប៉ុល ពត ហាក់ដូចជាបុគ្គលម្នាក់ដែលពន្យល់សាច់ការ ធ្វើយ៉ាងម៉េចឲ្យអ្នកស្តាប់ស្រឡាញ់យុត្តិធម៌និងភាពស្មោះត្រង់ ហើយឲ្យស្អប់អំពើពុករលួយ" ។ មានសិស្សមួយចំនួននៅចាំបានថា "ប៉ុល ពត មិនឆេវឆាវ ជឿជាក់លើខ្លួនឯង មុខមាត់ស្អាតបាត ស្លូតបូត និងពូកែនិយាយឲ្យគេជឿ ហើយពូកែនិយាយរហូតដល់អ្នកស្តាប់ដេកលក់ទៀតផង" ។ នៅក្នុងពេលមានការពិភាក្សាជាក្រុម ប៉ុល ពត បានវាយប្រហារលើសេចក្តីទុច្ចរិតនិងអំពើពុករលួយរបស់មជ្ឈដ្ឋានរដ្ឋាភិបាល សម្តេច សីហនុ ដោយមិនបាននិយាយអំពីសម្ព័ន្ធភាពនយោបាយកុម្មុយនិស្តរបស់ខ្លួនឡើយ ។ សិស្សម្នាក់របស់ ប៉ុល ពត រំពឹកឡើងវិញថា ប៉ុល ពត "មានប្រជាប្រិយភាពណាស់ក្នុងចំណោមសិស្សានុសិស្ស គាត់ជាគ្រូល្អនិងត្រឹមត្រូវណាស់" ។ នៅប្រទេសកម្ពុជាក្នុងទសវត្សរ៍ឆ្នាំ១៩៥០ ពាក្យ" កុម្មុយនិស្ត" គឺសំដៅទៅលើមនុស្សដូចជា ប៉ុល ពត ដែលមានបទពិសោធន៍ល្មមគួរសមរៀនបានចេះដឹងនិងមានកំហឹងចំពោះអំពើពុករលួយ ។ ការចេះដឹងមានន័យ រួមបញ្ចូលទាំងការអប់រំក្រោមអនុវិទ្យាល័យនៅប្រទេសបារាំង ។ មនុស្សដូចជា ប៉ុល ពត ត្រូវបានគិតថាជាអ្នកដែលមានការឈឺឆ្អាលអំពីសុខទុក្ខរបស់ប្រជាជនក្រីក្រ ។

នៅឆ្នាំ១៩៦២ នៅឯសិក្ខាសាលានៅទីក្រុងភ្នំពេញ ប៉ុល ពត បាននិយាយទៅកាន់អ្នកចូលរួមដែលរួមមានព្រះសង្ឃនិងសិស្សអនុវិទ្យាល័យ ។ អ្នកចូលរួមសិក្ខាសាលាម្នាក់បានរំពឹកថា សម្តីរបស់ ប៉ុល ពត គឺ "ស្តាប់ទៅពីរោះនិងគួរឲ្យជឿ" ។ គាត់ពូកែលើកឧទាហរណ៍មកពន្យល់ ។ គាត់ងាយធ្វើឲ្យគេចូលចិត្តណាស់" ។ ប៉ុល ពត បានសុំឲ្យអ្នកចូលរួមទាំងអស់គិតគូរអំពីសង្គមកម្ពុជា ។ ប៉ុល ពត និយាយថា រដ្ឋាភិបាលសីហនុ យកលុយពីប្រជាជនពេលកើត ពេលរៀបការ និងពេលស្លាប់ ។ "គ្មានអ្នកណាអាចធ្វើអ្វីកើតទេ បើរដ្ឋាភិបាលមិនយកលុយនោះ" ។ ប៉ុល ពត ឲ្យជាយោបល់ថា អំពើពុករលួយដែលចេះតែរាលដាលទៅៗ នៅក្នុងជួររដ្ឋាភិបាល នាំឲ្យប្រជាជនកាន់តែក្រទៅៗ ។ ប៉ុល ពត បាននិយាយអំពីសង្គមថ្មីដែលមានសមភាពស្មើៗគ្នាទាំងអស់ ។

ក្នុងពេលកំពុងបង្រៀនអំពីសភាពការណ៍ប្រទេសកម្ពុជា សុខៗ ប៉ុល ពត ឈប់ងាក់ ហើយសួរកូនសិស្សថា "តើយើងធ្វើយ៉ាងម៉េចដើម្បីឲ្យប្រជាជនស្រឡាញ់យើង?" ។ មានសិស្សមួយចំនួននិយាយថា ធ្វើឲ្យអំពើពុករលួយរបស់ក្រុមប្រឆាំងផ្សេងៗទៀតពុះសុសសាយដល់គេឯង និងបង្ហាញអំពីជំហរស្នេហាជាតិរបស់ខ្មែរក្រហម ។ សិស្សមួយចំនួនទៀតនិយាយថា ចំណុចសំខាន់គឺសេដ្ឋកិច្ច... ។ ប៉ុល ពត នៅតែគ្រវីក្បាលថាមិនត្រឹមត្រូវ ។ បន្ទាប់មកមានសិស្សម្នាក់លើកដៃឡើងឆ្លើយថា "យើងត្រូវតែដាក់ខ្លួនយើងឲ្យទាបដូចអ្នកដែលក្រីក្របំផុត ពេលនោះប្រជាជននឹងមកចោមរោមស្រឡាញ់យើងមិនខាន" ។ ពេលនោះលោកគ្រូឆ្លើយថា "ត្រឹមត្រូវ" ហើយសប្បាយចិត្តដោយសារមានកូនសិស្សរបស់ខ្លួនម្នាក់ឆ្លើយត្រូវ ។ "ត្រឹមត្រូវ! ពិតជាត្រឹមត្រូវហើយ!" ។

នៅក្នុងឯកសារមួយដែលត្រូវបានប្រើប្រាស់នៅវគ្គសិក្សារៀនសូត្ររបស់ខ្មែរក្រហមនៅឆ្នាំ១៩៧០នៅពេលដែលចលនា

កម្មុយនិស្តកម្ពុជាចូលដល់ដំណាក់កាលតស៊ូ ដោយអាវុធ អ្នកនិពន្ធអនាមិកបានសរសេរថា “ជនបដិវត្តត្រូវមានចិត្តល្អ បេះអាណិតអាសូរប្រជាជន ។ ជនបដិវត្តត្រូវតែប្រើពាក្យសមរម្យជានិច្ចនៅពេលនិយាយស្តីជាមួយប្រជាជន មិនត្រូវទាស់ពាក្យទាស់សម្តីទេ ។ ធ្វើឲ្យអ្នកស្តាប់អាណិតអ្នកនិយាយ ។ រាល់ពេលនិយាយស្តាប់ទៅគួរឲ្យស្រទន់ ។ បញ្ចេញទឹកមុខរីករាយ ស្រស់ស្រាយទៅកាន់គ្រប់ៗគ្នា និងធ្វើឲ្យអ្នកស្តាប់សប្បាយចិត្ត» ។ នេះចង់និយាយអំពីកាយវិការនិងពាក្យសម្តីដែល ប៉ុល ពត សម្តែងចេញ ។ ឯកសារដទៃៗទៀតសង្កត់ធ្ងន់ថា ជនបដិវត្ត “ត្រូវដកពិសោធន៍ពីប្រជាកសិករក្រ...និងកម្មករ”ដែលនៅជនបទឆ្ងាយៗ ។ បើតាមការប្រើពាក្យរបស់ខ្មែរក្រហម ជនបដិវត្តត្រូវតែ “យកចេញពីដីដូចពេជ្រមិនទាន់ច្នៃដូច្នោះដែរ” ។

## ប៉ុល ពត ជាមេដឹកនាំដែលមានអំណាចទាក់ទាញ

ប៉ុល ពត គឺជាមេដឹកនាំដែលមានអំណាចទាក់ទាញ ដោយសារហេតុផលមួយចំនួនដែលស្របគ្នាទៅនឹងការបរិយាយតាមទ្រឹស្តីខាងលើ ។ ដូចដែលបានពិភាក្សានៅវគ្គមុនៗ អំណាចទាក់ទាញដែលមានចរិតថ្លៃថ្នូរសមរម្យរបស់ ប៉ុល ពត គួបផ្សំជាមួយនឹងបទពិសោធន៍ល្មមគួរសមរៀនសូត្រចេះដឹង និងមានកំហឹងយ៉ាងក្តៅគគុកប្រឆាំងនឹងអំពើពុករលួយ បានធ្វើឲ្យប្រជាជនគ្រប់ស្រទាប់វណ្ណៈនៅក្នុងសង្គមកម្ពុជាពេញចិត្ត ជាពិសេសសិស្សានុសិស្សនិងប្រជាកសិករ ។ “ប្រជាជនកម្ពុជាដែលបានជួបមុខ ប៉ុល ពត ចាត់ទុកថា ប៉ុល ពត មានការទាក់ទាញណាស់ដោយសារចរិយាធម៌សមសួន ដូចជាការគ្រប់គ្រងអារម្មណ៍ខ្លួនឯង ចិត្តល្អដែលនៅជាប់នឹងសិស្សានុសិស្សនិងប្រជាកសិករ



ប៉ុល ពត

អស់ជាច្រើនឆ្នាំមកហើយ" ។ មនុស្សដែលមិនរស់នៅក្នុងបរិបទសង្គមបែបនេះអាចប្រហែលជាចាត់ទុក ប៉ុល ពត ថាជាមនុស្សក្តៅក្រហាយនិងមនុស្សលាក់ពុត ។ ក៏ប៉ុន្តែដូចដែលបានលើកមកពិភាក្សាក្នុងថ្នាក់រៀនជាច្រើនលើកហើយថា ការដែលអ្នកមិនមែនជាកូនចៅមានគំនិតទៅលើមេដឹកនាំ ពិតជាមានកម្រិតទាក់ទងតិចតួចណាស់នឹងសញ្ញាណនៃអំណាចទាក់ទាញ ។

ប៉ុល ពត និងគំនិតរបស់ខ្លួន បានបង្ហាញអំពីគុណធម៌ល្អ (ដូចជាសមភាពសង្គមនិងសេដ្ឋកិច្ច និងការប្រឆាំងនឹងអំពើពុករលួយ) ដែលជាការប៉ងប្រាថ្នារបស់ប្រជាជនកម្ពុជាទូទៅ ។ ក៏ប៉ុន្តែអំណាចចេញពីប្រពៃណីបង្ហាញពីអានុភាពអវិជ្ជមានដូចជាការធ្វើឲ្យល្អក់កករដល់សង្គមដែលជាការប៉ះពាល់ដល់សង្គមខ្មែរដែលប្រជាជនចង់លុបបំបាត់ដោយខ្លួនឯងតែធ្វើទៅមិនរួច ។ ក្នុងន័យនេះ ប្រជាជនដែលចូលរួមយោបល់ទៅលើសណ្តាប់ធ្នាប់សង្គមនិងបញ្ហាសង្គមនាពេលនោះ បានចាត់ទុក ប៉ុល ពត ថាជាអ្នកដែលបានដោះស្រាយបញ្ហាសម្រាប់ខ្លួនឯងដែលប្រជាជនមិនអាចធ្វើដូច្នេះបានសម្រាប់ខ្លួនរបស់ពួកគេ ។ ប្រជាជនទាំងនេះបានបៀមទុកក្នុងទ្រូងនូវ "របួសផ្លូវចិត្ត" អស់ជាច្រើនឆ្នាំនៅក្នុងក្រញាំដៃនៃរដ្ឋាភិបាលរបស់ខ្លួន ។ ប្រជាជនទាំងនេះបានរង់ចាំឲ្យ ប៉ុល ពត ប្រមែប្រមូលប្រជាជនមកឲ្យមូលមីរ ដើម្បីនាំមកនូវការផ្លាស់ប្តូរសណ្តាប់ធ្នាប់នៅក្នុងសង្គមកម្ពុជា ក្នុងគោលបំណងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាកសិករក្រខ្សត់និងមិនចេះអក្សរ ។



ការយល់ស្របរបស់ប្រជាកសិករទៅលើគំនិតនេះគឺជាគ្រឹះសម្រាប់បង្កើតចលនាកុម្មុយនិស្តដើម្បីសម្រេចជ័យជម្នះ ។ ប្រជាកសិករខ្មែរមានឆន្ទៈចង់កាន់អាវុធនិងលះបង់ជីវិតក្នុងការប្រយុទ្ធជាមួយអ្វីដែលខ្លួនយល់ថាជាអានុភាពអវិជ្ជមាន ។ ប្រជាកសិករខ្មែរដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធសង្គម សេដ្ឋកិច្ច និងនយោបាយ ត្រូវបានចាត់ទុកដូចជាខ្ញុំគេអីចឹង ហើយមិនដែលមានតួនាទីនៅក្នុងមជ្ឈដ្ឋានអ្នកដឹកនាំឡើយ ។ ប៉ុល ពត យល់ចិត្តកូនចៅ និងបានលើកឡើងនូវគំនិតឲ្យតម្លៃខ្លួនឯងប្រាប់ដល់កូនចៅរបស់ខ្លួនដែលជាប្រជាកសិករ នៅពេលដែលក្រុមអ្នកកាន់អំណាចមើលងាយមើលថោកប្រជាកសិករ ។ ប៉ុល ពត បានលើកតម្កើងគំនិតនិងឲ្យតម្លៃលើខ្លួនឯងតាមរយៈការអនុញ្ញាតឲ្យប្រជាកសិករចូលរួមយ៉ាងសកម្មក្នុងការសម្រេចអនាគតនៃនយោបាយរបស់កម្ពុជា ។ ដោយចូលរួមនៅក្នុងចលនាតស៊ូប្រដាប់អាវុធប្រឆាំងនឹងរបបពុករលួយ ប្រជាកសិករទាំងនេះត្រូវបានដឹកនាំឲ្យមានអារម្មណ៍ថាខ្លួនមានឱកាសក្នុងការធ្វើឲ្យមានការប្រែប្រួលការងារប្រវត្តិសាស្ត្រជាលើកទីមួយហើយ ។ ប្រជាកសិករចាត់ទុកការចូលរួមយ៉ាងសស្រាក់សស្រាំនៅក្នុងដំណើរការនយោបាយកម្ពុជា ថាជាទម្រង់មួយដែលខ្លួនពេញចិត្តបំផុត ។

ប៉ុល ពត បានសម្តែងចេញនូវគុណភាពនិងលក្ខណៈសម្បត្តិជាអ្នកដឹកនាំដែលមានអំណាចទាក់ទាញ ។ ប៉ុល ពត បានធ្វើទំនាក់ទំនងតាមលក្ខណៈសាមញ្ញ ហើយតែងតែនិយាយត្រង់ៗដោយឥតលាក់លៀម ។ សារដែលចេញពីមាត់ ប៉ុល ពត ទៅ

កាន់ប្រជាជន រួមជាមួយអំពើដែល ប៉ុល ពត បានធ្វើ ព្រមទាំងរបៀបរបបរស់នៅ បានធ្វើឲ្យ ប៉ុល ពត ក្លាយជាមនុស្សម្នាក់ដែលមិនអាចពុករលួយ និងជាមនុស្សម្នាក់ដែលមានការឈឺឆ្អាលអំពីសុខទុក្ខរបស់ប្រជាជនក្រីក្រ ។ ប៉ុល ពត គឺជាមនុស្សដែលមានសមត្ថភាពក្នុងការយល់ចិត្តប្រជាកសិករក្រីក្រ ។ នៅពេលដែល ប៉ុល ពត និយាយអំពីរដ្ឋាភិបាលពុករលួយ ប្រជាជនឆាប់ទទួលយកខ្លឹមសារនេះណាស់ ពីព្រោះខ្លួនគេផ្ទាល់ក៏មើលឃើញអំពើពុករលួយផ្ទាល់ភ្នែកដែរ ។ ប្រជាជនមានចិត្តអន្ទះសាចង់ក្រសោបគំនិតនេះណាស់ ។ ប៉ុល ពត បានបញ្ចូលគំនិតដល់អ្នកដែលដើរតាមខ្លួនឲ្យទុកចិត្តលើខ្លួនឯង ហើយមានលទ្ធភាពឃោសនាឲ្យអ្នកទាំងនោះងើបឡើងតស៊ូប្រយុទ្ធប្រឆាំង“ខ្មាំងសត្រូវ” ។

## *សេចក្តីសន្និដ្ឋាន*

ដូចដែលលោក ដាវីដ ឆេនដល័រ បានឲ្យជាយោបល់នៅក្នុងប្រវត្តិរូបនយោបាយរបស់ ប៉ុល ពត ដែលមានចំណងជើងថា“បងលេខ១”ស្រាប់ ប៉ុល ពត ឬ សាឡុត ស គឺស្ថិតនៅក្នុងចំណោមថ្នាក់ដឹកនាំដែលមានចក្ខុវិស័យហួរហៀរនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ដែលជាប្រវត្តិសាស្ត្រពោរពេញទៅដោយការជិះជាន់កេងប្រវ័ញ្ចពីសំណាក់មហាអំណាចបរទេសទាំងជិតទាំងឆ្ងាយ ។ ប៉ុល ពត ធ្លាប់បានបញ្ចេញប្រតិកម្មប្រឆាំងនឹងភាពខិនលំទោនញាបៗនិងស្លូតបូតមិនមាត់ករបស់ប្រជាជនខ្មែរ ។ ប៉ុល ពត មិនសូវសប្បាយចិត្តចំពោះអំណាចប្រពៃណីនៃរាជវង្សកម្ពុជា និងការទម្រន់របស់រាជវង្សនេះ ។ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ ប៉ុល ពត បានប្រកាន់យកលទ្ធិកុម្មុយនិស្ត ជាបណ្តុំបច្ចេកទេសផ្តល់អំណាចនិងរំដោះ ដែលអាចយកមកអនុវត្តនៅក្នុងប្រទេសកម្ពុជាដើម្បីបំបាត់អំណាចប្រពៃណីអយុត្តិធម៌សង្គមនិងសេដ្ឋកិច្ចនិងចរិតញាបៗ ។ តួនាទីដ៏សំខាន់របស់អ្នកចេះដឹងដូចជា ប៉ុល ពត នៅក្នុងដំណើរការនេះ គឺជាការរំលាយប្រជាកសិករខ្មែរឲ្យទៅជាឧបករណ៍ដ៏សំខាន់ ជាមធ្យោបាយដែលនាំដល់ការសម្រេចការផ្លាស់ប្តូរសង្គម ។ អំណាចទាក់ទាញរបស់ ប៉ុល ពត ដើរតួយ៉ាងសំខាន់នៅក្នុងការកសាងកម្លាំងក្នុងចំណោមប្រជាកសិករក្រីក្រនិងមិនចេះអក្សរ ដើម្បីមកបម្រើបុព្វហេតុរបស់ខ្លួន។ ជាទូទៅ ប្រជាជនប្រភេទនេះនៅក្នុងសង្គមកម្ពុជានៅតែមានកក្តីភាពចំពោះ ប៉ុល ពត រហូតដល់ពេល ប៉ុល ពត ស្លាប់នៅខែមេសា ឆ្នាំ១៩៩៨ ។

ពេញមួយឆាកជីវិតរបស់ខ្លួន ប៉ុល ពត ហាក់ដូចជាប្រកាន់យកនូវអាកប្បកិរិយារបស់ខ្លួនឲ្យស្របទៅនឹងប្រជាជន ឲ្យត្រូវដូចកាលដែលអ្នកដើរតាមខ្លួនសង្ឃឹមទុក ។ ការណ៍នេះធ្វើឲ្យក្លាយទៅជា“អំពើប្រល័យពូជសាសន៍ឆ្កួតលេលា” មួយដែលពិបាកនឹងធ្វើដូច ។ កាយវិការដ៏ប៉ិនប្រសប់ទាំងនេះ បង្ហាញពីការយល់ដឹងទូលំទូលាយទៅលើសញ្ញាណជាសារវន្តដែលចង់និយាយថា មេដឹកនាំស័ក្តិសិទ្ធិត្រូវតែបំពេញតាមតម្រូវការរបស់មហាជន ។ ប្រជាជនភាគច្រើន ពិសេសប្រជាកសិករខ្មែរ នៅតែប្រកាន់យកនូវគំនិត“សង្គមថ្មី”លុះដល់ទីបញ្ចប់ ។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការបែងចែងរវាងអំណាចទាក់ទាញដ៏សមគួររបស់ ប៉ុល ពត និងចំនួនមនុស្សស្លាប់ដោយសាររបប ប៉ុល ពត នៅតែជាប្រស្នាដែលមានលក្ខណៈលុបទៅលុបមកអាស្រ័យទៅតាមនិន្នាការនៃការបកស្រាយ ។ ប៉ុល ពត បាននិយាយទៅកាន់លោក ណេតថាយ័រ កាលពីឆ្នាំ១៩៩៧ថា “មើលមកខ្ញុំតើខ្ញុំជាមនុស្សសាហាវដែរឬទេ? ខ្ញុំមានមនសិការច្បាស់លាស់” ។ នៅចុងបញ្ចប់ អ្នកសង្កេតប្រវត្តិសាស្ត្រកម្ពុជាបច្ចុប្បន្នមិនអាចមើលរំលងការមិនសមនឹងកើតឡើងដ៏សំខាន់មួយទេ ។ បើក្រឡេកមើលទៅខាងក្រោយបុរសភ្ញាក់រឭកបដិវត្តន៍ដែលកើតចេញពីកំហឹងទៅលើអំណាចប្រពៃណី គឺគ្មានធ្វើអ្វីល្អលើសអ្នកដឹកនាំមុនៗ ។ ការដឹកនាំរបស់ ប៉ុល ពត បានប្រែទៅជាសោកនាដកម្មមហាសែនអាក្រក់ជាងអ្នកដឹកនាំមុនៗឆ្ងាយណាស់ ។ ការស្រឡាញ់អំណាចដ៏សោះកក្រោះរបស់ ប៉ុល ពត បានធ្វើឲ្យជនរួមជាតិខ្មែរស្លាប់អស់ជាងមួយលាននាក់ ឬក្នុងចំណោមមនុស្ស៧នាក់ មានម្នាក់ស្លាប់ ក្នុងរយៈពេលមិនដល់៤ឆ្នាំផង ។ ជីវិតជនស្លូតត្រង់ជាច្រើនស្លាប់ដោយគ្មានន័យ និងស្លាប់ដោយឈឺចាប់ដែលមិននឹកស្មានដល់ ។ អំពើរបស់មនុស្សម្នាក់បានធ្វើឲ្យសង្គមទាំងមូលផ្លាស់ប្តូរ ។ នេះមិនមែនជាលើកទី១ទេដែលមនុស្សជាតិទទួលរងនូវភាពអយុត្តិធម៌បែបនេះ ហើយក៏មិនប្រាកដថាសោកនាដកម្មនេះជាលើកចុងក្រោយសម្រាប់មនុស្សជាតិទូទៅដែរ ។

**សម សុជាតិ**

# រឿងក្តី មីឡូសីវិច
# និងការដាក់ឱ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋសង្គ្រាម

នៅក្នុងខណៈដែលការជំនុំជម្រះក្តី មីឡូសីវិច បានចាប់ផ្តើម មានអ្នកខ្លះនិយាយថា នេះគឺជាការចាប់ផ្តើម«សករាជថ្មីនៃការដាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់អន្តរជាតិ» ដែលជាការបង្ហាញឲ្យឃើញអំពី«សាកលភាវូបនីយកម្មយុត្តិធម៌» ។ នៅក្នុងអំឡុងសប្តាហ៍ទីមួយនៃការជម្រះក្តី រដ្ឋអាជ្ញាទីក្រុងឡាអេ លោកស្រី កាឡាឌែល ប៉ុនតេ បានទទូចថានេះមិនមែនជាការជម្រះក្តីក្នុងបែបផែននយោបាយទេ ។ មីឡូសីវិច ពើបប្រទះនូវការលំបាកមួយចំពោះធម្មានុរូបនៃតុលាការនេះ ។

បញ្ហាដែលកើតឡើងនៅទីនេះគឺការទាមទារទៅវិញទៅមករវាងអធិបតេយ្យភាពជាតិ និងសិទ្ធិមនុស្សជាសាកល ។ ប្រសិនបើយើងបានចូលដល់សករាជថ្មីនៃការដាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់អន្តរជាតិ វាមើលទៅមានលក្ខណៈដូចគ្នាគួរឲ្យកត់សម្គាល់ទៅនឹងទ្រឹស្តីដែលថាច្បាប់អនុវត្តបានតែចំពោះបុគ្គលមួយចំនួនតែប៉ុណ្ណោះ ។ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ អង្គការសហប្រជាជាតិដែលទទួលបានការគាំទ្រពីសំណាក់មជ្ឈដ្ឋានសិទ្ធិមនុស្ស បានជំរុញឲ្យមានសណ្តាប់ធ្នាប់ថ្មីមួយដោយផ្អែកលើវិធានសម្រាប់ដឹកនាំប្រទេស ។ ជាការគួរឲ្យសោកស្តាយ វិធានទាំងនោះត្រូវបានយកមកអនុវត្តតែចំពោះបុគ្គលមួយចំនួនប៉ុណ្ណោះ ធ្វើឲ្យ«សករាជថ្មីនៃការដាក់ឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មសង្គ្រាម»ជាការទាមទារជាជាងសភាពពិតជាក់ស្តែង ។

សករាជថ្មីដែលត្រូវបានលើកឡើងនេះ បានចាប់ផ្តើមនៅពេលដែលតុលាការនៅទីក្រុងឡាអេ នៅប្រទេសអេស្ប៉ាញ នៅប្រទេសប៊ែលហ្សិក និងសហរដ្ឋអាមេរិក បញ្ចេញយោបល់ប្រឆាំងជាមួយនឹងភាពមិនអាចរំលោភបាននៃអធិបតេយ្យភាពជាតិ ដោយពិចារណាទៅលើរឿងក្តីប្រឆាំងនឹងមេដឹកនាំជាតិ ស្លូបូដាន មីឡូសីវិច, អារៀលសារ៉ូន, អូសហ្កុស្តូ, ពីណូចេ អតីតរដ្ឋមន្ត្រីការបរទេស ហេនរី ឃីស៊ីងជើ, ហ្វ៊ីដែលកាស្ត្រូ នៃប្រទេសគុយបា ។ ប្រការមិនគួរឲ្យកើតឡើងនោះគឺថាក្នុងខណៈដែលក្រុមធ្វើការខាងសិទ្ធិមនុស្សនិងអ្នកច្បាប់ស៊ីវិលកំណត់និងពង្រីកក្រុមថ្មីនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ មេដឹកនាំលោកខាងលិចមិនអាចប្រមូលផ្តុំសេចក្តីសម្រេចដើម្បីទប់ស្កាត់អំពើឃោរឃៅក្នុងទ្រង់ទ្រាយធំនៅក្នុងសង្គ្រាមស៊ីវិលនៅអតីតយូហ្គោស្លាវី រ៉ាន់ដា ទីម័រខាងកើត និងសេរ៉ាឡេអូនឡើយ ។ នៅពេញមួយទសវត្សរ៍ឆ្នាំ ១៩៩០ ភាពខុសគ្នាដ៏សំខាន់រវាងទាហាននិងជនស៊ីវិលស្ទើរតែបាត់ស្រមោលទៅហើយនៅតាមកន្លែងមួយចំនួនដូចជានៅទីក្រុងឌីលី ទីក្រុងសារ៉ាយេវ៉ូ និងទីក្រុងហ្វ្រីថោន ។

មានផលប្រយោជន៍តិចតួចតែប៉ុណ្ណោះក្នុងការធ្វើអន្ត-រាគមន៍តាមផ្លូវយោធា សូម្បីតែជាមួយជនស៊ីវិលដែលជាជនរងគ្រោះនៃអំពើឃោរឃៅប្រល័យពូជសាសន៍ក៏ដោយ ។ ប៉ុន្តែអង្គការសហប្រជាជាតិបែរជាសន្យាជាមួយជនរងគ្រោះថានឹងរកយុត្តិធម៌ឲ្យក្នុងទម្រង់ជាការជម្រះក្តីឧក្រិដ្ឋកម្មសង្គ្រាមក្រោយពីសោកនាដកម្មត្រូវបានបញ្ចប់ ។ ចាប់តាំងពីឆ្នាំ១៩៩៣មក អង្គការសហប្រជាជាតិបានចំណាយថវិការហូតដល់ជាងមួយកោដិដុល្លារដើម្បីកាត់ទោសបុគ្គលមិនដល់៥០នាក់ផង មុនពេលមានតុលាការនៅទីក្រុងឡាអេនៃប្រទេសហុល្លង់និងទីក្រុងអារូហ្សានៃប្រទេសតង់ហ្សានី ។ ក៏ប៉ុន្តែការយកយុត្តិធម៌មកអនុវត្តជាក់ស្តែងគឺមានលក្ខណៈរើសមុខមិនស្មើភាពគ្នា ដែលទាំងអស់នេះជាការបង្ហាញឲ្យឃើញថា វិធានច្បាប់ខាងលើអនុវត្តបានតែចំពោះបុគ្គលមួយចំនួនប៉ុណ្ណោះ ។

ជិត២០ឆ្នាំក្រោយពីខ្មែរក្រហមបានសម្លាប់ប្រជាជន

កម្ពុជាអស់ពីរលាននាក់ អង្គការសហប្រជាជាតិបានចាប់ផ្តើមចរចាជាមួយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ទៅលើបញ្ហាបង្កើតអង្គជំនុំជម្រះក្តីដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនៅរស់រានមានជីវិត ។ ក្រោយពីចរចាគ្នាអស់រយៈពេល៤ឆ្នាំ អង្គការសហប្រជាជាតិបានប្រកាសនៅឆ្នាំ២០០២ថា ខ្លួនលែងចូលរួមក្នុងដំណើរការជម្រះក្តីមេដឹកនាំខ្មែរក្រហមទៀតហើយ ពីព្រោះ «តុលាការកម្ពុជានឹងមិនអាចធានាបាននូវឯករាជ្យភាព ភាពគ្មានលម្អៀង និងសម្រេចតាមគោលដៅឡើយ...» ។ អ្នកគាំទ្រសិទ្ធិមនុស្សព្រមទាំងបុគ្គលជាច្រើននាក់ទៀតក្នុងមជ្ឈដ្ឋានសិទ្ធិមនុស្ស បានចាត់ទុកថាសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិថាជាការប្រកាន់ខ្ជាប់នូវមូលដ្ឋាន«សុចរិត»របស់ខ្លួន ។

ក្រោយពីវៀតណាមបានផ្តួលរំលំខ្មែរក្រហមនៅឆ្នាំ១៩៧៩ ទាំងអង្គការសហប្រជាជាតិនិងរដ្ឋការលោក ជីមី ខាតធ័រ ពុំបានគាំទ្ររាល់កិច្ចខិតខំប្រឹងប្រែងនាំយកខ្មែរក្រហមមកកាត់ទោសឡើយ ។ នយោបាយខ្មែរក្រហមធ្វើឲ្យបាត់បង់ជីវិតប្រជាជនកម្ពុជាយ៉ាងហោចណាស់ពីរលាននាក់ ។ សហរដ្ឋអាមេរិកបានបោះឆ្នោតគាំទ្រម្តងហើយម្តងទៀត ដើម្បីឲ្យរបបប្រល័យពូជសាសន៍រក្សាអាសនៈកម្ពុជានៅអង្គការសហប្រជាជាតិពេញមួយទសវត្សរ៍ឆ្នាំ១៩៨០ ។ ទោះបីជា អៀង សារី ត្រូវបានកាត់ទោសប្រហារជីវិតដោយកំបាំងមុខនៅឆ្នាំ១៩៧៩ ក៏ពិតមែន ប៉ុន្តែ អៀង សារី នៅតែធ្វើជាតំណាងរបស់កម្ពុជានៅអង្គការសហប្រជាជាតិដដែល ។

ជាការច្បាស់ណាស់ អង្គការសហប្រជាជាតិឬ«សមត្ថកិច្ចសាកល»ធ្វើអ្វីខ្មែរក្រហមមិនបានឡើយ មានតែចំណាត់ការផ្នែកនយោបាយដាច់អហង្ការរបស់សម្តេច ហ៊ុន សែន ក្នុងឆ្នាំ១៩៩៦ និងឆ្នាំ១៩៩៧ប៉ុណ្ណោះ ដែលធ្វើឲ្យខ្មែរក្រហមទទួលបរាជ័យ ។

## ការលើកលែងទោសគឺជាតម្លៃនៃសន្តិភាពនៅកម្ពុជា

សម្តេច ហ៊ុន សែន បានផ្តល់ការលើកលែងទោសដល់មេដឹកនាំនិងអ្នកចុះចូលមួយចំនួននៅឆ្នាំ១៩៩៦ និងឆ្នាំ១៩៩៧ ដោយមានការជំទាស់ពីសំណាក់រដ្ឋាភិបាលលោកខាងលិច និងក្រុមសិទ្ធិមនុស្សលោកខាងលិច ។ ពេលនោះ«សមត្ថកិច្ចសាកល» ត្រូវប៉ះទង្គិចជាមួយនឹងអធិបតេយ្យភាពជាតិហើយ? នៅពេលដែលអង្គការសហប្រជាជាតិសុំឲ្យបង្កើតអង្គជំនុំជម្រះនៅប្រទេសទីបីក្រោមការជួយជ្រោមជ្រែងរបស់ខ្លួនផ្ទាល់នៅឆ្នាំ១៩៩៩ ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មសង្គ្រាមដែលប្រព្រឹត្តឡើងដោយមេដឹកនាំខ្មែរក្រហម សម្តេច ហ៊ុន សែន មិនយល់ព្រមចំពោះសំណើនេះឡើយ ។ បុរសមានអំណាចរបស់កម្ពុជាបានទាញហេតុផលចំៗដោយឥតលាក់លៀមថា វាសនារបស់មេដឹកនាំខ្មែរក្រហមគឺជាបញ្ហានយោបាយ មិនមែនជារឿងច្បាប់ទេ ។ «ដូច្នេះប្រសិនបើអ្នកច្បាប់បានធ្វើឲ្យវិវត្តនិងផ្លាស់ប្តូរទាំងផ្នែកសីលធម៌និងនយោបាយ ខ្ញុំគិតថាគេគួរតែឈប់ធ្វើជាអ្នកច្បាប់ ហើយចូលមកធ្វើការខាងនយោបាយវិញ» ។

បទដ្ឋានត្រួតត្រានៃច្បាប់អន្តរជាតិបច្ចុប្បន្នគឺមានដាក់ស្តែងក្រោយពីមានសង្គ្រាមស៊ីវិលបង្ហូរឈាមនៅប្រទេសសេរ៉ាឡេអូន ។ ក្រោយពី ហ្វូឌី សានកូស ដែលជាមេដឹកនាំរណសិរ្សរួបរួមបដិវត្តដ៏ល្បីអសោចត្រូវបានចាប់ខ្លួនដោយជនស៊ីវិលនៅឆ្នាំ១៩៩៩ អង្គការសហប្រជាជាតិបានសន្យាថានឹងបង្កើតតុលាការឧក្រិដ្ឋសង្គ្រាមមួយ ។ ទោះបីជាអង្គការសហប្រជាជាតិបានបង្កើតតុលាការនៅប្រទេសសេរ៉ាឡេអូនក៏ដោយ ប៉ុន្តែមកទល់នឹងពេលនេះអង្គការសហប្រជាជាតិមិនទាន់បានកាត់ទោស សានកូស នៅឡើយទេ ។ ថវិកាសម្រាប់ដំណើរតុលាការទាំងមូលត្រូវបានកាត់បន្ថយពី១១៨លាន មកត្រឹម៥៧លានដុល្លារ ។

ក្រោយពីសតវត្សរ៍ប្រកបដោយការបង្ហូរឈាមគ្នាដ៏ធ្ងន់ធ្ងរបំផុតក្នុងប្រវត្តិសាស្ត្រត្រូវបានបញ្ចប់ «សហគមន៍អន្តរជាតិ» បានចាប់ផ្តើមទទួលស្គាល់នូវអំពើគួរឲ្យព្រឺព្រួចដែលធ្លាក់មកលើបុគ្គលដែលគ្មានអំណាចនិងគ្មានសារសំខាន់ផ្នែកនយោបាយ ។ នៅក្នុងស្រមោលដ៏វែងអន្លាយនៃព្រឹត្តិការណ៍ថ្ងៃទី១១ ខែកញ្ញា អ្នកទោសដែលជាក្រុមអង្គការអាល់កេដាកំពុងតែប្រឈមមុខនឹងតុលាការយោធានោះ ការអះអាងអំពីសមត្ថកិច្ចសកលគឺជាការអះអាងមួយដែល«យកល្អតែមាត់ខាងក្រៅតែចិត្តផ្សេង» ។ ប្រសិនបើការធ្វើបត្យាប័ននិងការជំនុំជម្រះក្តីស្លូបូដានមីឡូសីវិច ជាការចាប់ផ្តើម «ទំព័រសករាជថ្មីនៃការដាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់អន្តរជាតិ»មែននោះ វាគ្មានអ្វីឲ្យប្លែកណាស់ណាពីសករាជមុនឡើយ ។ **ភីតធ័រ ម៉ាឃ្យែរ**

# ពៅ ហុង៖ បាត់បង់គ្រួសារ ដោយសារមានពូជពង្សជាវៀតណាម




ពៅ ហុង អាយុ៣៦ឆ្នាំ មានស្រុកកំណើតនៅភូមិអង្គរយស ឃុំព្រៃកអន្ទះ ស្រុកទីរួមខេត្តខេត្តព្រៃវែង។ ឪពុកគាត់ឈ្មោះ អៀង ពៅ ជាជនជាតិខ្មែរ និងម្តាយឈ្មោះ ម៉េង ស៊ីម ជាប់សែស្រឡាយវៀតណាម (ដោយមានជីតាទួតជាជនជាតិចិននិងជីដូនទួតជាជនជាតិវៀតណាម)។ មូលហេតុដូច្នេះហើយបានជាបងប្អូនបង្កើតនិងសាច់ញាតិខាងម្តាយរបស់ ពៅ ហុង ទាំងអស់ត្រូវខ្មែរក្រហមយកទៅសម្លាប់ស្ទើរតែផុតពូជ ក្រោមរូបភាពយកទៅ“រៀនសូត្រ”។ ក្នុងចំណោមសាច់ញាតិរបស់ ហុង ទាំងអស់ គឺមានតែពីរនាក់គត់ដែលមានសំណាងរួចផុតពីសេចក្តីស្លាប់ (ពៅ ហុង និងម្តាយធំរបស់គាត់)។ ពៅ ហុង នៅមានជីវិតរស់នៅរហូតមកដល់សព្វថ្ងៃ ដោយសារតែម្តាយបង្ខំឲ្យលួចរត់មកផ្ទះវិញដើម្បីមើលថែទាំជំងឺឪពុក។

នៅចុងឆ្នាំ១៩៧៥ ប្រធានភូមិអង្គរយសឈ្មោះ តាមួន និង ស៊ិន បានដើរប្រកាសប្រាប់អាណិកជនវៀតណាមនិងប្រជាជនដែលជាប់សែស្រឡាយវៀតណាមនៅក្នុងភូមិថា “អង្គការត្រូវបញ្ជូនទៅប្រទេសវៀតណាមវិញ”។ កាលនោះក្រុមគ្រួសាររបស់ ហុង រួមមានក្រុមគ្រួសារខាងយាយទួត តាទួត ជីដូន ជីតា ម្តាយធំ ឪពុកធំ ម្តាយមីង និងគ្រួសាររបស់ ហុង រួមជាមួយអាណិកជនវៀតណាមនៅភូមិអង្គរយសជាច្រើនគ្រួសារទៀត បានធ្វើដំណើរតាមទូកចាកចេញពីភូមិអង្គរយសឆ្ពោះទៅក្អមសំណ ស្ថិតនៅក្នុងស្រុកលើកដែក តំបន់២៥ ដែលជាព្រំដែនរវាងកម្ពុជានិងវៀតណាម ដោយមានការដឹកនាំពីសំណាក់កម្មាភិបាលខ្មែរក្រហម។ “ក្អមសំណ” គឺជាកន្លែងដែលភាគីកម្ពុជាបញ្ជូនអាណិកជនវៀតណាម និងក៏ជាទីកន្លែងដែលភាគីវៀតណាមមកទទួលអាណិកជនរបស់ខ្លួននៅទីនោះដែរ។ បន្ទាប់ពីក្រុមគ្រួសាររបស់ ហុង បានមកដល់ក្អមសំណនិងស្នាក់នៅទីនោះប្រមាណ៥យប់ ទើបខាងភាគីវៀតណាមមកប្រាប់ថា “ប្រជាជនទាំងអស់សុទ្ធតែជាជនជាតិខ្មែរ ដូច្នេះខាងវៀតណាមមិនទទួលយកទេ”។ កម្មាភិបាលខ្មែរក្រហមបានប្រាប់ប្រជាជនទាំងអស់ឲ្យវិលត្រឡប់មកភូមិកំណើតវិញ។ ក្រុមគ្រួសាររបស់ ហុង បានធ្វើដំណើរត្រឡប់មកអង្គរយសវិញ។ នៅពេលមកដល់ភូមិអង្គរយស គ្រួសាររបស់ ហុង ត្រូវរស់នៅនិងធ្វើស្រែចម្ការជាធម្មតាដូចប្រជាជនក្នុងភូមិ។

នៅដើមឆ្នាំ១៩៧៧ កងឈ្លបឃុំព្រៃកអន្ទះពីរបីនាក់បានមកហៅជីតាទួតនិងយាយទួតរបស់ ហុង ទៅរៀនសូត្រ ហើយក៏បាត់ខ្លួនរហូតមក។ ហុង បាននិយាយថា “ខ្ញុំមិនបានដឹងថាកងឈ្លបយកជីតាទួតនិងយាយរបស់ខ្ញុំទៅសម្លាប់នៅទីណាទេ”។

នៅពាក់កណ្តាលឆ្នាំ១៩៧៧ កងឈ្លបឃុំព្រៃកអន្ទះបានមកហៅកូនៗយាយទួតរបស់ ហុង ទៅរៀនសូត្រទៀត ដែលក្នុងនោះមានម្តាយធំ ឪពុកធំ ម្តាយមីង និងឪពុកមាររបស់ ហុង ម្នាក់ផង។ កងឈ្លបមិនបានយកម្តាយរបស់ ហុង ទៅទេ ដោយសារគាត់ទើបតែឆ្លងទន្លេរួច។ រយៈពេល១៥ថ្ងៃក្រោយ កងឈ្លបបានមកយកម្តាយរបស់ ហុង និងបងប្អូនរបស់ ហុង ៥នាក់ទៅទៀត ប៉ុន្តែប្អូនរបស់ ហុង ពីរនាក់បានគេចទៅពួននៅគុម្ពឫស្សី។ ដោយសារកងឈ្លបបានយកជីតាទួត យាយទួតនិងសាច់ញាតិទៅអស់ហើយ គ្រួសាររបស់ ហុង បានពិភាក្សាគ្នាថា “ប្រសិនបើគេមកយកទៅ ឲ្យយកតែម្តាយទៅចុះ ចំណែកបងប្អូនយើងមិនបាច់ទៅទេ យើងត្រូវតែរត់គេចទាំងអស់គ្នា”។ ប្រធានភូមិឈ្មោះ មួន មិនសុខចិត្តនៅខណៈដែលកងឈ្លបមកយកគ្រួសាររបស់ ហុង ទៅរៀនសូត្រ ហើយមិនឃើញប្អូន

របស់ ហុង ពីរនាក់ទៀត ។ មួន ក៏តាមហៅប្អូនៗទាំងពីរនាក់របស់ ហុង យកទៅលុះត្រាតែបាន ។ ក្នុងថ្ងៃដែលប្រធានភូមិមកយកម្តាយរបស់ ហុង ទៅ ហុង មិនបាននៅផ្ទះទេ ។ ហុង ត្រូវបានគណៈកងចាត់តាំងទៅមើលក្របីនៅឯវាលស្រែប្រាំង លុះពេលល្ងាចទើប ហុង ត្រឡប់មកផ្ទះវិញ ។ ពេលដែល ហុង កំពុងហូបបាយនៅរោងបាយសហករណ៍ភូមិអង្គរយស មួន បានមកហៅ ហុង ហើយដឹកដៃ ហុង ត្រឡប់មកផ្ទះវិញ ។ មួន បាននិយាយថា «អ្នកត្រូវទៅជាមួយម៉ែអ្នក» ។ ហុង មិនដឹងថា មួន មានការអ្វីទេ ។ ព្រលប់ៗទៅហើយ កងឈ្លបពីរនាក់បានយកកងមកឌុប ហុង និងប្អូនៗ២នាក់ទៀតចេញពីភូមិអង្គរយសឆ្ពោះទៅវត្តព្រែកតាំ ស្ថិតនៅក្នុងឃុំព្រែកអន្ទះដែរ ។ វត្តព្រែកតាំជាមន្ទីរឃុំឃាំងរបស់ឃុំព្រែកអន្ទះ ។ ម្តាយរបស់ ហុង និងអាណិកជនវៀតណាមដទៃទៀត ត្រូវខ្មែរក្រហមយកទៅដាក់ឃុំឃាំងនៅទីនោះ ។ ម្តាយរបស់ ហុង បាននិយាយប្រាប់ ហុង ថា គាត់នឹកអាណិតឪពុករបស់ហុងណាស់ព្រោះឪពុករបស់ ហុង មានជំងឺធំពោះ ។ ឪពុករបស់ ហុង មានជំងឺនេះតាំងពីពេលដែលគណៈឃុំព្រែកអន្ទះឈ្មោះ យស ប្រើគាត់ឲ្យទៅជីកព្រែកអង្គរយសម្ល៉ោះ ។ ដោយសារតែគាត់ធ្វើការធ្ងន់ហួសកម្លាំង ទើបបណ្តាលឲ្យគាត់កើតជំងឺនេះ ។ ជារៀងរាល់យប់គាត់នោមប្រហែលមួយបំពង់ទឹកត្នោតដែលធ្វើអំពីស័ង្កសីមានចំណុះ២លីត្រ ។ គាត់សម្រាន្តតែលើផ្ទះ ទៅណាមកណាមិនរួចទេ ។ ម្តាយរបស់ ហុង បានខ្សឹបប្រាប់ ហុង ថា «កូនឯងទៅផ្ទះមើលថែទឹកក្តៅទឹកត្រជាក់ឪពុកឯងវិញចុះ» ។ មនុស្សដែលខ្មែរក្រហមយកមកដាក់នៅវត្តព្រែកតាំត្រូវអត់បាយពេញមួយថ្ងៃរហូតដល់ម៉ោងប្រមាណ១០យប់ទើបសន្តិសុខហៅឲ្យទៅហូបបបរ ។ ឆ្លៀតពេលនោះ ហុង លួចចុះតាមជណ្តើរសាលាឆាន់មកខាងក្រោយវត្តដែលសុទ្ធតែផ្លូវខ្មោច ។ ហុង ខ្លាចខ្លាំងណាស់ ប៉ុន្តែខំកាត់ចិត្តដើរកាត់ព្រៃល្បាស់កាត់វាលឆ្លងទឹកវង្វេងផ្លូវរហូតដល់ម៉ោង៣ទៀបភ្លឺទើបមកដល់ផ្ទះ ។ ពេល ហុង មកដល់ផ្ទះហើយ ប្រធានភូមិនិងកងឈ្លបមកតាមចាប់ទៀត ។ ហុង គេចមកស្នាក់នៅផ្ទះអ៊ំស្រីដែលប្តីរបស់គាត់ត្រូវជាបងបង្កើតរបស់ម្តាយហុង ។ អ៊ំស្រីរបស់ ហុង មានកូនប្រុសម្នាក់ ។ នៅពាក់កណ្តាលឆ្នាំ១៩៧៧ កងឈ្លបមកយកប្តីរបស់គាត់ទៅរៀនសូត្រយកទាំងកូនប្រុសរបស់គាត់ទៅដែរ ។ ចំពោះរឿងនេះ ហុង ធ្លាប់បានឮប្រធានភូមិឈ្មោះ មួន និង សុិន និយាយថា «ប្រសិនបើគ្រួសារដែលមានប្តីជាជនជាតិខ្មែរហើយប្រពន្ធជាជនជាតិវៀតណាម គ្រួសារនោះត្រូវយកប្រពន្ធនិងកូនទៅរៀនសូត្រ ។ ចំណែកគ្រួសារដែលមានប្តីជាវៀតណាមប្រពន្ធជាខ្មែរ អង្គការយកតែប្តីម្នាក់ទៅរៀនសូត្រ» ។ ប៉ុន្តែដោយឡែកគ្រួសារអ៊ំស្រីរបស់ ហុង ប្តីជាប់ខ្សែវៀតណាម ចំណែកប្រពន្ធជាជនជាតិខ្មែរកាត់ចិន បែរជាត្រូវខ្មែរក្រហមយកប្តីនិងកូនរបស់គាត់ទៅរៀនសូត្រទាំងពីរនាក់តែម្តង ។ នៅពេលដែលកងឈ្លបមកយកប្តីរបស់គាត់ កូនប្រុសរបស់គាត់បានគេចនៅជាមួយគាត់ ប៉ុន្តែក្រោយមក ប្រធានភូមិឈ្មោះ មួន តាមមកយកកូនគាត់ទៅជាមួយម្តាយរបស់ ហុង ខាងតែបាន ។ នៅពេលដែល ហុង ទៅនៅជាមួយអ៊ំស្រី កងឈ្លបនៅតែបន្តតាមចាប់ ហុង ដដែល ។ ហុង បានគេចខ្លួនទៅនៅផ្ទះម្តាយធំម្នាក់ទៀតនៅភូមិកំពង់ឫស្សី ឃុំកំពង់ឫស្សី ក្នុងស្រុកជាមួយគ្នាដែរ ។ ម្តាយធំរបស់ ហុង ម្នាក់នេះហើយដែលបានរួចផុតពីការកាប់សម្លាប់របស់ខ្មែរក្រហម ។ ហុង រស់នៅទីនោះមិនបានប៉ុន្មានផងកងឈ្លបនៅទីនោះតាមចាប់ ហុង ទៀត ។ ម្តាយធំរបស់ ហុង ក៏ប្រាប់ ហុង ឲ្យត្រឡប់មកផ្ទះវិញ ។ ហុង ក៏ចាកចេញពីផ្ទះអ៊ំទៅរស់នៅនិងជួយរកខុសឲ្យក្រុមប្រជាជនដែលរម្ងាស់ស្លុកត្នោត ។ ប្រជាជនដែលរំងាស់ស្លុកត្នោតបានជួយលាក់បំពួន ហុង ឲ្យរួចពីការតាមចាប់របស់កងឈ្លប ។ នៅខែកញ្ញា ឆ្នាំ១៩៧៧ មានព្រឹត្តិការណ៍មួយកើតឡើង អង្គការប្រកាសថា «សោភ័មក្បត់» ។ នៅភូមិភាគបូព៌ាមានការច្របូកច្របល់ ។ អង្គការបើកទូលាយហើយប្រកាសថា «អ្នកណាចង់ទៅរស់នៅទីណា អាចទៅបាន» ។ ជាសំណាងល្អសម្រាប់ ហុង ឪពុករបស់គាត់ក៏បានធូរស្បើយពីជំងឺនិងអាចដើរបាន ។ ទាំងពីរនាក់ឪពុក និងកូនបានរៀបចំរៀបខ្លួនមកនៅជាមួយអ៊ំប្រុសខាងឪពុកនៅឃុំស្វាយអន្ទរ ។ នៅពេលមកដល់ទីនេះ ប្រធានភូមិបានចោទគាត់ទាំងពីរនាក់ថាជា «ប្រជាជន១៧មេសា» ត្រូវបញ្ជូនទៅដីខ្លាញ់ដែលស្ថិតនៅភាគខាងលិច ប្រហែលជានៅក្នុងខេត្តពោធិសាត់និងបាត់ដំបង ។

កាលនោះមានកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីពី-បីនាក់ បាននិយាយក្នុងមិទ្ទីងឃោសនាប្រាប់ប្រជាជនថា "ទៅដីខ្លាញ់ចុះ គឺធ្វើស្រែមិនបាច់មានទឹកមានអីទេ នៅទីនោះគេមានប្រព័ន្ធធារាសាស្ត្រ មានម៉ាស៊ីនបូមទឹករបស់ចិនទំនើបណាស់ ហើយសំបូរត្រីផ្លែឈើ មិនខ្វះហូបទេ" ។ ពេលនោះអ៊ំប្រុសរបស់ ហ៊ុង បានទៅតវ៉ាជាមួយប្រធានភូមិស្វាយអន្ទរថា "ប្អូននិងក្មួយប្រុសខ្ញុំមិនធ្លាប់រស់នៅភ្នំពេញ មិនមែនជាអ្នក១៧មេសាទេ គឺជាប្រជាជនចាស់រស់នៅក្នុងភូមិអង្គរយស ។ ដោយសារគ្នារស់នៅទីនោះវាកំព្រឹកំព្រា បានជាគ្នាមកសុំស្នាក់អាស្រ័យនៅស្វាយអន្ទរនេះ" ។ ប្រធានភូមិក៏យល់ព្រមលុបឈ្មោះ ហ៊ុង និងឪពុកចេញពីបញ្ជីវិញ ហើយឲ្យរស់នៅភូមិស្វាយអន្ទររហូតដល់ព្រឹត្តិការណ៍វៀតណាមចូលមកកម្ពុជានៅឆ្នាំ១៩៧៩ ។ ឪពុករបស់ ហ៊ុង ត្រូវបានចាត់តាំងឲ្យទៅនៅខាងក្រុមនេសាទ ចំណែក ហ៊ុង នៅជាមួយអ៊ំប្រុស មានភារកិច្ចជួយមើលគោ កើបអាចម៍គោក្របី និងដើរចាប់កណ្តុរនៅតាមស្រែប្រាំង ។

ទោះបីជា ហ៊ុង មានភ័ព្វវាសនាបានរួចផុតពីសេចក្តីស្លាប់ក៏ដោយ ក៏សេចក្តីទុក្ខសោកនិងសេចក្តីឈឺចាប់នៅតែញាំញីក្នុងចិត្តរបស់គាត់រហូតមកដល់សព្វថ្ងៃ ។ នៅពេលមានពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរនិងវៀតណាម ពេលភ្ជុំបិណ្ឌ ជាពិសេសពេលគាត់រៀបអាពាហ៍ពិពាហ៍មានញាតិមិត្តមកជួបជុំគ្នា ហ៊ុង មានអារម្មណ៍ថាខ្លួនគាត់ឯកោណាស់ ហើយនៅតែនឹកឃើញជានិច្ចនូវសម្តីចុងក្រោយរបស់ម្តាយគាត់ថា "បើទឹកដោះម្តាយថ្ងៃ គង់តែម្តាយបានជួបកូនវិញទេ" ។ នៅទីបញ្ចប់ ហ៊ុង មិនបានជួបម្តាយរបស់គាត់រហូត ។ ម្តាយ បងប្អូន និងសាច់ញាតិរបស់ ហ៊ុង ត្រូវខ្មែរក្រហមយកទៅសម្លាប់ដោយមូលហេតុក្រុមគ្រួសាររបស់គាត់ជាប់ពូជពង្សជាវៀតណាម ។ ពៅ ហ៊ុង បានរៀបការជាមួយប្អូនស្រីជីដូនមួយដែលត្រូវជាកូនម្តាយធំដែល ហ៊ុង ភៀសខ្លួនទៅស្នាក់នៅឯកំពង់ឫស្សី ។ ចំណងដៃអាពាហ៍ពិពាហ៍របស់ ហ៊ុង បានផ្តល់នូវកូនប្រុសម្នាក់ ។ កូននេះហើយដែលបានធ្វើឲ្យ ហ៊ុង ធូរស្បើយពីទុក្ខសោកខ្លះ ។ ប៉ុន្តែឧបទ្ទវហេតុមួយបានកើតឡើងនៅពេលភ្ជុំបិណ្ឌឆ្នាំ១៩៩៦ ក្នុងពេលដែលប្រពន្ធនិងកូនប្រុសរបស់ហ៊ុង ធ្វើដំណើរតាមកាណូតទៅលេងផ្ទះម្តាយនៅកំពង់ឫស្សី ។ នៅពេលត្រឡប់មកវិញដល់ស្ពានមួយមានទឹកហូរខ្លាំង ក្បាលកាណូតរេទៅបោកនឹងស្ពានបណ្តាលឲ្យបែកកាណូត ។ កូនប្រុសរបស់ ហ៊ុង ក៏លង់ទឹកស្លាប់នៅពេលនោះ ។ ការបាត់បង់កូនប្រុសជាទីស្រឡាញ់កាន់តែធ្វើឲ្យ ហ៊ុង នឹកឃើញឡើងវិញនូវរឿងរ៉ាវទុក្ខសោកដែលខ្មែរក្រហមបាន យកម្តាយនិងបងប្អូនសាច់ញាតិ របស់គាត់ទៅសម្លាប់យ៉ាងអាណោចអាធ័ម ។

ជាចុងក្រោយនេះ ពៅ ហ៊ុង សង្ឃឹមថា ក្នុងពេលអនាគតដ៏ខ្លីខាងមុខនេះនឹងមានតុលាការឯករាជ្យមួយជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ដើម្បីរកយុត្តិធម៌ឲ្យជនស្លូតត្រង់ទាំងឡាយដែលត្រូវខ្មែរក្រហមយកទៅសម្លាប់ដោយអយុត្តិធម៌ ។ ម្យ៉ាងទៀត ហ៊ុង បានសំណូមពរដល់អ្នកដឹកនាំក្រោយៗទៀតថា "កុំឲ្យប្រកាន់ពូជសាសន៍ បានជាគ្នារស់នៅទីនេះយូរលង់តាំងពីដូនតាមកហើយ សូមឲ្យគ្នារស់បានសុខសាន្តដូចប្រជាជនដទៃទៀតនៅទូទាំងប្រទេសផង" ។

**ឡុង ដានី**

## ពាក្យស្លោកខ្មែរក្រហម

◆ ដើម្បីសម្រេចកិច្ចការរបស់បក្សបាន ត្រូវយកផលប្រយោជន៍ពីប្រជាជន ប្រើលើសកលលោក មិនមែនពួកម្ចាស់ដី មិនមែនដើម្បីអ្នកមាន មិនមែនដើម្បីសម្រាប់ពួកប្រតិកិរិយាមនុស្សខាងស្តាំ។

◆ បដិវត្តន៍ចក្រពត្តិមិនមែនអញ្ជើញភ្ញៀវទៅពិសាបាយទេ មិនមែនសរសេរអត្ថបទទេ មិនមែនប៉ាក់ផ្កាទេ មិនមែនត្រូវអប់រំទេ ទន់ទេ មិនត្រូវព្រងើយកន្តើយ សុភាពរាបសារទេ មិនត្រូវខ្លាចខ្លាំងទេ បដិវត្តន៍គឺជាកំហឹងខណ្ណៈមួយ វាយរំលំខណ្ណៈមួយ។

(សៀវភៅកំណត់ហេតុរបស់សមមិត្ត ញ៉ុក សារុន)

*ប្រលោមលោកបដិវត្ត*

# ពលិកម្មម៉ែៗយើង

***(តពីលេខមុន)***

*តែខ្ញុំឮម៉ែខ្សឹបប្រាប់ខ្ញុំតិចៗថា "កុំយំកូន! កុំយំនៅមុខខ្មាំងដាច់ខាត!" សម្តីដ៏ម៉ឺងម៉ាត់នេះធ្វើឲ្យទឹកភ្នែកខ្ញុំដែលហៀបតែហូរចេញមកហើយ ឈប់ទើនៅត្រឹមក្នុងរង្វង់ត្របកភ្នែកទៅវិញ ។ ខ្ញុំមិនលើកដៃជូតទឹកភ្នែកដែលដក់លើកែវភ្នែកខ្ញុំទេ កុំឲ្យខ្មាំងវាមើលឃើញវាខ្ញុំយំ ។ ខ្ញុំខាំធ្មេញសង្រ្កឹតជំនួសវិញ ។ ខ្ញុំជាកូនពុក កូនម៉ែ ខ្ញុំត្រូវតែរឹងប៉ឹងដាច់ខាតនៅចំពោះមុខខ្មាំងឲ្យដូចគំរូពុកម៉ែខ្ញុំ ។*

*តាំងតែអត់ពីពុកទៅ ម៉ែធ្លាក់ខ្លួនឈឺ ។ យើងលក់អស់ហើយទ្រព្យសម្បត្តិបន្តិចបន្តួចដែលនៅសេសសល់ រហូតដល់គោរអំពែទៀត ។ អាគ្មោតនិងអាប្រដេះលែងបានខ្ញុំឃ្វាលទៀតហើយ យើងបានខ្វារកកាយលក់សព្វលក់គ្រប់ ទីបំផុតយើងគ្មានអីលក់តទៅទៀតទេ ។ យើងជំពាក់ថ្លៃដី អាឈ្មួន កាន់តែច្រើនឡើង ។ ឯបាយទឹកបានគ្រួសារ តាឃុត និង អ៊ំណាម ជួយមកជាហូរហែដែរ តែធ្វើម៉េចនឹងគ្រប់គ្រាន់បើគាត់ក៏ខ្វះខាតដែរ ។ បងទៅជួយធ្វើស្រែគេ ជួយឃ្វាលគោគេ បានអង្ករខ្លះជួយទប់ទល់ ។ ខ្ញុំទៅកាប់អុស បេះបណ្តូលថេរ បណ្តូលរកាំ ជីកក្តួច ជីកដំឡូង យកមកផ្សេងផ្សំនាយអាយគ្រាន់បានបន្តជីវិតដើម្បីតស៊ូបន្តទៅទៀត ។ ទោះបីឈឺយ៉ាងនេះក្តី ក៏ម៉ែនៅពុំស្ងៀមដែរ នៅពេលដែលម៉ែអាចក្រោកបាន ម៉ែក្រោកទប់ខ្លួនទៅនឹងជញ្ជាំងឬសសរផ្ទះ ប្រឹងវេញខ្សែគោឬធ្វើល្អីពុំទំនេរដៃទេ ។ នៅពេលដែលវិលមុខខ្លាំងទើបម៉ែសម្រាក ។*

*ក្រោយមកម៉ែក៏បានជាសះស្បើយ ។ ខ្ញុំ បង និងបងប្អូនជិតខាង ត្រេកអរខ្លាំងណាស់ ។ បានជាពីជំងឺក្លាម ម៉ែចុះធ្វើស្រែក្លាម ។ យើងធ្វើស្រែអត់គោទេ ។ ម៉ែធ្វើសត្វគោទាញនង្គ័លបងធ្វើអ្នកភ្ជួរ ខ្ញុំជួយសង្កត់ដងនង្គ័លបង ។ ភ្ជួរបានមួយជុំស្រែ ម៉ែឈប់ម្តង ម៉ែហត់ខ្លាំងណាស់ ដង្ហក់ដង្ហើមសឹងមិនដល់គ្នា ។ ដីនោះសោតក៏ស្អិតល្អិតដូចក្រមួនអ៊ីចឹង ផាលចាក់មិនចង់របើក ។ បើយើងខ្ចីគោបងប្អូនជិតខាងបាន យើងភ្ជួរនៅពេលយប់ៗក៏មាន ភ្ជួរនៅពេលភ្លៀងខ្យល់ក៏មាន ព្រោះពេលថ្ងៃបងប្អូនជាប់ភ្ជួរដែរ ។ ត្រូវតែតស៊ូដូច្នេះទើបបានហូប បានដោះបំណុលគេបានជួយឧបត្ថម្ភបដិវត្តន៍ ។ នៅគ្រប់ពេលលំបាកយ៉ាប់យ៉ឺនខ្លាំងម៉ែតែងតែធ្វើគំរូយើងជានិច្ច ។ ពេលបានស្រូវមក ម៉ែតែងលាក់ទុកមួយចំនួនបញ្ជូនតាមពូនឿនទៅឲ្យមិត្តយើងនៅឯភ្នំឯណោះ ។ មានម្តងនោះ ម៉ែហាលចេកបានមួយចំនួនហើយខ្ចប់ទៅផ្ញើមិត្តយើង ។ ខ្ញុំចូលមកទាន់ម៉ែកំពុងលិទ្ធដៃដែលជាប់ជាតិផ្អែមនោះយ៉ាងឆ្ងាញ់ ។ ខ្ញុំនឹកខ្លោចចិត្តអាណិតម៉ែ ខ្ញុំសួរម៉ែថា: "ម៉េចក៏ម៉ែមិនយកចេកមួយពិសាទៅ?" ម៉ែឆ្លើយថា: "កុំអីកូន! ចេកនេះយើងសម្រិតសម្រាំងទុកជូនមិត្តយើងចុះ ។ មិត្តយើងតស៊ូវេទនាជាងយើងនេះឆ្ងាយណាស់ ។ មិត្តយើងនៅឯព្រៃ ឯណោះសម្រាកឥតមានមុង ត្រូវមូលដែកគោលខាំគ្រុនចាញ់ តាកែខាំរលេះរលួយខ្លួន ទាកខាំបឺតឈាមពាសពេញប្រាណ ។ ជួនកាលអត់បាយ២-៣ថ្ងៃ ។ ជួនកាលដាច់បាយមួយអាទិត្យហូបតែស្លឹកឈើ ។ ពេលឈឺគ្មានថ្នាំសង្កូវទេ ។ យើងនៅឯភូមិយ៉ាងហោចណាស់ក៏មានញាតិមិត្តជិតខាងជួយជ្រោមជ្រែងដែរ ។ ម៉ែគ្រាន់តែលិទ្ធឲ្យស្គាល់រសជាតិប៉ុណ្ណេះបានហើយ!" ។*

*ក្រោយមក ពូនឿន បានប្រគល់ភារកិច្ចឲ្យម៉ែទទួលខុសត្រូវក្នុងការនាំស្បៀងទៅឯភ្នំ ។ ម៉ែបំពេញភារកិច្ចនេះដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត ។ ម្តងនោះ ម៉ែទៅបាត់អស់កន្លះខែឥតឃើញត្រឡប់មកផ្ទះវិញសោះ ។ ខ្ញុំនិងបងទន្ទឹងមើលផ្លូវម៉ែរៀងរាល់ថ្ងៃ ។ ថ្ងៃមួយ មីងធីម យកដំណឹងមកប្រាប់បងនិងខ្ញុំថាម៉ែត្រូវពួកទាហានចាប់យកទៅឃុំឃាំងនៅបន្ទាយត្រែងបាត់ទៅហើយ ។ គេចោទពីបទដឹកស្បៀងទៅផ្គត់ផ្គង់ពួក "ខ្មែរក្រហម" ។ ស្អែកឡើង យើងធ្វើដំណើរទៅសួរសុខទុក្ខម៉ែនៅត្រែង ។ យើងសុំដោយសាររទេះគោអ្នកភូមិ ។ ធ្វើដំណើរអស់មួយថ្ងៃទើបដល់ត្រែង ។ ពេលមកដល់ត្រែងល្ងាចទៅហើយ*

យើងត្រូវនៅសំរាកក្រោមបន្ទាយមួយយប់សិន ។ ខ្ញុំបន់ឲ្យតែឆាប់ភ្លឺនឹងអាលបានជួបមុខម៉ែ ។ ស្អែកព្រឹក យើងទៅសុំច្បាប់អនុញ្ញាតជាមួយបងប្អូនដទៃទៀត ដើម្បីចូលជួប"អ្នកទោស"ពីមេបញ្ជាការ ។ យើងចាំតាំងពីម៉ោង៦ព្រឹករហូតដល់ម៉ោង១១ថ្ងៃត្រង់ទើបពួកវាបញ្ចេញ"អ្នកទោស"ឲ្យមកជួបមិត្តញាតិ ។ ពេលគេបញ្ចេញ "អ្នកទោស"មក ខ្ញុំខំវែកគេវែកឯងរកមើលម៉ែ តែមិនឃើញម៉ែខ្ញុំសោះ ឃើញតែម៉ែគេ ។ ខ្ញុំតោងខ្សែលួសបន្លាដែលពួកវាចងខ័ណ្ឌ"អ្នកទោស"ហើយនិងញាតិមិត្តដែលទៅសួរ ខំមាត់ភ្នែករំពៃពីឆ្វេងទៅស្តាំ ពីលិចមកកើត រកមើលម៉ែចង់ផ្សាភ្នែកតែនៅតែមិនឃើញម៉ែខ្ញុំសោះ ។ បងរៀបនឹងទៅសួរអាមេបញ្ជាការទីឃុំឃាំងដើម្បីសុំវាបើកបញ្ជីឈ្មោះមើល តើមានឈ្មោះម៉ែខ្ញុំឬអត់ ។ បងទាញដៃខ្ញុំទៅ តែខ្ញុំនៅពុំទាន់អស់ចិត្តនៅឡើយ ។ ខ្ញុំហៀបនឹងឈានជើងចេញពីទីនោះទៅហើយ ស្រាប់តែមានដៃគ្រោតគ្រាតរឹងដូចថ្មមួយមកចាប់ដៃខ្ញុំជាប់យ៉ាងណែន ហើយព្រុសសំឡេងមួយបន្លឺឡើងខ្សាវៗថា "កូនស្រីម៉ែ! កូនស្រីម៉ែ!" ខ្ញុំភ្ញាក់ព្រើត ចង់កន្ត្រាក់ដៃចេញពីខ្សែលួសបន្លាភ្លាម តែហាក់ដូចជាមានកម្លាំងអ្វីមួយទប់ខ្ញុំមិនឲ្យដកដៃទៅវិញ ។ ខ្ញុំងាកទៅរកម្ចាស់សំឡេង ឃើញអ្នកទោសស្រីម្នាក់សក់ក្បាលកន្ទ្រើងឡើងក្រហមប្រេញ កមរមាស់និងដំបៅកើតពាសពេញខ្លួន នៅសល់តែគ្របកភ្នែកឡើងខ្មៅជាំឃើញតែប្រស្រីភ្នែកឡើងសស្លេត ។ ខោអាវគាត់ពាក់ពុំដឹងជាពណ៌អ្វីទេ ព្រោះវាប្រែក្លាយពីក្រណាត់សំពត់ធម្មតាមកជាកន្ទបរយីរយៃ ប៉ះផុតប៉ះដើយប៉ប៉ះប៉ប៉ុន លេចមុខលេចក្រោយ កណ្តេកកណ្តាច មិនជាបើនឹងមើលឡើយ ។ ខ្ញុំខំសម្លឹងមើលដែរ តែពុំស្គាល់ជានរណាសោះ ។ ទាល់តែខ្ញុំឃើញម្រាមដៃកំបុតពីរទើបខ្ញុំដឹងថាជាម៉ែខ្ញុំ ។ គ្រាន់តែបែកគ្នាកន្លះខែប៉ុណ្ណោះ ម៉ែប្រែសភាពពីមនុស្សទៅជាគំរោងឆ្អឹងដណ្តប់ស្បែក ។ ខ្ញុំអួលណែនដើមកនឹកអាណិតម៉ែខ្ញុំខ្លោចចិត្ត ។ ដោយយើងឱបគ្នាពុំកើត ព្រោះទើសនឹងលួសបន្លា ខ្ញុំចាប់ដៃម៉ែទាំងពីរមកដាក់លើថ្ពាល់ខ្ញុំ ហើយទឹកភ្នែកខ្ញុំក៏ហូរមកដូចទឹកបាក់ទំនប់ ស្រោចស្រប់លើដៃម៉ែជោកជាំ ។ ចំណែកបង គាត់អត់និយាយអីចេញទេ ក្រៅពីគ្រវីក្បាល ហើយបន្លឺពាក្យថា "ហ៊ឺម៉ែខ្ញុំ! ហ៊ឺម៉ែខ្ញុំ!" ។ បងស្រាយកញ្ចប់កំពឹសលីង ត្រីរ៉ស់អាំងនិងបាយកញ្ចប់ជូនម៉ែ ។ ខ្ញុំហុចកញ្ចប់ចេកហាលជូនម៉ែ ។ យើងគ្មានអ្វីក្រៅពីនេះទេ ។ ឃើញកញ្ចប់ចេកហាលភ្លាម ម៉ែបន្ទោសយ៉ាងស្រទន់ថា "ម៉េចក៏កូនមិនទុកផ្ញើទៅជូនមិត្តយើងនៅឯភ្នំ" ខ្ញុំឆ្លើយថា "អានេះនៅសល់ទេ ទើបខ្ញុំខ្ចប់មកជូនម៉ែ" ។ ខ្ញុំយកដៃទាំងពីរទៅទ្រោបលើទ្រូងម៉ែ ។ ម៉ែញោចខ្លួនសម្តែងអាការៈឈឺចាប់ ។ ខ្ញុំសួរម៉ែថា "ម៉ែកើតអី?" ម៉ែឆ្លើយថា "អត់កើតអីទេ" ហើយគាត់បន្ទប់ទៅនិយាយរឿងផ្សេងវិញ ។ នៅពេលក្រោយទេទើបខ្ញុំដឹងថាទ្រូងរបស់ម៉ែត្រូវពួកអាខ្មាំងយោរយៅទាំងនោះវាយកភ្លើងបារីអុជឡើងសុស ដើម្បីបង្ខំគាបឲ្យម៉ែសារភាពប្រាប់វាពីកន្លែងដែលយុទ្ធមិត្តយើងពួនក្នុងព្រៃ ។ តែម៉ែប្រយុទ្ធដាច់ខាត ។ ចម្លើយដែលវាបានពីម៉ែគឺពាក្យថា "អត់ដឹង"រហូត ។ វាយកម៉ែទៅធ្វើទារុណកម្មរហូតដល់សន្លប់ ៤-៥ដងក្នុងមួយថ្ងៃ ។ វាយកម៉ែទៅដាក់ក្នុងគុកកំបោរបង្អត់បាយបង្អត់ទឹក ។ ពេលខ្លះម៉ែហូបទឹកនោមខ្លួនឯងដោយស្រេកខ្លាំងពេក ។ តែពួកវានៅតែអត់បានទទួលលទ្ធផលអីសោះ ។

ម៉ែផ្តើមសួរខ្ញុំថា "កូន! ពូនឿន មានមកផ្ទះយើងទេ?" ខ្ញុំឆ្លើយថា "អត់ឃើញទេ" ។ ម៉ែបន្តទៀតថា "ហ៊ឺ! មើលទៅមិត្តយើងនៅឯភ្នំប្រហែលដាច់ពោះស្លាប់ហើយមើលទៅ! ម៉ែពុំទាន់នាំស្បៀងដល់មូលដ្ឋានផង ត្រូវខ្មាំងវាចាប់បានមុន គួរឲ្យស្តាយណាស់!" ។ និយាយមកដល់ត្រឹមនេះ ទឹកភ្នែកពីរតំណក់រមៀលធ្លាក់តាមថ្ពាល់ម៉ែ ។ ម៉ែច្របាច់ដៃកូនទាំងពីរយ៉ាងណែន ។ ម៉ែនិយាយមករកខ្ញុំនិងបងថា "កូនទាំងពីរត្រូវបំពេញភារកិច្ចនេះជួសម៉ែឲ្យបានដាច់ខាតណា៎! ឲ្យបានដាច់ខាតទើបម៉ែអស់ចិត្ត ឲ្យបានដាច់ខាតទើបម៉ែស្លាប់ទៅបិទភ្នែកជិត ។ កូនទាំងពីរសន្យាជាមួយម៉ែមកថា សម្រេចកិច្ចការនេះឲ្យបានដល់ទីដៅ" ។ និយាយបណ្តើរ ម៉ែអង្រួនស្មាយើងទាំងពីរនាក់បណ្តើរ ។ សន្ទុះចិត្តស្នេហាបដិវត្តន៍ ស្នេហាប្រជាជនរបស់ម៉ែ ឆ្លងជ្រាបចូលមកក្នុងបេះដូងខ្ញុំតាមរយៈពន្លឺកែវភ្នែកម៉ែ តាមដង្ហើមម៉ែ តាមដៃដ៏ក្តៅរបស់ម៉ែ ។ ការនេះធ្វើឲ្យខ្ញុំរំភើបឥតឧបមា ហើយខ្ញុំនិងបងខ្ញុំក៏ឆ្លើយព្រមគ្នាថា "ដាច់ខាតខ្ញុំនឹងបំពេញភារកិច្ចនេះឲ្យបានជូនអង្គការ" ។ កុំតែទើសនឹងខ្សែលួសបន្លា កុំអីម៉ែយើងចាប់យើងទាំងពីរថើបញាក់ញីយ៉ាងណាទេ ។...

**(នៅមានត)**

**(តមកពីទំព័រ៣)** បងថ្លៃខ្ញុំត្រូវបានវាយដំយ៉ាងឃោរឃៅ ដោយសារប្រព្រឹត្តអំពើដែលខ្មែរក្រហមហៅថា "បទខុក្រិដ្ឋ" ។ គាត់ដេកនៅលើគ្រែ ដើរទៅណាក៏មិនរួច ហូបអ្វីក៏មិនបាន ចុងបញ្ចប់គាត់ក៏ដាច់ខ្យល់ស្លាប់ទៅ ។ បងស្រីខ្ញុំមិនរាយការណ៍ជូនអង្គការភ្លាមទេ ដោយទុកសាកសពបងថ្លៃខ្ញុំរហូតដល់ជិតមួយសប្តាហ៍ដើម្បីអាចមានឱកាសទទួលបាននូវរបបហូបចុកសម្រាប់យកមកចិញ្ចឹមកូនតូចៗ ។ សាកសពរបស់បងថ្លៃខ្ញុំទុកនៅលើដំណេកដដែលជាមួយនឹងកូនតូចៗដែលនៅគោងគាត់ជាប់ ។

ក្មួយស្រីខ្ញុំឈឺកាន់តែធ្ងន់ទៅៗ ដោយសារជំងឺពកសាច់ ។ នៅក្នុងរបបខ្មែរក្រហមគ្មានថ្នាំសង្កូវទំនើបៗ សម្រាប់ព្យាបាលទេ ។ ជាការពិត គ្មានការព្យាបាលថែទាំជំងឺទាល់តែសោះឡើយនៅជំនាន់នោះ ។ ក្មួយស្រីខ្ញុំចេះតែទ្រាំទទួលរងនូវការឈឺចាប់ឥតស្រាកស្រាន្ត ធ្វើអ្វីមិនកើត គិតតែពីស្រែកយំជារៀងរាល់ថ្ងៃរហូតដល់ថ្ងៃមួយវាក៏ឈប់យំរហូត ។ បងស្រីរបស់វានៅចាំបានថាកាលណោះគឺជារដូវវស្សាធ្លាក់ភ្លៀងជោកជាំ ហើយមានទឹកជំនន់ទៀតផង ។ សាកសពក្មួយស្រីរបស់ខ្ញុំដែលស្ថិតនៅលើគ្រែក៏រសាត់អណ្តែត ។ ចាប់តាំងពីពេលនោះមក គ្មានអ្នកណាបានឃើញស្រមោលសាកសពក្មួយស្រីខ្ញុំទៀតទេ ។

ក្រោយមកទៀត កូនប្រុសរបស់បងស្រីខ្ញុំដែលនៅជាទារកនៅឡើយ ក៏ត្រូវស្លាប់ដោយសារខ្វះទឹកដោះជៅ ។ បងស្រីខ្ញុំអត់អាហារហូប យូរៗទៅក៏អត់ទឹកដោះឲ្យកូនជៅ ។ នៅឆ្នាំ១៩៧៧ បងស្រីខ្ញុំត្រូវបានចោទថាបានលួចបាយសមូហភាព ។ បងស្រីខ្ញុំប្រកែកថាគាត់មិនបានធ្វើដូច្នេះទេ ប៉ុន្តែកម្មាភិបាលខ្មែរក្រហមនៅតែមិនជឿគាត់ ។ កម្មាភិបាលខ្មែរក្រហមម្នាក់វះពោះបងស្រីរបស់ខ្ញុំ ។ ជាលទ្ធផល បងស្រីខ្ញុំត្រូវស្លាប់ដោយអាណោចអាធ័មជាទីបំផុត ។ សិទ្ធិដែលសំខាន់បំផុតរបស់មនុស្សគឺសិទ្ធិរស់រានមានជីវិត ។ សិទ្ធិរស់រានមានជីវិតរបស់បងស្រីខ្ញុំ បងថ្លៃខ្ញុំ ក្មួយស្រីខ្ញុំ និងកូនងើតរបស់បងស្រីខ្ញុំ ត្រូវបានខ្មែរក្រហមដកហូតទាំងអស់ ។ រឿងរ៉ាវចេញពីគ្រួសារខ្ញុំ ធ្វើឲ្យខ្ញុំក្រៀមក្រំជានិច្ចរាល់ពេលដែលខ្ញុំរំឭករឿងនេះឡើង ។ នេះមិនមែនដោយសារវាជារឿងផ្ទាល់ខ្លួនពេកទេ ប៉ុន្តែវាជារឿងទូទៅ ។ គ្រប់ក្រុមគ្រួសារនៅក្នុងប្រទេសកម្ពុជាទាំងអស់ សុទ្ធតែទទួលរងនូវការរំលោភឈឺចាប់ក្រោមរបបខ្មែរក្រហមប្រហាក់ប្រហែលគ្នា ។ យើងមិនទទួលយកពិភពលោកមួយដែលមនុស្សធ្វើខុសហើយមិនទទួលទោសនោះទេ ។ ព្រះអាចសន្តោសប្រណីទោសឲ្យចារីនៃបទល្មើសបាន ប៉ុន្តែប្រជាជនមិនអាចផ្សះផ្សាជានាជាមួយគ្នាវិញបានទេ ប្រសិនបើយុត្តិធម៌និងការពិតមិនត្រូវបានលាតត្រដាងទេនោះ ។ យើងចង់រស់នៅក្នុងបច្ចុប្បន្នកាល ។ យើងមិនចង់រស់នៅក្នុងអតីតកាលទេ ។ ក៏ប៉ុន្តែអតីតកាលនៅតែតាមលងយើងជានិច្ចមិនចេះចប់មិនចេះហើយ ។ យើងចាំបាច់ត្រូវតែបញ្ចប់បញ្ហានេះឲ្យបាន ។ ប្រសិនបើគ្មានធ្វើសកម្មភាពអ្វីសោះនោះ វានឹងក្លាយជាគំរូដ៏អាក្រក់សម្រាប់កម្ពុជាទាំងមូលនិងជាគំរូអាក្រក់សម្រាប់ពិភពលោកនៅសតវត្សរ៍នេះ ។

យើងទាំងអស់គ្នាត្រូវជួយដល់ប្រជាជនកម្ពុជាក្នុងការស្វែងរកការពិត ស្វែងរកយុត្តិធម៌ និងសម្រេចបាននូវការបង្រួបបង្រួមនិងផ្សះផ្សាជាតិ ។ យើងរាល់គ្នាត្រូវបានបដិសេធពីការពិត យុត្តិធម៌និងការបង្រួបបង្រួមជាតិយូរណាស់មកហើយ ។ ករណីបែបនេះគឺមិនមែនជាការត្រឹមត្រូវទេ ។ ប្រសិនបើអង្គការសហប្រជាជាតិបដិសេធមិនព្រមចូលខ្លួនមកចរចាសាជាថ្មី យ៉ាងហោចណាស់ អង្គការសហប្រជាជាតិគួរតែចាត់តាំងឲ្យមានតំណាងអង្គការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិមកទាក់ទងដោយផ្ទាល់ជាមួយប្រជាជនកម្ពុជាដើម្បីពន្យល់ប្រាប់ប្រជាជនកម្ពុជាថាតើអង្គការសហប្រជាជាតិខ្លួនឯងចង់ឬមិនចង់ចូលរួមជាមួយកម្ពុជា ក្នុងការស្វែងរកយុត្តិធម៌នៃអំពើប្រល័យពូជសាសន៍ ហើយប្រសិនបើចង់ចូលរួមក្នុងគោលគំនិតនេះដែរ តើអង្គការសហប្រជាជាតិនឹងធ្វើយ៉ាងដូចម្តេចខ្លះ ។ រដ្ឋាភិបាលកម្ពុជាក៏មានកាតព្វកិច្ចដូចគ្នានេះដែរក្នុងការពន្យល់អំពីគោលនយោបាយរបស់ខ្លួនឲ្យប្រជាជនបានដឹងច្បាស់ ។ តាមរយៈការឆ្លងកាត់ផ្ទាល់ខ្លួនក៏ដូចជារបស់ក្រុមគ្រួសារ សមាជិករាជរដ្ឋាភិបាលច្បាស់ជាដឹងយ៉ាងច្បាស់អំពីការឈឺចាប់ដែលប្រជាជនកម្ពុជាទទួលរងក្នុងរបបខ្មែរក្រហមនិងការភ័ន្តច្រឡំច្របូកច្របល់ដែលជនរងគ្រោះនៅតែបន្តមានក្នុងខណៈដែលយុត្តិធម៌របស់ខ្លួនកំពុងត្រូវបានបដិសេធចោល ។ រដ្ឋាភិបាលកម្ពុជាក៏ដូចជាអង្គការសហប្រជាជាតិដែរ គឺត្រូវតែស្តែងចេញជាសកម្មភាពដើម្បីយុត្តិធម៌នៃអំពើប្រល័យពូជសាសន៍ ។

**ឆាំង យុ**

# លិខិតពីស្រុកប្រាសាទបល្ល័ង្ក

ឯកឧត្តមជាទីគោរព ក្នុងនាមអាជ្ញាធរដែនដី ក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការកោតសរសើរយ៉ាងស្មោះអស់ពីដួងចិត្ត ចំពោះស្នាដៃស្រាវជ្រាវរបស់ឯកឧត្តមព្រមទាំងសហការី ក្នុងការស្រាវជ្រាវទាំងរូបភាពប្រភពព័ត៌មានក៏ដូចជាវត្ថុតាងនានា មកថតបោះពុម្ពផ្សព្វផ្សាយបង្ហាញដល់ពលរដ្ឋខ្មែរទាំងក្នុងនិងក្រៅប្រទេស ដើម្បីបានយល់ជ្រួតជ្រាបនិងស៊ីជម្រៅនូវសោកនាដកម្មដ៏រន្ធត់ដែលមិនអាចពិពណ៌នាបានឲ្យបានអស់ក្នុងប្រវត្តិសាស្ត្ររបស់ខ្មែរយើងនេះ ដែលបណ្តាលមកពីអ្នកដឹកនាំនៃរបបគ្រប់គ្រងកម្ពុជាប្រជាធិបតេយ្យ ព្រោះថារូបភាពនិងឯកសារប្រភពព័ត៌មានទាំងអស់នេះគឺបានក្រើនរំឭកឲ្យប្រជាពលរដ្ឋខ្មែរគ្រប់រូបនឹកឃើញនិងចងចាំមិនអាចបំភ្លេចបានទៅសម័យ៣ឆ្នាំ៨ខែនិង២០ថ្ងៃ ។ ជាគុណប្រយោជន៍ដល់យុវជនយុវនារីដែលកើតក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩ ដែលពួកគេមិនបានឃើញផ្ទាល់ភ្នែកនិងមិនបានឆ្លងកាត់ជួបប្រទះនោះ ។ ពិសេសប្រភពព័ត៌មានឯកសារនិងរូបភាពវត្ថុតាងទាំងអស់នេះ ហើយដ្បិតតែមិនបានគ្រប់រាល់សកម្មភាពទាំងអស់របស់របបប៉ុលពតនេះក៏ដោយ ក៏អាចជួយជាទុនដល់ស្ថាប័នតុលាការជាតិនិងអន្តរជាតិក្នុងការកាត់ទោសមេដឹកនាំនៃរបបយង់ឃ្នងព្រៃផ្សៃនេះ ។ ឯកឧត្តមជាទីគោរព! មុនពេលដែលទស្សនាវដ្តីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានបោះពុម្ពនិងចេញផ្សាយ រូបខ្ញុំតែងតែគិតថារាល់អាថ៌កំបាំងនិងបទឧក្រិដ្ឋផ្សេងៗដែលកើតមានឡើងក្នុងរបបប៉ុលពតនោះ ពិតជាមិនងាយនឹងមាននរណាម្នាក់អាចស្រាវជ្រាវចងក្រងកត់ត្រាទុកបានឡើយ ហើយរាល់សកម្មភាពទាំងអស់នោះនឹងអាចលាក់ខ្លួនគេចចេញពីប្រវត្តិសាស្ត្រនិងបាត់បង់ការជឿជាក់ពីមនុស្សខ្មែរជំនាន់ក្រោយៗនិងពិភពលោក ។ ប៉ុន្តែជាសំណាងរបស់ប្រជាពលរដ្ឋខ្មែរយើងណាស់ ដែលរាល់ប្រភពព័ត៌មាន ឯកសាររូបភាព និងវត្ថុតាងផ្សេងៗ ត្រូវបានទស្សនាវដ្តីស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលដឹកនាំដោយឯឧត្តម បានធ្វើការស្រាវជ្រាវនិងកត់ត្រាបានយ៉ាងពិស្តារ ហើយថែមទាំងបានបោះពុម្ពផ្សាយជាសាធារណៈនៅទូទាំងប្រទេសថែមទៀតផង ពិសេសគឺចែកជូនដោយឥតគិតថ្លៃនៅតាមអាជ្ញាធររដ្ឋបាលនានាដែលធ្វើឲ្យសាធារណជនព្រមទាំងមន្ត្រីរាជការកាន់តែយល់ដឹងនិងចងចាំមិនអាចបំភ្លេចបានទៀតផង ។ រូបខ្ញុំសង្ឃឹមថា បងប្អូនជនរួមជាតិខ្មែរយើងដែលបានបាត់បង់អាយុជីវិតដោយគ្មានកំហុស ហើយអ្នកដែលនៅរស់រានមានជីវិតដែលរងគ្រោះនូវសម័យនោះ នឹងបានទទួលយុត្តិធម៌ នៅពេលដែលស្ថាប័នតុលាការកាត់ទោសមេដឹកនាំនៃរបបខ្មែរក្រហមកើតឡើងនៅថ្ងៃខាងមុខ ។ ឯកឧត្តមជាទីគោរព! បន្ទាប់ពីទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពដែលផ្សាយរួចមក រូបខ្ញុំក៏ដូចជាមន្ត្រីរាជការជុំវិញស្រុក អស់លោកមេឃុំ មានការជក់ចិត្តជិតអារម្មណ៍ខិតខំពិនិត្យតាមដានរូបភាពនិងខ្លឹមសាររបស់ទស្សនាវដ្តីស្វែងរកការពិតរាល់លេខដែលសាលាស្រុកនិងសាលាឃុំបានទទួលមកពីមជ្ឈមណ្ឌលឯកសារកម្ពុជានោះ រហូតដល់មានរូបភាពខ្លះនិងអត្ថបទខ្លះបានធ្វើឲ្យរូបខ្ញុំរឹតតែអាណោចអាធ័មនិងរន្ធត់ចិត្តដល់ឪពុករបស់ខ្ញុំព្រមទាំងបងប្អូនខ្មែរយើងដែលបានទទួលទារុណកម្មនិងបាត់បង់អាយុជីវិតក្នុងរបបយង់ឃ្នងនេះ ។ ខ្ញុំគិតថាទោះបីពេលវេលាកន្លងហួសទៅជាង២០ឆ្នាំទៅហើយក្តី ក៏ហាក់បីដូចជានៅពេលថ្មីៗនិងមិនទាន់បានបញ្ចប់និងឃ្លាតឆ្ងាយពីភ្នែកពីអារម្មណ៍នៅឡើយ ។ ពិសេសទៅទៀតរឹតតែធ្វើឲ្យរូបខ្ញុំសម្តែងនូវការដឹងគុណទ្បើងថែមទៀតចំពោះថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជាដែលបានដឹកនាំសង្គ្រោះអាយុជីវិតនិងរំដោះប្រជាជនកម្ពុជាទាំងអស់ឲ្យរួចផុតពីសោកនាដកម្មដ៏ទារុណ ដ៏សាហាវព្រៃផ្សៃនៃរបបគ្រប់គ្រងដ៏សាហាវយង់ឃ្នងនិងអសីលធម៌នេះ ។ រូបខ្ញុំសូមឆ្លៀតយកវេទិកានេះថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយសម្តេច ហ៊ុន សែន ក្នុងការទាមទារឲ្យមានការកាត់ទោសមេដឹកនាំនៃរបប ប៉ុល ពត និងអ្នកពាក់ព័ន្ធនៃការសម្លាប់រង្គាលប្រជាជនខ្មែរយើងសម័យនោះ ។ យើងខ្ញុំជាមន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ព្រមទាំងប្រជាពលរដ្ឋក្នុងស្រុកប្រាសាទបល្ល័ង្កទាំងមូល សូមគាំទ្រយ៉ាងពេញទំហឹងក្នុងការទាមទារឲ្យមានការកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងអស់នោះ ។ ដើម្បីឲ្យបានដឹងថា “ពេលទឹកថ្លាតើយើងអាចមើលឃើញត្រីក៏អត់” ។ ឯកឧត្តមជាទីគោរព! រាល់រូបភាពនិងព័ត៌មានទាំងអស់នេះបានញ៉ាំងឲ្យខ្ញុំយល់ឃើញថាជាឯកសារដ៏មានតម្លៃមិនអាចកាត់ថ្លៃបានសម្រាប់ប្រវត្តិសាស្ត្រជាតិខ្មែរក៏ដូចជាសកលលោកផងដែរ ។ ជាឯកសារដែលចងក្រងឡើងសម្រាប់ជាគុណប្រយោជន៍ដល់សង្គមជាតិកម្ពុជាយើងទាំងពេលបច្ចុប្បន្នក៏ដូចជាទៅអនាគត ។ មិនមែនជាឯកសារសម្រាប់ចងក្រងឡើងសម្រាប់បង្កនូវទំនាស់បែកបាក់ ឬបំផុសគំនុំគុំកួនចងអាឃាតនៅសង្គមកម្ពុជាតទៅទៀតនោះទេ គឺជាប្រទីបដ៏សំខាន់មួយសម្រាប់កូនខ្មែរជំនាន់ក្រោយទុកជាពុទ្ធិនិងធ្វើការពិចារណា ។ យើងខ្ញុំសូមប្រសិទ្ធពរជ័យជូនឯកឧត្តមនិងសហការី សូមទទួលបានសេចក្តីសុខចំរើននិងសម្រេចបាននូវជោគជ័យក្នុងភារកិច្ចដ៏ខ្ពង់ខ្ពស់នេះ ។ ប្រាសាទបល្ល័ង្ក, ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០២ ◆◆◆ **ព្រឹម រដ្ឋា**

ចម្រៀងបដិវត្តន៍ខ្មែរក្រហម

# ជយោ! ថ្ងៃ១៧ មេសា យើងរំដោះភ្នំពេញ

គ្រប់មុខព្រួញយ៉ាងខ្នួលខ្នាញ់បាញ់សម្រុក ចំៗសំបុកបនលក់ស្រុកចោរភ្នំពេញ

កងរំដោះវាយឆើតស្រស់លឿនសស្រាញ់ លោតផ្លោះភ្លៀវផ្ទាញបាញ់តម្រង់ចំមេក្បត់ ។

បនអាណុលឆ្កែផងផុលរត់ចោលស្រុក កងយើងទៅមុខវាយខ្ទេចខ្ទុកឆ្កែចក្រពត្តិ

ទាំងរបបទាំងបុគ្គលមហាក្បត់ វិឲ្យវារលត់ផុតរលាយជាអវសាន ។

បន្ទរៈ ១៧ មេសា ឆ្នាំ៧៥ កងយើងខត្តមបានរំដោះក្រុងភ្នំពេញ គ្រប់មុខព្រួញចូល

ចាប់ដៃយ៉ាងសស្រាញ់ កណ្ដាលក្រុងភ្នំពេញវាយបណ្ដេញអាក្បត់ជាតិ ។

ពីពាយ័ព្យជាប់ខាងជើងឡើងនិរតី អាគ្នេយ៍ជោគជ័យតជាប់ដៃ បូព៌ា ត្បូសាន ទង់បដិវត្ត

បក់រវិចយ៉ាងថ្កើងថ្កាន កណ្ដាលទីលានបាននចតុមុខខ្ពស់ត្រដឹម ។

នេះជាមហាជោគជ័យធំទំហំអស្ចារ្យ ប្រជាកម្ពុជាមហិមាខ្លាំងសម្បើមកងបដិវត្ត ជាកុលបុត្រ

អង់អាចឆ្នើម វាយខ្មាំងឈ្នះសម្បើម អត្តភាពខ្ពស់ស្កឹមស្កៃ ។

បន្ទរៈ ជយោប្រជាជនកម្ពុជាមហិមា កងសេរីកាខ្លាំងអស្ចារ្យវាយយកជ័យ ។

ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្ដីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្ដីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្ដីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: *Searching for the truth.* Number 28, April 2002.
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance;
Canadian International Development Agency (CIDA) through the Civil Society Fund; the Royal Danish Government
and the Royal Netherlands Government, *The Hague.*